# សម័យអាណាព្យាបាលបារាំង



អ្នកនិពន្ធ៖ លោក យុន មុនី

គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ៖
"មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍"
ឆ្នាំ២០២២

គណៈកម្មការនិពន្ធ ៖ លោក ឃុន មុនី
គណៈកម្មការរចនាទំព័រ ៖ លោកស្រី សំបាត់ អ៊ិត លោកស្រី ឈុំ ពៅ
គណៈកម្មការត្រួតពិនិត្យ ៖
១.លោក ថ្លាង សន្តុំ
២.លោកស្រី ឡាំ ប៊ុនមករា

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨%ក្នុងមួយឆ្នាំ។ លើសពីនេះទៀតអត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣%នៅឆ្នាំ២០០៤មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ ក៏កំពុងលេចរូបរាងឡើងដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោក និងតំបន់រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានកំពុងបន្តពង្រឹង និងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវ និងនវានុវត្តន៍ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្ស នៅកម្ពុជាឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូង និងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផលប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូង និងអាហ្វ្រិកមានប្រមាណ៥%នៃការវិនិ យោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជន ពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី?ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួល

មនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ២០០២ នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លង ដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការ ផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អ ជីវភាពរស់នៅ។ សមត្ថភាពទាំងនេះអាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួល បានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំគឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកប ដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិ នឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទា ក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជា សង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជា មូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បាន ពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការ អប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌ នៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជា ចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយ ពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃ វិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះ ដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយ ជា ស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹង ផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌាតំបន់ផលិតគ្រឿងអេឡិចត្រូនិក និងសារ គមនាគមន៍ ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរ៉េខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និង ឥន្ធនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក លក្ខណៈសម្បត្តិនៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិស ដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថាន ឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ការប្រកួតប្រជែងដោយគុណា

ធិបតេយ្យ និង ជាពិសេសគឺការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះមានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ក្នុងមួយឆ្នាំ មានសៀវភៅជាង២,២លានចំណងជើងត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន ៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន១២០ពាន់ចំណងជើង។ ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃមធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស និស្សិត និងសាធារណៈជនរួមមានការអានសៀវភៅ ការអានលើឧបករណ៍ អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយ  សំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿនទោះបីជា  បច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណាអំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិកនិងការអប់រំពីចម្ងាយដើម្បីលើកកម្ពស់អំណានតាមរយៈការផលិតមាតិកា ឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំ ជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សាឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

1. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា
2. គ្រឹះស្ថានឧត្តមសិក្សាសូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាងដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និង និស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ

3. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាន និងស្រាវជ្រាវជាមួយធនធានអំណាន
4. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យមជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថល ជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សា អាចទទួលបាននិងស្វែងរកប្រភពសម្រាប់អំណាន កាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន
5. និស្សិតគ្រប់កម្រិតសិក្សា ត្រូវខិតខំនិងចំណាយពេលអាន និងចាត់ទុកវប្បធម៌ និងអាកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ
6. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែ ច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា"មូលនិធិ ស.គ.ន" និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមាន ឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.០ ( Digitalization for IR.4.0 ) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម ( Applied Agricultural Research ) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ ( 21st Century Pedagogy Research )។

ដោយមានការធ្វើអាទិភាពវូបនីយកម្មទៅលើទិសដៅនៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្ដល់ការគាំទ្រដល់ការ**រៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា ( Text book ) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា**។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសាជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀតការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

- ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា

- លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់
- បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់ឋានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ
- រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់ នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិរួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋនិងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំ សូមចូលរួមដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូច និងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

# សេចក្តីបញ្ជាក់

នៃមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោង**រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។** សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ និងរូបភាព គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយ ពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# មាតិកា


បុព្វកថា ............ i

សេចក្តីបញ្ជាក់ ............ vi

មាតិកា ............ vii

អារម្ភកថា ............ ix

សេចក្តីថ្លែងអំណរគុណ ............ x

ការបរិយាយលើមុខវិជ្ជា ............ xi

មូលន័យសង្ខេប ............ xii

មេរៀនទី១ អាណាព្យាបាលបារាំងនៅកម្ពុជា(១៨៦៣គ.ស..១៩៥៣គ.ស.) ............ 1

១. និយមន័យៈ អាណាព្យាបាលនិងអាណានិគម ............ 1

២. វត្តមានបារាំងនៅលើទឹកដីកម្ពុជា ............ 1

២.១. ខ្មែរស្ថិតក្រោមគំនាបយួននិងសៀម ............ 3

២.២. អំណាចបារាំងក្នុងទស្សនៈខ្មែរ ............ 4

២.៣. ផលប្រយោជន៍ខ្មែរក្នុងទស្សនៈបារាំង ............ 5

២.៤. ការស្វែងរកកិច្ចការពារពីបារាំង ............ 6

៣. ការស្ថាបនាអាណាព្យាបាលបារាំងពីឆ្នាំ (១៨៦៣គ.ស.-១៨៦៧គ.ស.) ............ 7

៣.១. សន្ធិសញ្ញាអាណាព្យាបាល ១១សីហា ឆ្នាំ ១៨៦៣គ.ស. ............ 8

៣.២. សន្ធិសញ្ញាថ្ងៃ ២៧ មិថុនា ១៨៨៤ ............ 11

៣.៣. សន្ធិសញ្ញាសៀម-ខ្មែរថ្ងៃទី១ធ្នូឆ្នាំ ១៨៦៣ ............ 12

៣.៤. សន្ធិសញ្ញាបារាំង-សៀមថ្ងៃទី០១ ធ្នូ ឆ្នាំ១៨៦៧គ.ស ............ 13

៤. ការវិវត្តរបបអាណាព្យាបាលពីឆ្នាំ១៩០០គ.ស.-១៩៤៥គ.ស ............ 14

៤.១. ស្ថាប័នសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ............ 14

៤.២. សារៈមន្ទីរជាតិនិងការជួសជុលព្រះរាជវាំង ............ 15

៤.៣. ការទទួលបានទឹកដីពីសៀមមកវិញ ............ 15

៤.៤. កិច្ចអភិរក្សអង្គរ ............ 16

៤.៥. កំណែទម្រង់ផ្ទៃក្នុងរបស់បារាំងក្នុងឆ្នាំ១៩១១គ.ស ............ 18

៤.៦. ដំណើរការអភិវឌ្ឍន៍ប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩១១គ.ស. ............ 19

៤.៧. ដំណើរការអភិវឌ្ឍស្ថាប័នរដ្ឋបាលនិងសន្តិសុខឆ្នាំ១៩១១ ............ 21

៥. អាណាព្យាបាលចាស់ និងអាណាព្យាបាលថ្មី ............ 22

៥.១. សៀម និងបារាំងក្នុងបរិបទកម្ពុជា ............ 22

៥.២. យួន និងបារាំងក្នុងបរិបទកម្ពុជា ........ 22
៦. អភិក្រមទំនើបកម្មនិងផលវិបាក ........ 24
៦.១. កំណែទម្រង់ពន្ធដារ ........ 24
៦.២. កំណែទម្រង់រដ្ឋបាល ........ 24
៦.៣. កំណែទម្រង់សង្គមកម្ពុជា ........ 25
៦.៤. កំណែទម្រង់វប្បធ៌ម ........ 28
៦.៥. ចលនាជាតិនិយម ........ 29
៦.៦. គណបក្សនយោបាយ ........ 30
៦.៧. ផលវិបាកនៃអភិក្រមទំនើបកម្ម ........ 32
៧. កម្ពុជានិងសង្គ្រាមលោកលើកទី១ ........ 38
៨. កម្ពុជានិងសង្គ្រាមលោកលើកទី២ ........ 39
៨.១. ឥទ្ធិពលជប៉ុននៅកម្ពុជា ........ 39
៨.២. កម្ពុជានិងឯករាជ្យភាព ........ 40
៨.៣. ការវិលត្រឡប់របស់បារាំង និងកំណែទម្រង់ ........ 43
៩. កម្ពុជានិងឥទ្ធិពលជាតិនិយមថៃ ........ 44
៩.១. បាត់ដំបងក្នុងសម័យសង្គ្រាមលោកលើកទី២ ........ 44
៩.២. ខ្មែរឥស្សរៈនិយមថៃ ........ 44
១០. អំណាចកូសាំងស៊ីនលើកម្ពុជា ........ 48
១០.១. ការតែងតាំងមន្ត្រីជាន់ខ្ពស់ ........ 48
១០.២. ការកំណត់ព្រំដែនរដ្ឋបាល ........ 48
១០.៣. ការកំណត់ដែនពាណិជ្ជកម្ម ........ 49
១១. ចលនាតស៊ូទាមទារឯករាជ្យ ........ 51
១១.១. ខាងក្នុងរដ្ឋាភិបាល ........ 51
១១.២. ខាងក្រៅរដ្ឋាភិបាល ........ 53
១២. ផលវិជ្ជមាននិងអវិជ្ជមាននៃអាណាព្យាបាលបារាំង ........ 54
១២.១. ផលវិជ្ជមាន ........ 54
១២.២.ផលអវិជ្ជមាន ........ 57
សំណួរត្រិះរិះ ........ 58
ឯកសារយោង ........ 59

# អារម្ភកថា

សៀវភៅមួយក្បាលនេះត្រូវបានស្រាវជ្រាវឡើងក្នុង គោលបំណងដើម្បីបង្ហាញពី «សម័យអាណានិគមបារាំងលើប្រទេសកម្ពុជាក្នុងឆ្នាំ១៨៦៣គ.ស.ដល់១៩៥៣គ.ស.» ដើម្បីចែករំលែកដល់សិស្សានុសិស្ស និស្សិត មិត្តអ្នកអានបានដឹងនឹងយល់អ្វីដែលជាមេរៀនសម្រាប់មនុស្សជំនាន់ ក្រោយៗទៀត។ ប្រវត្តិរឿងរ៉ាវរបស់ពួកអាណានិគមនិយមបារាំង ដែលបានត្រួតត្រាលើប្រទេសខ្មែរអស់រយៈពេល៩០ឆ្នាំបានធ្វើបាបរាស្ត្រខ្មែរនិងធ្វើឱ្យបាត់បង់ទឹកដីកូសាំងស៊ីននិងកោះខ្មែរបន្ថែមទៀត និងចង់រំលឹកឡើងវិញអំពើរបស់ពួកអាណានិគមបារាំងដែលចង់បំបាត់អក្សរសាស្ត្រខ្មែរ ឱ្យកូនខ្មែររៀនតែអក្សរឡាតាំងជំនួសវិញនិងបំផ្លាញវត្ថុសិល្បៈទំនៀមទំលាប់ខ្មែររូបចម្លាក់ដែលមានជាយូរមកហើយ។ ខ្ញុំបាទសង្ឃឹមថាសៀវភៅមួយនេះនឹងក្លាយជាឯកសារថ្មីមួយក្នុងចំណោមឯកសារដ៏ទៃទៀត ដែលមិត្តអ្នកអាន ក៏ដូចជាសិស្ស និស្សិតទាំងអស់បានជួបកន្លងមក ។ ឯកសារនេះជាឯកសារថ្មីមួយទៀតដែលបានចងក្រងសម្រាប់ ទុកជាបទពិសោធន៍ក្នុងការរស់នៅកុំឱ្យរស់នៅជាន់ដានប្រវត្តិសាស្ត្រដដែលៗមិនចេះចប់។ដើម្បីកុំឱ្យមានការបាត់បង់ទឹកដីបន្តទៅទៀតយើងទាំងអស់គ្នាត្រូវចេះសាមគ្គីគ្នា ហើយ ចេះថែរក្សាការពារទឹកដីដែលនៅសល់ឱ្យបានគង់វង្សជារៀងរហូតតរៀងទៅ ។

ខ្ញុំបាទសូមខន្តីអភ័យទោសរាល់ចំណុចខ្វះខាតនិងកំហុសឆ្គងមួយចំនួនដោយ អចេតនា។ព្រមទាំងទទួលយកនូវការរិះគន់ និងការកែ តម្រូវពីគ្រប់មជ្ឈដ្ឋានដោយសេចក្តីរីករាយបំផុត។

# សេចក្តីថ្លែងអំណរគុណ

ជាការពិតសៀវភៅ «សម័យអាណានិគមបារាំង១៨៦៣គ.ស.-១៩៥៣គ.ស. » ដែលលេចចេញជារូបរាងនៅពេលនេះគឺបានកើតឡើងពីការចូលរួមប្រឹងប្រែង និងយកចិត្តទុកដាក់ចូលរួមពីភាគី និង ស្ថាប័នពាក់ព័ន្ធជាច្រើន។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់ភាគី និងស្ថាប័នពាក់ព័ន្ធទាំងអស់ដូចជាៈ

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានគាំទ្រយ៉ាងពេញទំហឹងដល់ក្រសួងអប់រំ យុវជន និងកីឡាឱ្យបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ហៅកាត់ថា «មូលនិធិ ស.គ.ន»។

- ក្រសួងអប់រំ យុវជន និងកីឡាដែលបានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា «មូលនិធិ ស.គ.ន» ដើម្បីរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។

- មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលបានគាំទ្រដល់ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសាជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

- ឯកឧត្តនាយកវិទ្យាស្ថានដែលបានចាត់តាំងជាគណៈកម្មការនិពន្ធចូលរួមការរៀបរៀង និពន្ធ និងកែលម្អសៀវភៅនៅកម្រិតឧត្តមសិក្សានេះ។

- នាយកដ្ឋានបណ្តុះបណ្តាលដែលបានចាត់តាំងជាគណៈកម្មការនិពន្ធ និងគណៈកម្មការត្រួតពិនិត្យ លើស្នាដៃនៃការចូលរួមការរៀបរៀង និពន្ធ និងកែលម្អសៀវភៅនៅកម្រិតឧត្តមសិក្សានេះ។

- លោកប្រធាន នាយកដ្ឋានបណ្តុះបណ្តាលដែលព្រមព្រៀងទទួលសិទ្ធិជាតំណាងអ្នករៀបរៀងក្នុងការចាត់ចែង និងសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា ចុះហត្ថលេខាលើកិច្ចព្រមព្រៀង និងកិច្ចដំណើការទូទាត់ថវិកាតាមរយៈការស្នើសុំ និងទទួលថវិកា បោះពុម្ព និងផ្សព្វផ្សាយបន្តនូវស្នាដៃរៀបរៀង និពន្ធ និងកែលម្អរបស់អ្នករៀបរៀងក្នុងការរៀន និងបង្រៀនក្នុងគ្រឹះស្ថានសិក្សា និងប្រគល់សិទ្ធិស្របតាមការកំណត់នៃកិច្ចព្រមព្រៀង ស្តីពីការរៀបរៀង និពន្ធ និងកែលម្អសៀវភៅនៅកម្រិតឧត្តមសិក្សា ក្រោមការគាំទ្រនៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។

- គ្រូឧទ្ទេសមុខវិជ្ជា ប្រវត្តិវិទ្យា នៃវិទ្យាស្ថានគរុកោសល្យបាត់ដំបង ដែលបានផ្តល់មតិកែលម្អលើខ្លឹមសារ នៃមេរៀននីមួយៗឱ្យកាន់តែមានភាពសុក្រឹត និងមានលក្ខណៈវិទ្យាសាស្ត្រ។

ខ្ញុំបាទសង្ឃឹមថា សៀវភៅនេះនឹងឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់សិស្ស និស្សិត នៅកម្រិតវិទ្យាល័យ និងឧត្តមសិក្សា។

# ការបរិយាយលើមុខវិជ្ជា

ប្រវត្តិសាស្ត្រគឺជាវិទ្យាសាស្ត្រដែលសិក្សាពីព្រឹត្តិការណ៍ ឬហេតុការណ៍ដែលបានកើតឡើងតាំងពី អតីតកាល ។ដែលប្រជាជនរស់នៅក្នុងប្រទេសមួយ ត្រូវតែយល់ និងដឹងពីរឿងរ៉ាវ ទាំងនោះ ។ ការសិក្សាពីប្រវត្តិសាស្ត្រប្រទេសរបស់ខ្លួន គឺបានធ្វើឱ្យយើងយល់ដឹងពីដើមកំណើត ការវិវត្តន៍ បម្រែបម្រួលរបស់របបសង្គមនិងការរីកចម្រើនជឿនលឿនក៏ដូចជា ការធ្លាក់ចុះអន់ថយរបស់ ប្រទេសជាតិ ។ ក្រៅពីនេះប្រសិនបើប្រជាជនខ្លួនយើងគ្មានការយកចិត្តទុកដាក់ សិក្សាស្រាវជ្រាវទេ ប្រភពឯកសារដែលជាធនធានបម្រើឱ្យការសិក្សានៅខ្វះខាត។ ដូចនេះហើយការសិក្សាប្រវត្តិដើមកំណើតនេះ ហើយដែលប្រៀបទៅនឹងការស្រលាញ់ ការពារថែរក្សា ហើយចង់ចែករំលែកអរិយធម៌របស់ប្រទេសខ្លួនទៅកាន់ជនបរទេស ទៅកាន់ពិភពលោកទាំងមូលឱ្យបានដឹង ។ ប្រទេសកម្ពុជាយើងគឺជាប្រទេសមួយដែលមានអរិយធម៌ដ៏ខ្ពង់ខ្ពស់ហើយចំណាស់ជាងគេនៅអាស៊ីអាគ្នេយ៍ ដែលបានកើតឡើងនៅពាក់កណ្តាលសតវត្សទី១នៃ គ.ស. មកម្លេះ ។ រហូតមកដល់បច្ចុប្បន្ននេះប្រទេសកម្ពុជានៅតែរក្សាបាននូវមុខមាត់ ឈរក្នុងលំដាប់មួយនៃបណ្តា ប្រទេសក្នុងពិភពលោកបាន ដោយមានការខិតខំប្រឹងប្រែងពីមួយជំនាន់ទៅមួយជំនាន់ក្រោយទៀត ទោះបីជាមានការគំរាមកំហែងពីសត្រូវឈ្លានពានយ៉ាងណាក៏ដោយ ។

ការស្រាវជ្រាវនេះធ្វើឡើងក្នុងគោលបំណង បម្រើដល់អ្នកសិក្សាទាំងអស់ដែលចង់យល់ដឹងពីប្រវត្តិសាស្ត្រខ្មែរជាពិសេសសម័យអាណានិគមបារាំង ហើយដឹងពីបទពិសោធន៍មួយនេះ ដើម្បីទប់ស្កាត់ការកើតឡើងវិញនូវអំពើកេងប្រវ័ញ្ច នឹងរំលោភបំពានលើសិទ្ធិមនុស្សដែលមិនអាច ចាក់ឫសនៅក្នុងប្រទេសយើងសារជាថ្មីម្តងទៀតបានទេ ។ ខ្ញុំបាទសង្ឃឹមថាសៀវភៅ មួយក្បាលនេះធ្វើឱ្យកូនខ្មែរជំនាន់ក្រោយ ឱ្យចាប់អារម្មណ៍អំពីប្រវត្តិសាស្ត្រជាតិខ្មែរយើងឱ្យកាន់តែទូលំទូលាយដោយខិតខំស្វែងរកស្រាវជ្រាវ ចូលរួមចំណែកថែរក្សាការពារទឹក ដីប្រកបដោយទឹកចិត្តស្នេហាជាតិមាតុភូមិ និងការចូលរួមអភិរក្សសម្បត្តិវប្បធម៌ និងសម្បត្តិធម្មជាតិ ក្នុងប្រទេសយើងឱ្យបានគង់វង្សជាដរាប។

# មូលន័យសង្ខេប

ប្រទេសកម្ពុជាស្ថិតនៅក្រោមអាណានិគមបារាំងជិតមួយរយឆ្នាំ ពីឆ្នាំ១៨៦៣គ.ស.ដល់ឆ្នាំ ១៩៥៣គ.ស. ។ នៅឆ្នាំ១៨៦៣គ.ស. ព្រះបាទនរោត្តម ដែល បានឡើងសោយរាជ្យ បានស្វះស្វែងរកការការពារពីបារាំង។ បន្ទាប់ពីមានភាពតានតឹងបានកើតឡើងរវាងសៀម និងយួនមកលើ កម្ពុជា ។ នៅឆ្នាំ ១៨៦៧នៃ គ.ស. ស្តេចសៀមបានចុះហត្ថ លេខាសន្ធិសញ្ញាមួយជាមួយបារាំង ដោយការលះបង់អធិរាជភាពលើកម្ពុជាក្នុងការដោះដូរសម្រាប់ ការគ្រប់គ្រងខេត្តបាត់ដំបង និងសៀមរាប ដែលជាផ្លូវការក្លាយជាប៉ែកនៃប្រទេសសៀម ។ ខេត្តទាំង ប៉ុន្មាននេះត្រូវបានប្រគល់ត្រឡប់មកឱ្យកម្ពុជាវិញដោយសន្ធិសញ្ញាព្រំដែនមួយរវាងបារាំង និងសៀមក្នុង ឆ្នាំ ១៩០៦គ.ស. ។ កម្ពុជាបានបន្តជាអាណាព្យាបាលបារាំងចាប់ពីឆ្នាំ ១៨៦៣គ.ស. ដល់ ១៩៥៣គ.ស. ដែលបានគ្រួត គ្រារដ្ឋបាលនៃអាណានិគមនៃសហភាពឥណ្ឌូចិន ។បន្ទាប់ពីការសោយទីវង្គតរបស់ព្រះបាទ នរោត្តមនៅឆ្នាំ ១៩០៤ គ.ស. បារាំងបានរៀបចំការជ្រើសរើសព្រះមហាក្សត្រ និងព្រះស៊ីសុវត្ថិ ព្រះភាតា របស់ព្រះនរោត្តម ត្រូវបានជំនួសលើរាជបល្ល័ង្ក ។ រាជបល្ល័ង្កបានប្រែជាទំនេរនៅឆ្នាំ ១៩៤១នៃ គ.ស. ជាមួយ ការសោយ ទីវង្គតនៃព្រះបាទមុនីវង្ស រាជបុត្ររបស់ព្រះបាទស៊ីសុវត្ថិ និងបារាំងបានរំលងព្រះរាជបុត្ររបស់ ព្រះស៊ីសុវត្ថិ មុនីវង្ស គឺព្រះស៊ីសុវត្ថិមុនីរ៉េត ដោយដឹងថាទ្រង់មានចិត្តឯករាជ្យពេក ។ ជំនួសមកវិញព្រះនរោត្តម សីហនុ គឺព្រះនត្តាខាងមាតានៃព្រះបាទស៊ីសុវត្ថិត្រូវបានលើកឱ្យឡើងសោយរាជ្យ ។ ពួកបារាំងបានគិតថា ព្រះបាទសីហនុវ័យក្មេងអាចនឹងងាយស្រួលក្នុងការគ្រប់គ្រង ។ ពួកគេបានយល់ខុសហើយយ៉ាងណាមិញ នៅក្រោមរជ្ជកាលនៃព្រះបាទនរោត្តម-សីហនុ ក្រោយពីការកាន់កាប់របស់ជប៉ុន ក្នុង រយៈកាល សង្គ្រាម ឆ្នាំ ១៩៤១នៃ គ.ស.ដល់ ១៩៤៥គ.ស. កម្ពុជាបានទទួលបានឯករាជ្យពីបារាំងនៅថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ១៩៥៣នៃ គ.ស. ហើយប្រកាន់របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញដឹកនាំដោយព្រះបាទនរោត្តមសីហនុ ។ ការស្ថាបនាគ្រឹះខាងវិស័យសន្តិសុខ និង សណ្តាប់ធ្នាប់សង្គម។ មានតាំងពីពន្ធមនុស្សពន្ធដីពន្ធលំនៅ ពន្ធសត្វពាហនៈ ពន្ធយានជំនិះ ពន្ធលើអាជីវកម្មជាដើម។ដើម្បីបង់ពន្ធឱ្យបារាំងកសិករខ្មែរបានខិតខំពង្រីកដំណាំឧស្សាហកម្ម មានកៅស៊ូជាដើមព្រមទាំងពង្រីកដំណាំដទៃទៀតមានស្រូវ ពោត សណ្តែក។ ដូចនេះហើយកសិករក្រីក្រ ក៏ក្លាយទៅជាអ្នកជាប់បំណុលពួកឈ្មួញកណ្តាល និងឈ្មួញបរទេស។ ចំណែកឯការចងការប្រាក់វិញមានកម្រិតខ្ពស់ណាស់ ហើយ ការប្រាក់នេះបានក្លាយជាបន្ទុកដ៏ធំសម្រាប់ប្រជាជនកម្ពុជា។ដោយមានការជំរិតទារពន្ធដារយ៉ាងធ្ងន់ធ្ងរ ពីពួកអាណានិគមបារាំងនេះហើយ បានជាធ្វើឱ្យ ចលនាបះបោរសំណាក់ប្រជារាស្ត្រ សិស្ស និស្សិត បញ្ញវន្តខ្មែរ បានងើបឡើងតវ៉ាប្រឆាំងនឹងពួកអាណានិគមបារាំង រហូតទទួលបានឯករាជ្យនៅថ្ងៃទី៩វិច្ឆិកា ១៩៥៣គ.ស.។

# មេរៀនទី១

# អាណាព្យាបាលបារាំងនៅកម្ពុជា( ១៨៦៣គ.ស..១៩៥៣គ.ស. )

## ១. និយមន័យ៖ អាណាព្យាបាលនិងអាណានិគម

អាណាព្យាបាលគឺ អ្នកគ្រប់គ្រងមើលថែរក្សាការពារមិនឱ្យបាត់បង់ឱ្យនៅគង់វង្សរហូត មិនមែនអ្នកណាអាចមកប៉ះពាល់បានឡើយ។

អាណានិគមនិយមគឺ លទ្ធិឬ ជនខ្លះដែលចូលចិត្តតែខាងជ្រៀតជ្រែកវាយដណ្តើមយកប្រទេសដទៃធ្វើជាស្រុកចំណុះរបស់ខ្លួន។[1] រដ្ឋដែលតាំងក្នុងអំណាចគ្រប់គ្រងលើប្រទេសមួយដោយពុំឱ្យប្រទេសនោះមានសិទ្ធសេរីភាពទាំងអ្នកដឹកនាំទាំងប្រជាជន និងគាបសង្កត់ទាញយកផលប្រយោជន៍ពីប្រទេសនោះដោយគ្មានការអនុគ្រោះឡើយ។

## ២. វត្តមានបារាំងនៅលើទឹកដីកម្ពុជា



( ព្រះបាទនរោត្តម GoogleSearch )

ចាប់តាំងពីក្រោយសម័យអង្គរ អាណាចក្រខ្មែរ ដែលធ្លាប់តែជាមហាអំណាចដ៏ធំមួយ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ បានធ្លាក់ចុះទន់ខ្សោយឥតឈប់ហើយដែនដីក៏ចេះតែរួញតូចទៅៗ ដោយសារតែការលេបត្របាក់ពីប្រទេសជិតខាង គឺសៀម និងយួន។ មិនតែប៉ុណ្ណោះ ទឹកដីដែលនៅសេសសល់របស់នគរខ្មែរ ក៏មិនមានឯករាជ្យពេញលេញនោះដែរ ដោយត្រូវសៀម និងអាណ្ណាមបានផ្លាស់ប្តូរគ្នាគ្រប់គ្រងជានគរចំណុះម្តងម្នាក់ៗ ស្ទើរតែជាប់ជាប្រចាំ។ នៅពេលដែលព្រះបាទអង្គដួងឡើងគ្រងរាជ្យភ្លាម ព្រះអង្គមើលឃើញស្ថានភាពប្រទេសខ្មែរយើងត្រូវពួកសៀម និងយួន លេបត្របាក់ស្ទើរតែជិតអស់ហើយ ព្រមទាំងមានបំណងពុះចែកប្រទេសខ្មែរយើងជាពីរចំណែ ត្រើយខាងកើតគឺសម្រាប់ពួកយួន និងត្រើយខាងលិចសម្រាប់ពួកសៀម ដែលពួកគេបានយកដងទន្លេមេគង្គធ្វើជាព្រំប្រទល់របស់ពួកគេ។ ហេតុដូចនេះហើយទើបព្រះអង្គមានការសោកស្តាយយ៉ាងខ្លាំង នូវការបាត់បង់ទឹកដីរបស់ខ្មែរទៅសៀមនិងយួន។ពេលនោះព្រះអង្គបានត្រាស់បង្គាប់ឱ្យរៀបចំសង់បន្ទាយកងទ័ពជើងគោក យ៉ាងធំដែលមានមូលដ្ឋានទ័ពនៅ ខេត្តមាត់ជ្រូក( ចូវដុក )និងពាមឬមួងខាំ( ហាទៀង ) ដែលជាបន្ទាយជួរមុខនៃកងទ័ពខ្មែរ។ដោយសព្វព្រះ ទ័យម្យ៉ាងនឹងជោគជ័យដំបូង របស់ព្រះអង្គនិងដោយឃើញបរាជ័យជាបន្តបន្ទាប់គ្នារបស់យួនអាណ្ណាម ដើម្បីវាយយកខេត្តរបស់ខ្មែរដែលបានបាត់ពីមុនយកមកវិញ តែពេលវេលាមិនអនុគ្រោះឱ្យព្រះអង្គឡើយគឺព្រះអង្គបានធ្លាក់នូវព្រះកាយប្រឈួនយ៉ាងធ្ងន់ ដែលធ្វើឱ្យគម្រោងការវាយយកដែនដីកម្ពុជាក្រោមមកវិញត្រូវអាក់ ខាន។ក៏ប៉ុន្តែ នៅពេលនោះ នគរខ្មែរនៅតែស្ថិតក្រោមការត្រួតត្រាពីសំណាក់ស្តេចសៀម និងអាណ្ណាម ហើយសូម្បីតែការធ្វើរាជាភិសេករបស់ព្រះបាទអង្គដួងនៅឆ្នាំ១៨៤៧គ.ស.ក៏ត្រូវបានធ្វើឡើងនៅចំពោះមុខតំណាងស្តេចនៃនគរជិតខាងទាំងពីរនេះដែរ។ ដែនដីកូសាំងស៊ីន ដែលត្រូវបាននគរអាណ្ណាមដណ្តើមកាន់កាប់កាលពីមុន នៅតែបន្តស្ថិតក្រោមការកាន់កាប់របស់អាណ្ណាមដដែល ហើយខេត្តទាំង ២១

---

[1] -វចនានុក្រមសម្តេចសង្ឃ ជួនណាត

នៃដែនដីកូសាំងស៊ីននេះត្រូវបានប្ដូរឈ្មោះទៅជាភាសាវៀតណាមរហូតមកទល់នឹងសព្វថ្ងៃ។ ចំណែកនៅប៉ែកខាងលិចវិញមានជាង៣១ខេត្តត្រូវសៀមលេបត្របាក់យកនិងទន្ទ្រានយកពេលថ្មីៗថែមទៀត រួមមានខេត្ត បាត់ដំបង សៀមរាប មង្គលបុរី ស៊ីសុផុន ដែលត្រូវសៀមដណ្ដើមយកទៅកាន់កាប់ពីមុនមកនោះ ក៏បន្តស្ថិតក្រោមការកាន់កាប់របស់សៀមជាបន្តទៀត។ លើសពីនេះទៅទៀត សៀមបានបង្ខំឱ្យព្រះបាទអង្គឌួងចុះកិច្ចព្រមព្រៀងទទួលស្គាល់ការកាត់ខេត្តពីរទៀតឱ្យទៅសៀម គឺខេត្តម្លូព្រៃ និងទន្លេពៅ។ ក្រោយពីបានឡើងគ្រងរាជ្យ ព្រះបាទអង្គឌួងទ្រង់យល់ច្បាស់ក្នុងចិត្តថា ទាំងនគរសៀម និងនគរអាណ្ណាមសុទ្ធតែនាំគ្នាបន្តចិញ្ចឹមចិត្តចង់លេបត្របាក់យកនគរខ្មែរ ហើយដោយបារម្ភថា នៅក្រោយពេលព្រះអង្គសោយទិវង្គតទៅ នគរខ្មែរអាចនឹងត្រូវសៀម និងអាណ្ណាមពុះចែកគ្នាជាពុំខាន ទើបព្រះអង្គក៏មានព្រះរាជតម្រិះចង់ស្វះស្វែងរកកិច្ចការពារពីចក្រភពបារាំង។ ចក្រភពបារាំង ដែលក្រោយពីចាញ់សង្គ្រាមទល់នឹងអង់គ្លេស នៅឥណ្ឌា បានចាប់ផ្ដើមងាកមកផ្ដោតលើការពង្រីកដែនអាណានិគម នៅក្នុងតំបន់ឥណ្ឌូចិន។

នៅឆ្នាំ១៨៥៣គ.ស. ព្រះបាទអង្គឌួង បានផ្ញើរាជសារមួយច្បាប់ ដោយមានភ្ជាប់ជាមួយនឹងអំណោយយ៉ាងច្រើនផង ទៅកាន់អធិរាជណាប៉ូឡេអុង ទី៣ (ត្រូវជាក្មួយរបស់ណាប៉ូឡេអុង បូណាប៉ាត) ដើម្បីស្នើសុំចងភ្ជាប់សម្ព័ន្ធមិត្តជាមួយចក្រភពបារាំង។ ប្រវត្តិសាស្ត្រចង្អុលបង្ហាញថា ប្រទេសកម្ពុជាឥត ដែលយល់ព្រមបោះបង់ចោលកម្មសិទ្ធិលើដីនោះ ( កម្ពុជាក្រោម) ដែលលោកម៉ូរ៉ា ព្រមទាំងអ្នកនិពន្ធប្រវត្តិវិទូធំៗទទួលស្គាល់ជាឯកច្ឆ័ន្ទ ថាជាទឹកដីរបស់ខ្មែរ ។ លើសពីនេះទៀត នៅមុនពេលបារាំងចូលត្រួតត្រាដីនោះ វាពុំមានព្រំដែនខណ្ឌប្រទេសកម្ពុជាដូចពេលបច្ចុប្បន្ន និងកូសាំងស៊ីនបច្ចុប្បន្ន កម្ពុជាក្រោម)នោះទេ ។ ហេតុនេះសបញ្ជាក់ឱ្យឃើញថា មកទល់នឹងបារាំងចូលមកត្រួតត្រា យួនមិនអាចយកដីខ្មែរផ្នែកនេះធ្វើជាដី ខ្លួនបាន ឡើយ នឹងធ្វើខ្លួនឱ្យទៅជាម្ចាស់ផុតសិទ្ធិតវ៉ារបស់ខ្មែរបានឡើយ ។ព្រែកជីកវិញតេ ដែលបារាំងយកធ្វើជាព្រំដែននោះ គឺត្រូវជីកឡើងដោយពួកយួននិងខ្មែរ សម្រាប់សេចក្ដីត្រូវការរួមនៅសម័យនោះ សោតឯថៅហ្វាយខែត្រយួន ដែលត្រួតត្រាការដ្ឋាននោះ បានទទួលស្គាល់ខ្លួនឯងថា គាត់ទទួលជាវអាជ្ញាសឹកមួយនិងព្រះសង្ខារ (ត្រា ដើម្បីជាសក្ខីភាពនៃអំណាចយោធា និងស៊ីវិលនៅប្រទេសកម្ពុជា ដើម្បីធ្វើការស្ថាបនាព្រែកជីកនេះ គឺរឿងព្រែកជីកវិញតេនេះហើយ ដែលនាំឱ្យខ្មែរបំភ្លេចមិនបានពីអនុស្សាវរីយ៍កំពប់តែអុង តាមលោកម៉ូរ៉ាថាថៅហ្វាយខែត្រយួនត្រួតត្រាស្រុកខ្មែរនៅឆ្នាំ១៨១៣ គ.ស.នោះ គ្មាននរណាក្រៅពីរូបអាណាព្យាបាលប្រទេសកម្ពុជា ដែលស្ដេចយួនអណ្ណាមចាត់ជាតំណាងមកត្រួតខ្មែរនោះឡើយ ។

ដូច្នេះទោះនៅក្នុងសម័យណាក៏ដោយកូសាំងស៊ីនឬកម្ពុជាក្រោម នៅតែជាដីរបស់ខ្មែរជានិច្ច ។ យើងពុំដែលបញ្ឈប់ការប្រយុទ្ធ ដើម្បីដណ្ដើមដីនេះម្ដងណានោះទេ លុះត្រាតែបារាំងចូលមកធ្វើថៅហ្វាយរួមរបស់យួន និងខ្មែរ ហើយរួចធ្វើជាដីចំណុះ ទើបការនោះត្រូវយកដីនោះធ្វើជាដីកម្មសិទ្ធខ្លួនដោយខ្លួនឯងហើយព្យួរការទាមទារសិន ។បើទោះជានៅក្នុងការកាន់កាប់នោះ បញ្ហា "កូសាំងស៊ីន" ហាក់ដូចជា បានដោះស្រាយជ្រះស្រឡះ ហើយរវាងប្រទេសបារាំង និងប្រទេសកម្ពុជា ហើយដូចគ្នានេះដែរ រវាងប្រទេសកម្ពុជា និងយួនអណ្ណាម ក៏យើងបានទាមទារសិទ្ធជា ម្ចាស់ដីជាច្រើនលើកច្រើនសាដោយកម្លាំងអាវុធ បន្ទាប់មកដោយកិច្ចចរចា ខកចិត្តជាមួយប្រទេសបារាំង ។ នៅពេលថ្មីៗនេះ គឺក្រោយពីសៀមដណ្ដើមយកខេត្តបាត់ដំបង និង

សៀមរាបក្នុងឆ្នាំ១៩៤១គ.ស. គណៈរដ្ឋមន្ត្រីខ្មែរបានទៅស្រុកបារាំង ដើម្បីទាមទារដី កូសាំង ស៊ីន ប៉ុន្តែ ត្រូវខកចិត្តទៀតដោយសារតំណាងប្រទេសបារាំងនៅប្រទេសកម្ពុជារារាំង ។[2]

## ២.១. ខ្មែរស្ថិតក្រោមគំនាបយួននិងសៀម

នៅមុនពេលដែលបារាំងមកដល់កម្ពុជា ប្រទេសខ្មែរបានស្ថិតនៅក្នុងភាពទន់ខ្សោយ ជាទីបំផុត។ ចម្បាំងផ្ទៃក្នុងដណ្ដើមរាជបល្ល័ង្គ និងការវាតទីនិយមរបស់សៀម និងយួន បានធ្វើឱ្យប្រទេស ខ្មែរបាត់បង់នូវអធិតេយ្យភាព និងបូរណភាពទឹកដីរបស់ខ្លួននៅឆ្នាំ១៨០៦គ.ស. ជាសក្ខីភាពស្រាប់ ពីព្រោះ ព្រះបាទអង្គច័ន្ទ(ព្រឹត្តការណ៍ ១៧៩៦គ.ស.-១៨៣៤គ.ស.) ត្រូវបានបំពេញពិធីអភិសេកនៅទីក្រុងបាងកក រៀបចំឡើងដោយព្រះ រាជាសៀម ហើយនៅពេលដែលយាងមកដល់រាជធានីភ្លាម មហាក្សត្រខ្មែរអង្គនេះ ក៏បានផ្ញើរក្លកដំរី ក្រមួន ក្រវាញ និងភ្លុកជាសួយសារអាករថ្វាយស្ដេចអាណ្ណាម។ការដណ្ដើមរាជបល្ល័ង្គបានធ្វើឱ្យស្ដេចខ្មែរម្ដងរត់ទៅពឹងទ័ពសៀមម្ដងរត់ទៅពឹងទ័ពយួន ដើម្បីដោះស្រាយវិបត្តិផ្ទៃក្នុងក្នុងប្រទេស ដែលបង្ហាញឱ្យឃើញថា ខ្មែរសម័យនោះបាត់បង់ឯករាជ្យភាពរបស់ខ្លួន។ ព្រះបាទអង្គឌួង ជាព្រះបិតាព្រះបាទនរោត្តម(១៨៦០គ.ស.-១៩០៤គ.ស.) ដែលឡើងសោយរាជ្យ នៅចុងឆ្នាំ១៨៤៧គ.ស. ត្រូវអភិសេកធ្វើឡើងដោយមានអាណាព្យាបាល តំណាងចក្រភព អាណ្ណាម និងសៀមចូលរួម។ ប្រទេសទាំងពីរនេះបានគ្រប់គ្រង និងកាន់កាប់ព្រះរាជាណាចក្រកម្ពុជាទាំងមូល ហើយនៅតាមអាណាខេត្តនានា ចៅហ្វាយខេត្តជាច្រើនស្ថិតក្នុងភាពភ័យខ្លាច ដោយគ្មានជំនួយពីរដ្ឋាភិបាលភ្នំពេញនាជំនាន់នោះបានលះបង់ខេត្តជាច្រើននៅភាគខាងជើង និងខាងត្បូងដោយកងទ័ពយួនជាច្រើន។

នៅអំឡុងសតវត្សរ៍ទី១៩ នគរអាណ្ណាម ដែលបានកាត់យកទឹកដីកូសាំងស៊ីន ឬកម្ពុជាក្រោម ពីនគរខ្មែររួចទៅហើយ ដោយថែមទាំងបានត្រួតត្រាស្ដេចខ្មែរជានគរចំណុះថែមទៀត ប៉ុន្តែនៅមិនអស់ចិត្ត ក៏មានគម្រោងចង់កាត់យកនគរខ្មែរទាំងមូលយកទៅធ្វើជាទឹកដីខ្លួនទៀតផង។ នៅឆ្នាំ១៨៣៤គ.ស. អាណ្ណាមបានលើកបន្តុបក្សត្រិយមួយអង្គព្រះនាម អង្គម៉ី ដែលត្រូវជាបុត្រីរបស់ព្រះបាទអង្គចន្ទ ឱ្យឡើងមកគ្រងរាជ្យជាមហាក្សត្រខ្មែរ រួចហើយបានចាត់វិធានការគ្រប់យ៉ាង ដើម្បីព្យាយាមបំបាត់ប្រពៃណី ទំនៀមទម្លាប់ សាសនា និងរបៀបរបបគ្រប់គ្រងរដ្ឋបាលពីបុរាណរបស់នគរខ្មែរ។ ខេត្តរបស់ខ្មែរ ពេលនោះមានរហូតដល់ ៥៦ខេត្ត ត្រូវបានកាត់បន្ថយមកនៅត្រឹម ៣៣ខេត្ត ហើយត្រូវប្ដូរឈ្មោះហៅតាមភាសាវៀតណាមវិញ ហើយគ្រប់ចៅហ្វាយខេត្តទាំងអស់នោះ ត្រូវមានជំនាញការយួន១នាក់មកត្រួតត្រាពីលើខ្មែរ ដោយខ្មែរពុំមានសិទ្ធិក្នុងការសម្រេចចិត្តកិច្ចការប្រទេសជាតិឡើយ។ ដោយទ្រាំមិនបាននឹងទង្វើនេះ ប្រជារាស្ត្រខ្មែរក៏បាននាំគ្នាងើបឡើងបះបោរ ធ្វើការវាយឆ្មក់ កាប់សម្លាប់ទាហាន និងប្រជាជនអាណ្ណាម ដោយឥតរើសមុខ។ក្នុងពេលវេលាដែលមានភាពចលាចលនោះ មន្ត្រីខ្មែរក៏បានឯកភាពគ្នា ទៅសុំអន្តរាគមន៍ពីស្ដេចសៀមឱ្យមកជួយវាយបណ្ដេញពួកអាណ្ណាម និងលើកអ្នកអង្គម្ចាស់ អង្គឌួង ដែលមានការស្រឡាញ់ចូលចិត្តពីប្រជារាស្ត្រខ្មែរ ឱ្យឡើងសោយរាជ្យ ជំនួសក្សត្រីអង្គម៉ី។ ក្រោយពីបានធ្វើសង្គ្រាមនឹងគ្នាអស់រយៈពេលជាច្រើនឆ្នាំ។ នៅឆ្នាំ១៨៤៥

[2] -សាំង ម៉ាក់សាង កូសាំងស៊ីនជាដីរបស់ខ្មែរឆ្នាំ១៩៧៣ទំព័រ៥៧

គ.ស. នគរខ្មែរ សៀម និងអាណ្ណាមបានចរចាគ្នាបញ្ចប់សង្គ្រាម ហើយទាំងសៀម និងទាំងអាណ្ណាមសុទ្ធតែបានទទួលយល់ព្រមឱ្យព្រះបាទអង្គឌួង ឱ្យឡើងគ្រងរាជ្យជាព្រះមហាក្សត្រខ្មែរ។

## ២.២. អំណាចបារាំងក្នុងទស្សនៈខ្មែរ

ក្រោយពីបារាំងបានដាក់ជាអាណាព្យាបាលលើកម្ពុជា មកពួកគេបានធ្វើអ្វីស្រេចតែនឹងចិត្ត ដូចជាការទារពន្ធដារ ការធ្វើកំណែន ។ទោះបីជាសន្ធិសញ្ញាថ្ងៃទី ១១ សីហា ១៨៦៣គ.ស. ស្ថិតក្នុងការផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមកក៏ដោយក៏អ្នកស្នេហាជាតិខ្មែរ បានក្រោកឈរកាន់អាវុធប្រឆាំង នឹងការប៉ុនប៉ងរបស់បារាំងក្នុងការត្រួតត្រាប្រទេសខ្មែរដែរ។បន្ថែមលើសន្ធិសញ្ញាថ្ងៃទី១៧ មិថុនា ១៨៨៤គ.ស. រឹតតែបង្ករភាពក្តៅក្រហាយទ្វេរឡើងគ្រប់ស្រទាប់ប្រជាជនខ្មែរដែលនាំឱ្យកើតមានចលនាតស៊ូជាហូរហែ។ដូចជានៅក្នុងរាជ ព្រះបាទស៊ីសុវត្ថិ ( ១៩០៤គ.ស. ដល់១៩២៧គ.ស.) ។នៅថ្ងៃទី២៤ មេសា ដដែលនោះ វេលាម៉ោង ៣ និង២០នាទីល្ងាច ក្រុមប្រឹក្សារាជបល្លង្គ ដែលមានគណៈរដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់ទាំងបព្វជិត និងទាំងគ្រហស្ថបានបើកសម័យប្រជុំក្រោមអធិបតីភាពនៃលោករេស៊ីដង់ស៊ុប៉េរីយ៍រ ដើម្បីជ្រើសរើសព្រះមហាក្សត្រថ្មីទៅតាមប្រពៃណីខ្មែរ ។ ដោយហេតុថាព្រះបាទនរោត្តម ពុំសូវស្និទ្ធស្នាលនឹងបារាំង ព្រះរាជបុត្ររបស់ព្រះអង្គពុំត្រូវបានជ្រើសរើសឱ្យឡើងសោយរាជ្យស្នងពីព្រះបិតាទេ ។ ពេលនោះ ក្រុមប្រឹក្សារាជបល្ល័ង្គ ដែលមានរេស៊ីដង់ស៊ុបើរីយ៍រ ជាអធិបតីនោះ បានសំរេចជ្រើសរើសព្រះមហាឧបរាជស៊ីសុវត្ថិ ជាព្រះអនុជព្រះបាទនរោត្តម ឱ្យឡើងសោយរាជ្យវិញ ។បើតាមលោក Paul Collard ( ពូលខូលឡាដ )ព្រះបាទស៊ីសុវត្ថិ ជាបុគ្គលដែលគួរឱ្យស្រឡាញ់ជាទីបំផុត ជាមនុស្សដែលមានចិត្តទូលាយ និងចិត្តមេត្តាជាទីបំផុតក្នុងចំណោមខ្មែរទាំងឡាយ ។ ព្រះអង្គទ្រង់បានខិតខំទាំងកម្លាំងព្រះទ័យ និងទាំងកម្លាំងព្រះកាយ ដើម្បីធ្វើឱ្យមានសន្តិភាព និងធ្វើឱ្យប្រជារាស្ត្របានសម្បូណ៌សប្បាយ ។លុះបានឡើងសោយរាជ្យភ្លាម ព្រះអង្គទ្រង់បានប្រកាសឱ្យប្រើនូវព្រះរាជបញ្ញត្តិនៅថ្ងៃទី ២១ ខែឧសភា ១៩០៤នៃ គ.ស. ដែលបញ្ជាឱ្យលប់ចោលនូវការធ្វើទុក្ខបុកម្នេញលើរាងកាយ ចំពោះជនមានទោស និងលើជនដែលត្រូវជាប់ចោទ។ក្នុង  វិស័យសេដ្ឋកិច្ច គេបានដឹងថាក្នុងរជ្ជកាលរបស់ព្រះបាទស៊ីសុវត្ថិ ចំការកៅស៊ូត្រូវបានបង្កើតជាលើកដំបូងនៅត្រង់តំបន់ ៩៥( ១៩២១.គ.ស. ) ។ ដោយការសាកល្បងនេះបានជោគជ័យ ពួកមូលធននិយមបារាំងបានបង្កើតចំការកៅស៊ូធំៗផ្សេងទៀតនៅត្រង់តំបន់ដីក្រហមក្នុងខេត្តកំពង់ចាមនិងក្រចេះ។ ដប់ឆ្នាំក្រោយមកគឺនៅឆ្នាំ១៩៣១គ.ស. ទំហំផ្ទៃដីដាំកៅស៊ូកើនឡើងពី ២៥០០០ ហិចតា ។




នៅទីបញ្ចប់នេះ គួរកត់សំគាល់ថាក្នុងរជ្ជកាលរបស់ព្រះបាទ ស៊ីសុវត្ថិ រាស្ត្រខ្មែរបានក្រោកឡើងប្រឆាំងនឹងការរំលោភជិះជាន់របស់បារាំងអស់បីលើក ។ យ៉ាងណាមិញ នៅឆ្នាំ១៩១៦.គ.ស. ដើម្បីជាការដឹងគុណចំពោះរដ្ឋការបារាំងព្រះបាទស៊ីសុវត្ថិ ទ្រង់បានអនុញ្ញាតឱ្យពួកនេះកែនរាស្ត្រខ្មែរធ្វើទាហានយកទៅច្បាំងនៅប្រទេសបារាំង ក្នុងសង្គ្រាមសកលលោកលើកទី១( ១៩១៤-១៩១៨ គ.ស. ) ។ ប៉ុន្តែមិនយូរប៉ុន្មាន

រាស្ត្រខ្មែរចំនួន១សែននាក់បានបះបោរឡើងប្រឆាំងនឹងការរំលោភក្នុងកំណែនខាងលើនេះ និងក្នុងការស្ដាបនាផ្លូវថ្នល់ ។ ជាកុសល ព្រះរាជាទ្រង់បានធ្វើអន្តរាគមន៍ដោយប្រជារាស្ត្ររបស់ព្រះអង្គក៏សុខចិត្តព្រមវិលទៅលំនៅដ្ឋានរៀងៗ ខ្លួនវិញទៅ ។ក្រោយមក ប្រហែលជាដោយសារបារាំងត្រូវការលុយកាក់នាំយកទៅស្រុករបស់ខ្លួន ដែលបានងើបពីចម្បាំងជាមួយពួកអាល្លឺម៉ង់ បារាំងក៏បានតម្លើងពន្ធដា ហើយទារពន្ធពីរាស្ត្រខ្មែរដែលមានជីវភាពកាន់តែយ៉ាប់យ៉ឺនទៅៗ។ម្ល៉ោះហើយ រាស្ត្រខ្មែរដែលនៅកន្លែងខ្លះអត់ទ្រាំនឹងអំពើជិះជាន់នេះមិនបានក៏នាំគ្នាងើបឡើងតស៊ូរហូតដល់ហ៊ានសម្លាប់រេស៊ីដង់បារាំង ដូចករណីលោករេស៊ីដង់ Bardez (បាដេស)នៅឃុំក្រាំងលាវខេត្តកំពង់ឆ្នាំងនៅថ្ងៃទី១៨ខែមេសា ១៩២៥ គ.ស.។[3]

## ២.៣. ផលប្រយោជន៍ខ្មែរក្នុងទស្សនៈបារាំង

- ពង្រឹងអំណាចបារាំង-ខ្មែរទៅកាន់តំបន់ដាច់ស្រយាល តំបន់ឆ្នេរសមុទ្រចាប់ពីក្រោយឆ្នាំ១៩០៤ គ.ស.។នៅឆ្នាំ១៩០៤-១៩០៦គ.ស. តំបន់ឆ្នេរសមុទ្ររបស់កម្ពុជាមានខេត្តពីរ ដែលគ្រប់គ្រងដោយចៅហ្វាយខេត្តបារាំង គឺខេត្តកំពត និង ខេត្តកោះកុង-ក្រាត។

- នៅឆ្នាំ១៩៣៣-១៩៣៤គ.ស. មានព្រះសង្ឃពីរអង្គគឺវត្តអង្គសុភី ស្រុកកំពង់ត្រាច ខេត្តកំពត ដែលបានស្ម័គ្រចិត្តនិមន្តទៅខេត្តកោះកុង ដើម្បីបង្កើតវត្ត និងបង្រៀនភាសាខ្មែរនៅទីនោះ។

- នៅភូមិភាគឥសាន ចាប់ពីចុងទសវត្សរ៏១៩២០-១៩២៩គ.ស.មានការចាប់ផ្ដើមធ្វើផ្លូវលំពីស្នួលចូលទៅក្នុងភូមិភាគឥសានឡើងវិញ ដែលហៅថាការចូលទៅកាន់តំបន់ឆ្លងលើ គឺខេត្តមណ្ឌលគិរីសព្វថ្ងៃ។ នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៣១គ.ស. មន្ត្រីនៃដែនប្រតិភូស្នួល ឈ្មោះហ្គាទីយ ដែលទទួលភារកិច្ចធ្វើផ្លូវទៅកាន់ឆ្លងលើ ត្រូវបានសម្លាប់ដោយពួកព្នង។

-នៅឆ្នាំ១៩៩៣គ.ស. មន្ត្រីនៃពុទ្ធសាសនាបណ្ឌិត លោកស្រី ស៊ូហ្សាន ការប៉េល និង ព្រះភិក្ខុ ហួត តាត ដែលជាសាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់បានទៅកាន់តំបន់ឆ្លងលើ នៅពេលដែលតំបន់នោះមិនទាន់មានសន្តិភាពទាំងស្រុងនោះឡើយ (ដោយសារការប្រឆាំងពីជនជាតិភាគតិច) ដើម្បីរៀបចំកម្មវិធីបង្រៀនភាសាខ្មែរ ដល់ជនជាតិភាគតិចនៅទីនោះ ដោយចាប់ផ្ដើមពីប៉ុស្សឡឺ រ៉ូឡង់។

-នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៣៤គ.ស. ព្រះសង្ឃ៨អង្គបាននិមន្តពីភ្នំពេញ ទៅកាន់ប៉ុស្តឡឺ រ៉ូឡង់ ដើម្បីរៀបចំសម្ពោធវត្តមួយនៅទៅនោះ និងចាប់ផ្ដើមបង្រៀនភាសាខ្មែរ។ទន្ទឹមនឹងការពង្រឹងអំណាចរបស់បារាំង ចលនាជាតិនិយមខ្មែរក៏បានលេចរូបរាងផងដែរពីដើមទសវត្សរ៍ ឆ្នាំ១៩៣០គ.ស. តាមរយៈពុទ្ធសាសនបណ្ឌិត វិទ្យាល័យស៊ីសុវត្ថិ (សមាគមអតីតសិស្សអនុវិទ្យាល័យ) ។ ឪពុកម្ដាយត្រូវតែបញ្ជូនកូនប្រុសស្រីឱ្យទៅកាន់សាលារៀន បើពុំដូច្នោះទេនឹងត្រូវទទួលទណ្ឌកម្មយ៉ាងទម្ងន់។ សូមប្រាប់ថានៅសម័យនោះក្រៅពីសាលាវត្តរាជការបានបង្កើតសាលានៅតាមឃុំជាច្រើនទៀតដើម្បីឱ្យក្មេងសិក្សាភាសាជាតិខ្លួន។ ចំពោះក្មេងណាដែលចង់បន្តការសិក្សាថែមទៀត រដ្ឋការអាណាព្យាបាលបារាំង បានបង្កើតសាលាបឋមសិក្សាជាន់ដំបូងខ្លះដែលនៅទីនោះ គេបានផ្ដើមការបង្រៀនភាសាបារាំង ។ សាលាទាំងនោះនៅមានសាលាដែលមានកំរិតវិជ្ជាខ្ពស់ជាងនៅតាមទីរួមខេត្ត ហើយដែលមានចាងហ្វាងជាបារាំង។ សម្រាប់មធ្យមសិក្សា គេ

[3] -ត្រឹងងា ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ១៩៧៣ ទំព័រ២៦៩

មានអនុវិទ្យាល័យស៊ីសុវត្ថិមួយគត់នៅរាជធានីភ្នំពេញ ដែលត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩០៤គ.ស. មកម្ល៉េះ ។ក្នុងវិស័យសិក្សាអប់រំ និងវប្បធម៌ គេបានដឹងថាតាមរាជបញ្ញត្តិថ្ងៃទី៤ ខែកញ្ញា ១៩១៥គ.ស. ព្រះបាទស៊ីសុវត្ថិ ទ្រង់បានបង្កើតគណៈកម្មការមួយដែលមាននាទីរៀបចំវចនានុក្រមខ្មែរជាលើកដំបូង រួចនៅឆ្នាំ ១៩២១គ.ស. ព្រះអង្គទ្រង់បានកសាងសាលាបាលីជាន់ខ្ពស់ និងព្រះរាជបណ្ណាល័យ ។ ម្យ៉ាងទៀត នៅក្នុងរជ្ជកាលរបស់ព្រះអង្គដដែល (១៩១៨គ.ស.) លោក Georges Groslier(ចច គ្រូស្លី) បានបង្កើតសារមន្ទីរមួយនៅក្រុងភ្នំពេញ ដើម្បីប្រមែប្រមូលនូវស្នាដៃខ្មែរដែលជាវត្ថុបុរាណយកមកថែរក្សាឱ្យបានគង់វង្សតទៅ ។គួរកត់សំគាល់ដែរថា ចាប់តាំងពីឆ្នាំ ១៩១២គ.ស. ព្រះរាជាទ្រង់បានប្រកាសឱ្យប្រើនូវក្រមព្រហ្មទណ្ឌថ្មី។ នៅឆ្នាំបន្ទាប់ ក្រុមស៊ើបអង្កេតបទឧក្រិដ្ឋ និងនៅឆ្នាំ១៩២០គ.ស. ក្រុមរដ្ឋប្បវេណី និងក្រមនីតិវិធីខាងបទបវេណី ក៏ត្រូវបានប្រកាសឱ្យប្រើជាបន្តបន្ទាប់គ្នា។ ក្រោយមកទៀតរាជបញ្ញត្តិថ្ងៃទី ១៤ ខែកញ្ញា ១៩២២គ.ស. បានបង្កើតឱ្យមានសាលាលហុ សាលាដំបូង សាលាឧទ្ធរណ៍ សាលាឧក្រិដ្ឋ និងសាលាវិនិច្ឆ័យ ។ ប៉ុន្តែសាលាទាំងនោះ ឬវិស័យតុលាការទាំងមូលត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រងរបស់រដ្ឋការអាណាព្យាបាលបារាំង ។[4]

## ២.៤. ការស្វែងរកកិច្ចការពារពីបារាំង

នៅឆ្នាំ ១៨៥៤គ.ស. បព្វជិតបារាំងម្នាក់ឈ្មោះ **មីស**(Miche) ដែលស្និទ្ធនឹងព្រះអង្គឌួង បានថ្វាយយោបល់ដល់ព្រះអង្គឱ្យធ្វើទំនាក់ទំនងជាមួយព្រះចៅអធិរាជបារាំង ណាប៉ូលេអុងទី៣ដើម្បីឱ្យបារាំងជួយការពារប្រទេសកម្ពុជា ។ព្រះចៅអធិរាជបារាំង ណាប៉ូលេអុងទី៣ បានបញ្ជូនគណៈប្រតិភូមួយរូប គឺលោក **ដឺម៉ុងទីញី** ឱ្យមកកម្ពុជាយ៉ាងរួសរាន់ (១៨៥៥គ.ស.) ដើម្បីពិនិត្យស្ថានភាពនៅកម្ពុជា ។

-ព្រះអង្គបានយកព្រះទ័យរំដោះខ្លួនចេញឱ្យផុតពីភាពចំណុះគេ (១៨៤១-១៨៦០គ.ស.) ប្រទេសខ្មែរនៅតែស្ថិតក្រោមអំណាចសៀម និងយួននៅឡើយ ។ ព្រះបាទអង្គឌួងទ្រង់តូចព្រះទ័យយ៉ាងខ្លាំងព្រះអង្គបានខិតខំរកគ្រប់មធ្យោបាយដើម្បីរំដោះទឹកដី និងគេចឱ្យផុតពីភាពចំណុះគេ ។

នៅឆ្នាំ១៨៥៥គ.ស. បេសកជនបារាំងប្រចាំស្រុកចិន និងស្រុកសៀម ឈ្មោះ ស្ហាល ដឺម៉ុងទីញី (Charles de Montigny) បានទទួលបញ្ជាពីអធិរាជណាប៉ូឡេអុងទី៣ ឱ្យរៀបចំចុះកិច្ចព្រមព្រៀងភ្ជាប់ សម្ព័ន្ធមិត្តជាមួយនឹងនគរខ្មែរ តាមសំណើរបស់ព្រះបាទអង្គឌួង។ ក៏ប៉ុន្តែ មុននឹងទៅនគរខ្មែរ លោកដឺម៉ុងទីញី បានធ្វើដំណើរកាត់តាមនគរសៀម ហើយបានធ្លោយមាត់ប្រាប់សៀមអំពីគម្រោងមកចុះសន្ធិសញ្ញាសម្ព័ន្ធភាពជាមួយនឹងនគរខ្មែរ។ សៀមដឹងអំពីរឿងនេះ ស្តេចសៀមបានចាត់មន្ត្រីម្នាក់ឱ្យក្លែងខ្លួនជាអ្នកដំណើរ ធម្មតា ហើយចុះកប៉ាល់ជាមួយ លោកដឺម៉ុងទីញី ដើម្បីឃ្លាំតាមមើលដំណើររបស់ លោកដឺម៉ុងទីញីផង និងដើម្បីនាំសារមកថ្វាយព្រះរាជាខ្មែរផង ដើម្បីគំរាមកុំឱ្យព្រះអង្គចុះសន្ធិសញ្ញាជាមួយបារាំង។ ពេលធ្វើដំណើរមកដល់ស្រុកខ្មែរ លោកដឺម៉ុងទីញី បានប្រព្រឹត្តកំហុសឆ្គងមួយទៀត គឺលោកមកស្នាក់នៅត្រឹមខេត្តកំពតប៉ុណ្ណោះ ដោយមិនបានធ្វើដំណើរទៅដល់រាជធានីឧដុង្គ ដើម្បីជួបព្រះរាជាខ្មែរដោយផ្ទាល់នោះទេតែបែរជាចាត់បុព្វជិត កាតូលិកម្នាក់ឱ្យជាតំណាងទៅចូលគាល់ព្រះបាទអង្គឌួងទៅវិញ។ ណាមួយភ័យខ្លាចរង

[4] -ត្រឹងងាប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ១៩៧៣ ទំព័រ១៦៩

ការវាយប្រហារពីសំណាក់នគរសៀម ណាមួយទៀត មើលឃើញ អំពីចរឹកខ្ជិខ្ជារបស់មន្ត្រីបារាំង ដែលមិនគួរឱ្យទុកចិត្តថា បារាំងពិតជានឹងមិនអាចជួយការពារប្រទេសខ្មែរពីការវាយប្រហាររបស់សៀមបាន ព្រះបាទអង្គឌួង ក៏បានបដិសេធមិនចុះសន្ធិសញ្ញាជាមួយបារាំង ហើយលែងស្វះស្វែងរកអន្តរាគមន៍ពីបារាំងតទៅទៀត។ រហូតដល់ឆ្នាំ១៨៥៨គ.ស. នៅក្រោយពេលឃើញបារាំងបញ្ជូនទ័ពមកវាយលុកលើអាណ្ណាមនៅកូសាំងស៊ីនទើបព្រះបាទអង្គឌួងចាប់ ផ្តើមពិចារណាចង់ទាក់ទងបារាំងម្តងទៀត។ ក៏ប៉ុន្តែ ព្រះអង្គត្រូវធ្លាក់ព្រះកាយប្រឈួន និងសោយទិវង្គត នៅឆ្នាំ១៨៦០គ.ស. ហើយបុត្រាច្បងរបស់ព្រះអង្គ ឈ្មោះអង្គវតី ក៏បានឡើងមកស្នងរាជ្យជាព្រះមហាក្សត្រខ្មែរ ដោយយកព្រះនាមថា ព្រះបាទនរោត្តម។

នៅឆ្នាំ១៨៦២គ.ស. បារាំងបានឈ្នះសង្គ្រាមនៅវៀតណាមខាងត្បូង ដោយដណ្តើមយកទឹកដីកូសាំងស៊ីនមកគ្រប់គ្រងជាអាណាខេត្តរបស់បារាំង។មួយឆ្នាំក្រោយមកទៀត ទេសាភិបាលបារាំងនៅកូសាំងស៊ីន បានបញ្ជូនតំណាងម្នាក់ ឈ្មោះ ឌូដារ ដឺឡាគ្រេ (Doudart de Lagrée) ឱ្យទៅចូលគាល់ព្រះបាទនរោត្តម នៅរាជធានីឧដុង្គ។ ក្រោយពីបានឮបន្ទូលរបស់ព្រះបាទនរោត្តមដែលថា ព្រះអង្គមិនចង់នៅរណបសៀមទៀតទេ ទើបលោកឌូដារ ដឺឡាគ្រេ ក៏បានស្នើឱ្យព្រះអង្គដាក់កម្ពុជាឱ្យស្ថិតក្រោមអាណាព្យាបាលបារាំងដោយសន្យាថា បារាំងនឹងការពារប្រទេសកម្ពុជាឱ្យរួចផុតពីការគ្រួតត្រារបស់នគរសៀម និងអាណ្ណាម។ ព្រះបាទនរោត្តមយល់ព្រម ហើយក៏បានចុះសន្ធិសញ្ញាទទួលយកអាណាព្យាបាលបារាំង នៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣គ.ស.។

នៅដើមឆ្នាំ ១៨៦៤គ.ស. បារាំងបានគាបសង្កត់ក្រុងបាងកក តាមផ្លូវទូត និងផ្លូវយោធា ដើម្បីឱ្យក្រុងបាងកកបញ្ជូនគ្រា ព្រះខ័នរាជ និងមកុដរាជ សម្រាប់រាជាពិសេក ព្រះបាទនរោត្តម ជាព្រះមហាក្សត្រពេញលក្ខណៈនៅក្រុងឧដុង្គ នាថ្ងៃទី៣ ខែមិថុនា ឆ្នាំ ១៨៦៤គ.ស. ។ដោយបានរើរាជធានីចេញពីឧត្តុង្គមកតាំងនៅភ្នំពេញ។នៅអាណ្ណាមឯណោះវិញបារាំងដែលបានយកកូសាំងស៊ីនធ្វើជាអាណាខេត្តរបស់ខ្លួនរួចទៅហើយនោះ បានប្រើកម្លាំងទ័ពព្យាយាមពង្រីកឥទ្ធិពលរបស់ខ្លួន ទៅកាន់ទឹកដីប៉ែកកណ្តាល និងប៉ែកខាងជើងនៃនគរអាណ្ណាមជាបន្តទៀត។ នៅទីបំផុត នៅឆ្នាំ១៨៨៤គ.ស. បារាំងបានយកនគរអាណ្ណាមទាំងមូលយកមកដាក់ក្រោមអាណានិគមបារាំង គឺទាំងភូមិភាគកណ្តាល ដែលគេហៅថា អាណ្ណាម និងភូមិភាគខាងជើងជាប់ព្រំដែនចិន ដែលគេហៅថា តុងកឹង។ នៅឆ្នាំដដែលនោះ គឺនៅយប់ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៨៨៤ គ.ស. នៅកម្ពុជា បារាំងបានបង្ខំឱ្យព្រះបាទនរោត្តម ឡាយព្រះហស្តលេខាលើអនុសញ្ញាថ្មីមួយទៀត ដើម្បីប្រគល់រាល់កិច្ចការផ្ទៃក្នុងនគរខ្មែរទាំងអស់ទៅឱ្យបារាំងជាអ្នកគ្រប់គ្រង បន្ថែមពីលើវិស័យការពារជាតិ និងកិច្ចការបរទេស ដែលបានព្រមព្រៀងគ្នា ក្នុងសន្ធិសញ្ញាឆ្នាំ១៨៦៣គ.ស.។ ការបះបោរប្រឆាំងនឹងបារាំងក៏បានចាប់ផ្ទុះឡើង ចាប់ពីចុងឆ្នាំ១៨៨៤គ.ស. រហូតដល់ដើមឆ្នាំ១៨៨៧គ.ស.។ ក្រោយពីមានការបះបោរនេះ បារាំងក៏បានប្រគល់អំណាចខ្លះៗ ទៅឱ្យព្រះរាជាខ្មែរវិញ ព្រមទាំងបានចាត់ចែងឱ្យមាន គណៈរដ្ឋមន្ត្រីព្រមទាំងរដ្ឋបាលសាធារណៈខ្មែរឡើង ក៏ប៉ុន្តែ រ៉េស៊ីដង់ជាន់ខ្ពស់បារាំង (Résident supérieur) ព្រមទាំងរ៉េស៊ីដង់បារាំង នៅតាមខេត្តចំនួន ៤ គឺ កំពត កំពង់ធំ ក្រចេះ និងពោធិសាត់ នៅតែមានអំណាចច្រើន ក្នុងកិច្ចការរដ្ឋបាលរបស់ ខ្មែរ។

### ៣. ការស្ថាបនាអាណាព្យាបាលបារាំងពីឆ្នាំ (១៨៦៣គ.ស.-១៨៦៧គ.ស.)

## ៣.១. សន្ធិសញ្ញាអាណាព្យាបាល ១១សីហា ឆ្នាំ ១៨៦៣គ.ស.

ប្រភពឯកសារបារាំងបានឱ្យដឹងថា នៅខែមេសា ឆ្នាំ១៨៦៣គ.ស. ព្រះបាទនរោត្តម ទ្រង់បានយាងមកកាន់ក្រុងឧត្តុង្គ ។នាយករងវសេនាតូចកាំភ្លើងធំ ជើងទឹកប្រ៊ីយែរដឺលីស (Briere de I'isle) ដែលបានកាន់កាប់តំបន់តាយនិញ(ជាប់នឹងប្រទេសកម្ពុជា)។ព្រះអង្គបានសំដែងភាពអន្ទះអន្ទែងរបស់ទ្រង់ឱ្យលោកប្រ៊ីយែរដឺលីសបានឃើញនូវការថយចុះ"។ព្រះអង្គបានប្រកាសជម្រាប ទៅលោកថាពួកភ្នាក់ងាររបស់សៀមបានត្រួតត្រាគ្រប់ផ្នែកទាំងអស់នៃរដ្ឋបាលខ្មែរ ហើយថាមន្ត្រីម្នាក់ដែលនៅក្រុងបាងកកបានបញ្ជូនមកនោះបាន ប្រតិបត្តិការឃ្លាំមើល ជាប្រចាំ មកលើព្រះអង្គ។ ព្រះបាទនរោត្តម បានបញ្ចប់ការសន្ទនាដោយប្រកាសថាព្រះអង្គ"ប្រាថ្នាចង់ឃើញ អំពើរបស់ប្រទេស បារាំងចាប់ផ្តើម"ដែលផ្អែកនៅលើអ្វី ដែលបានធ្វើរវាងគ្នានេះ គេបានតែងតាំង ដឺឡាក្រង់ឌីយែរ(De La Grandière)ឱ្យធ្វើជាទេសាភិបាលនៃកូសាំស៊ីននៅ ខែមករា ឆ្នាំ ១៨៦៣គ.ស.។ ដោយអនុលោមតាម សំណើរបស់ស្លាស្ស៊ីលូឡូបា (Chase loup Laubat)គាត់បានសម្រេចចិត្តនិយាយកិច្ចការអ្វីៗដោយផ្ទាល់ជាមួយព្រះមហាក្សត្រតែម្តងដោយ មិនឆ្លងតាមរយៈព្រះរាជវាំងនៃក្រុងបាងកកឡើយ។ គឺ ដោយសាហេតុនេះនៅពេលដែល លោកប្រ៊ីយែរដឺលីស(Briere de I'isle) ណែនាំ លោកឱ្យយកប្រទេសកម្ពុជាដាក់ ក្រោមកិច្ចការពាររបស់ខ្លួន លោកទេសាភិបាលបានបញ្ជូនវេជ្ជបណ្ឌិត ហិនកាត (Hennecart) និង អនុនាវីទោ ឌូដាត៏ ដឺឡាគ្រេ (Doudart de Lagrée)ឱ្យមកបំពេញបេសកកម្ម នៅឧដុង្គតាមនាវាធុនអាវីសូ (Aviso)ឈ្មោះ Gia Dinh ។ សម្តេចមីស្ស ដែលបានស្គាល់ ព្រះមហាក្សត្រ នរោត្តម យ៉ាងជិតស្និទ្ធនោះ បានអមដំណើរអង្គបេសកកម្ម ក្នុងឋានៈសម្តេចជាអ្នកបកប្រែ។វាលេចចេញអំពីបេសកកម្មនេះគឺព្រះបាទនរោត្តម "ពោរពេញទៅដោយចេតនាល្អ ចំពោះប្រទេសបារាំង"ម៉្យាងទៀត វាហាក់ដូចជាព្រះមហាក្សត្រទ្រង់ស្រពិចស្រពិលថាប្រទេសបារាំង ការពារ បុព្វហេតុរបស់ទ្រង់ស៊ីវត្ថា ដែលមានប្រជាប្រិយភាពជាងព្រះអង្គ។តើរឿងនេះគឺជាការគំរាមកំហែងកេ្លីមួយបែប ពីសំណាក់បេសកជនរបស់បារាំង ឬ? ក្នុងសភាពបច្ចុប្បន្ននៃប្រភពឯកសារ គ្មានអ្វីដែល អាចឱ្យនិយាយបានឡើយ។ គ្រប់ករណីទាំងអស់ តាមលោក ដឺឡាគ្រេ (De lagre) គេត្រូវឆ្លៀតយក ប្រយោជន៍ អំពីចេតនាល្អរបស់ព្រះមហាក្សត្រមុននឹងឥទ្ធិពលផ្សេងៗធ្វើឱ្យព្រះអង្គផ្លាស់ប្តូរព្រះទ័យ។លោកឧត្តមនាវី ដឺឡាគ្រេ( de La Grandière ) បានមកកាន់ក្រុងឧត្តុង្គនៅខែសីហាឆ្នាំ១៨៦៣គ.ស.។ សម្តេចមីស្ស(Miche) បានថ្វាយព្រះបាទនរោត្តមនូវគម្រោងសន្ធិសញ្ញាមួយ នឹងព្រះបាទនរោត្តម។ សន្ធិសញ្ញាមិត្តភាព និងពាណិជ្ជកម្មមួយដែលប្រែក្លាយឱ្យទៅជាអាណាព្យាបាលធិរាជភាព ដែលប្រទេសបារាំង បានអះអាងថា បានជាមត៌តក ពីព្រះរាជវាំងក្រុងវេ ចាប់ពីពេលដែលខ្លួនបានទទួលផ្នែកពាក់កណ្តាលខាងត្បូងនៃកូសាំងស៊ីនមក។

មាត្រា១ ៖ព្រះចៅអធិរាជបារាំងព្រមផ្តល់ នូវកិច្ចការការពារព្រះអង្គចំពោះ ព្រះរាជានៃប្រទេសកម្ពុជា

មាត្រា២៖ ព្រះចៅអធិរាជបារាំងនឹងតែងតាំងរេស៊ីដង់ (Resident)៖ អ្នកប្រចាំទី ឬអ្នកតាំងលំនៅក្រៅ ស្រុកកំណើតមួយរូបនៅអមព្រះរាជានៃប្រទេសកម្ពុជាដែលនឹងទទួលភារកិច្ចពិនិត្យលើការអនុវត្តឱ្យបានត្រឹមត្រូវនូវ លិខិតអាណាព្យាបាល(Lettre du protectorat) ទាំងនេះនៅក្រោមអំណាច ដ៏ខ្ពង់ខ្ពស់នៃទេសាភិបាល កូសាំងស៊ីន (Cochinchine)។ ព្រះរាជានៃប្រទេសកម្ពុជា នឹងអាចតែងតាំងរេស៊ីដង់ខ្មែរ មួយរូបនៅក្រុងព្រៃនគរដើម្បីទាក់ទងផ្ទាល់ ជាមួយទេសាភិបាលកូសាំងស៊ីន (Cochinchine) ។

មាត្រា ៣៖ រេស៊ីដង់បារាំង នឹងមានឋានៈជាមន្ត្រីជាន់ខ្ពស់នៅប្រទេសកម្ពុជា ហើយត្រូវផ្តល់ឋានៈនិងកិត្តិយសនេះនៅក្នុងព្រះរាជាណាចក្រទាំងមូល ។

មាត្រា៤ ៖ កុងស៊ុល( Consul )នៃប្រជាជាតិដទៃទៀតក្រៅពីបារាំងនឹងអាចនៅអមព្រះរាជា នៃប្រទេសកម្ពុជា បានទេ ឬក៏នៅកន្លែងណាមួយលើទឹកដីនេះ ដោយមិនបានប្រាប់ព័ត៌មានទៅទេសាភិបាលកូសាំងស៊ីនហើយដែលមិនមានការយល់ព្រមជាមួយរដ្ឋាភិបាលកម្ពុជា។

មាត្រា៥ ៖ ជនជាតិបារាំងនៅលើទឹកនៃព្រះរាជាណាចក្រកម្ពុជា នឹងមានសេរីភាពពេញលេញ ចំពោះខ្លួនគេផ្ទាល់ និងកម្មសិទ្ធរបស់ពួកគេ។ គេនឹងអាចធ្វើចរាចរអាចមានរបស់ជាកម្មសិទ្ធិ និងអាចតាំងទីលំនៅដោយសេរីនៅគ្រប់ខេត្ត និងតំបន់នៃព្រះរាជាណាចក្រនេះ កាលណាគេជម្រាបដំណឹង ទៅមន្ត្រីជាន់ខ្ពស់ខ្មែរណាម្នាក់ ដែល នឹងចេញលិខិតអនុញ្ញាតឱ្យ។

មាត្រា ៦៖ ជនជាតិខ្មែរនឹងមានសេរីភាពពេញលេញនៅលើទឹកដីនៃចក្រភពបារាំង ចំពោះខ្លួនគេផ្ទាល់ និង កម្មសិទ្ធ។ គេអាចធ្វើចរាចរណ៍ អាចមានរបស់ជាកម្មសិទ្ធិ និង អាចតាំងទីលំនៅដោយសេរីនៅគ្រប់ខេត្តនិងតំបន់នៃព្រះរាជាណាចក្រនេះ កាលណាគេជម្រាប ដំណឹងទៅនាយទាហាន បារាំងណាម្នាក់ដែលមានសមត្ថកិច្ច នឹងចេញលិខិត អនុញ្ញាតឱ្យ។

មាត្រា៧ ៖ កាលណាជនជាតិបារាំងណាម្នាក់ ដែលតាំងទីលំនៅ ឬធ្វើដំណើរឆ្លងកាត់រាជាណាចក្រកម្ពុជា មានរឿងក្តីក្តាំងឬតវ៉ាប្រឆាំងនឹងជនជាតិខ្មែរណាម្នាក់ ដំបូងគេត្រូវដាក់ពាក្យបណ្តឹង ទៅរេស៊ីដង់បារាំង  ក្រោយពីបានពិនិត្យលើសំណុំរឿង និងព្យាយាមសម្រុះសម្រួលតាមលក្ខណៈ ជាមិត្តភាព។ក្នុងករណីបែបនេះកាលណាជនជាតិ ខ្មែរណាម្នាក់ មានរឿងក្តីក្តាំងជាមួយជនជាតិបារាំង រេស៊ីដង់បារាំង នឹងស្តាប់ការទាមទារនោះ ដោយយកចិត្តទុកដាក់ និង រិះរកមធ្យបាយសម្រុះសម្រួល ក្នុងលក្ខណៈជាមិត្តភាព។ក្នុងករណីនីមួយៗប្រសិនបើគេមិនអាចដោះស្រាយរួច  រេស៊ីដង់បារាំងនិងស្នើរសុំជំនួយពីមន្ត្រីខ្មែរម្នាក់មានសមត្ថកិច្ច ហើយមន្ត្រីទាំងពីរនេះក្រោយពីបានសុំណុំរឿងរួមគ្នានិងធ្វើការវិនិច្ឆ័យរួមគ្នាទៅតាមគតិយុត្តិធម៌។ រេស៊ីដង់បារាំងនឹងមិនធ្វើអន្តរាគមន៍ នៅក្នុងរឿងវិវាទរវាងខ្មែរនិងខ្មែរទេ។បទឧក្រិដ្ឋដែលបានប្រព្រឹត្តដោយជនជាតិបារាំងនៅក្នុងរាជាណាចក្រកម្ពុជា និងត្រូវយកទៅជំនុំជម្រះ នៅឯក្រុងព្រៃនគរ ដោយតុលាការមានសមត្ថកិច្ច។ នៅក្នុងករណីបែបនេះកម្ពុជានឹងបង្ករលក្ខណៈងាយស្រួលដល់រេស៊ីដងបារាំង ក្នុងការចាប់ជនប្រព្រឹត្តបទល្មើស រួចបញ្ជូនទៅឱ្យ ទេសាភិបាលកូសាំងស៊ីន។នៅក្នុងករណីអវត្តមានរបស់រេស៊ីដងបារាំងមេបញ្ជាការ នៃកងកម្លាំងបារាំងនិងបំពេញភារៈកិច្ចនេះដើម្បីអនុវត្តយុតិធម៌ តាមខ្លឹមសារខាងលើបញ្ជាក់ឱ្យឃើញថាខ្មែរចាញ់ប្រៀបបារាំងខ្លះទៅហើយ ប៉ុន្តែខ្មែរនៅអាចទទួលយកបាន ដោយការសន្យារបស់បារាំងថានឹងការពារប្រទេសកម្ពុជាពីការវាយលុកពីប្រទេសជិតខាង។ម្យ៉ាងទៀតសិទ្ធិអំណាចព្រះរាជានៅរក្សាដំណែងដដែល។ ក្រៅពីនេះនៅមានលក្ខណៈមួយចំនួនទៀតដូចជា៖

-នាវាបារាំងនឹងមានសេរីភាពពេញទី ធ្វើដំនួញនៅដែនដីទឹកដីកម្ពុជា។ មានតែសិទ្ធិលើអាភៀនទេដែល ត្រូវបានគេរក្សាទុក។ ដូចគ្នានេះកំពង់ផែទាំងឡាយនៃទឹកដីកូសាំងស៊ីននឹងបើកសេរីភាពឱ្យនាវា ដែលដឹកជញ្ជូនទំនិញខ្មែរក្នុងលក្ខខណ្ឌដែលនាវាទាំងនោះ មានលិខិតអនុញ្ញាតនៃនាវាចរដែលចុះទិដ្ឋាកាដោយទេសាភិបាលបាំរាំង។

-រដ្ឋាភិបាលខ្មែរសន្យាការពារ បេសកជនកាតូលិកពួកអ្នកស្រាវជ្រាវបារាំងនឹងតាមបែបទូទៅ ជនជាតិបារាំងទាំងអស់ដែលធ្វើនាវាចរឬស្នាក់អាស្រ័យនៅក្នុងជាដែនដីកម្មសិទ្ធរបស់បារាំងនឹងត្រូវបានកាពារ ដោយទេសាភិបាល នៃ ដែនដីទាំងនោះ។

-ព្រះចៅអធិរាជរបស់ប្រជាជនបារាំងសន្យារក្សាប្រទេសកម្ពុជាឱ្យនៅមានសណ្តាប់ធ្នាប់នៃសន្តិភាព ការពារប្រឆាំងរាល់ការវាយប្រហារពីប្រទេសក្រៅ ជួយដកហូតពន្ធដារ នឹងផ្តល់ភាពងាយស្រួល គ្រប់ បែបយ៉ាងដើម្បី ភ្ជាប់ គមនាគមន៍ ជាមួយសមុទ្រ។ប្រទេសកម្ពុជា ធ្វើសម្បទាន ឱ្យបារាំង ការតាំងទីលើទន្លេចតុមុខដើម្បីរក្សាឃ្លាំងធ្យូងថ្ម ភណ្ឌាគារិកសម្រាប់ផ្គត់ផ្គង់ស្បៀង សម្រាប់នាវានឹងបន្ទាយតូចមួយសម្រាប់ដាក់កងពល។ទីបញ្ចប់ប្រទេកម្ពុជាបានធ្វើសម្បទានឱ្យប្រទេសបារាំងសិទ្ធធ្វើអាជីវកម្ម ព្រៃឈើនៃព្រះរាជាណាចក្រដើម្បីកសាងនាវា សោហ៊ុយ អាជីវកម្ម ដែល នៅ សល់ជាបន្ទុកនៃ រដ្ឋាភិបាលបារាំង ។

ដូច្នេះជាសរុប ទៅសន្ធិសញ្ញាឆ្នាំ១៨៦៣គ.ស. នេះគ្រាន់តែជាសន្ធិសញ្ញាមួយនៃអាណាព្យាបាល តែប៉ុណ្ណោះ វាមិនបានកាត់បន្ថយសិទ្ធិរបស់ព្រះមហាក្សត្រទេក្នុងវិស័យ នយោបាយនឹងរដ្ឋបាលលើកលែងតែអ្វីដែលពាក់ព័ន្ធនឹងកាហាមឃាត់តាំងឡើងនៃចំណងផ្លូវទូត ដែលគ្មាន ស្រុះស្រួលអំពីប្រទេបារាំងនោះ។ ក៏ប៉ុន្តែសន្ធិសញ្ញានេះត្រូវបានឆ្លើយរួចតាមគំនិតផ្តួចផ្តើមរបស់ទេសាភិបាលនៃកូសាំងស៊ីនដែលធ្វើហួសពីសេចក្តីណែនាំដែលលោកបានទទួលពីក្រុងប៉ារីសមក។ជារឿយៗគំនិតផ្តួចផ្តើម បែបនេះនឹងអាចកើតឡើងវិញនៅពេលបន្ទាប់មកហើយផលវិបាកមិនមែនសុទ្ធតែឱ្យរីករាយជានិច្ចនោះទេ ។ ប្រាកដហើយថាក្នុងកិច្ចការទាំងនោះ ទេសាភិបាលទាំងឡាយនៃឥណ្ឌូចិន បានទទួលនៅឥទ្ធិពលរួមនៃ សម្ពាធរួមដែលពួកអាណានិគមនៅក្រុងព្រៃនគរ ។ ប្រជាជនឥណ្ឌូចិនដែលភ័យខ្លាចខ្លាំងជាងគេនោះ គឺការរីកដុះដាលនៃឥទ្ធិពលអង់គ្លេសនៅអាស៊ីអាគ្នេយ៍។ ដូច្នេះវាមិនមែនជាផលនៃការចៃដន្យនោះទេ បើសិនជាមាត្រាមួយនៃសន្ធិសញ្ញាបានយល់ព្រមឱ្យប្រទេសបារាំងតាំងមូលដ្ឋាននាវាមួយនឹងបន្ទាយតូចមួយនៅជ្រោយ ចង្វានោះដែលវាជាទីបន្តក់នៃផ្លូវតាមទន្លេដែលជាចំណុចចាប់ផ្តើមនៃការគំរាមសំឡុតនៅពេលអនាគត នោះទីបញ្ចប់ គេមិនត្រូវបំភ្លេចទេថា បើសិនជាការិះគន់ស៊ីជម្រៅនៃអត្ថបទ រំលេចឱ្យឃើញ សន្ធិសញ្ញាថ្ងៃ១១ សីហា ១៨៦៣គ.ស. ជាសន្ធិសញ្ញាអាណាព្យាបាលដ៏សាមញ្ញមួយនោះក្តី ការតាំងទេសាភិបាលមួយរូបនៅប្រទេសកម្ពុជានិងអន្តរាគមន៍ពីបារាំងក្នុងវិស័យពន្ធដា នោះ វាបានលាក់បាំង នយោបាយអន្តរាគមន៍និយមមួយ ដែលជម្រុញកាន់តែខ្លាំងឡើងៗពីខាងភាគីនៃប្រទេសបារាំងនោះ។

**-ដំណាក់កាលទី១**ដំបូងបារាំងប្រើវិធីត្រជាក់ក្នុងការអនុវត្តការត្រួតត្រាខ្មែរ ។ ក្រោយពីត្រឡប់ទៅព្រៃនគរវិញ បារាំងបានកំណត់គោលការណ៍ពីរយ៉ាងគឺៈ

-ដើម្បីបានបញ្ចូលដែនដីកូសាំងស៊ីនជាកម្មសិទ្ធិ របស់ខ្លួនបារាំងបានយកលេសមួយសមស្របមកកំណត់ ។ ពោលគឺបារាំងមានសិទ្ធិលូកដៃចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួន ព្រោះប្រទេសខ្មែរ ពីមុនមកធ្លាក់ជាសាមាន្តរដ្ឋរបស់យួន ។

-លោកទេសាភិបាល បូណាសង្កត់ធ្ងន់លើសេចក្តីប្រាថ្នារបស់សៀមមកលើខ្មែរ ដែលប្រទេស បារាំងត្រូវតែការពារឯករាជ្យនៃប្រទេសនេះដែលមានការទំនាក់ទំនងទៅនឹងសន្តិភាពនៃដែនដីកូសាំងស៊ីន។ ក្រោយពីបានទូលថ្វាយហេតុផលសព្វគ្រប់ និងសូមព្រះអង្គព្រមដាក់ប្រទេសខ្មែរឱ្យបារាំងជួយការពារបព្វជិតមីស ( Miche ) ទ្រង់បានថ្វាយគម្រោងសន្ធិសញ្ញាមួយ ហើយទ្រង់បានធ្វើការពិភាក្សាជា មួយព្រះរាជាខ្មែរ

លុះដល់ថ្ងៃទី ១១ ខែសីហា ឆ្នាំ ១៨៦៣គ.ស. លោកឡាក្រង់ឌីយែ ( La Grandiere ) បានចុះហត្ថលេខាលើសន្ធិសញ្ញាក្នុងនាមលោកផ្ទាល់ ជាមួយនិងសម្ដេចនរោត្តមដែលបានយល់ព្រម ទាំងញញើតញញើម ។ នេះជាសន្ធិសញ្ញាលើកទី១ ដែលខ្មែរយល់ព្រមឱ្យបារាំងធ្វើអាណាព្យាបាល ។

## ៣.២. សន្ធិសញ្ញាថ្ងៃ ២៧ មិថុនា ១៨៨៤

មាត្រា១ ៖ព្រះរាជានៃប្រទេសកម្ពុជាព្រមទទួលយក នូវរាល់កំណែទម្រង់រដ្ឋបាល តុលាការហិរញ្ញវត្ថុ និង ពាណិជ្ជកម្ម។ចំពោះកំណែទម្រង់ទាំងនេះ រដ្ឋាភិបាលនៃសាធារណៈរដ្ឋបារាំង យល់ថា នៅពេលអនាគតមានផលប្រយោជន៍ នឹងបង្កលក្ខណៈងាយស្រួលដល់ការអនុវត្តរបបអាណាព្យាបាលរបស់ខ្លួន។

មាត្រា២ ៖ ព្រះរាជាកម្ពុជាក្នុងអតីតកាលនឹងបន្តគ្រប់គ្រងរដ្ឋ និងដឹកនាំកិច្ចការរដ្ឋបាល លើកលែងតែការកាត់បន្ថយ អំណាចដែលជាលទ្ធផលនៃកិច្ចព្រមព្រៀងនេះ។

មាត្រា៣ ៖ មន្ត្រីខ្មែរនឹងបន្តគ្រប់គ្រងខេត្តក្រោមការត្រួតពិនិត្យពីអាជ្ញាធរបារាំង លើកលែងតែការបង្កើតនិងការទារពន្ធដារ (គយ សាធារណៈការ) ហើយជាទូទៅកិច្ចការទាំងឡាយណាដែលតម្រូវឱ្យមានការដឹកនាំតែមួយគឺភ្នាក់ងារបារាំង។

មាត្រា៤ ៖ រេស៊ីដង់ (Resident ) និងរេស៊ីដង់រង (Resident Adjoint ) ដែលតែងតាំងដោយរដ្ឋាភិបាលបារាំង នឹងត្រូវកាន់កាប់គ្រប់គ្រងខេត្ត ឬ កន្លែងដែលចាំបាច់។

មាត្រា៥ ៖ អគ្គរេស៊ីដង់មានសិទ្ធិធ្វើសាវនាការជាឯកជននៅអមព្រះរាជានៃប្រទេសកម្ពុជា។

មាត្រា៦ ៖ការចំណាយលើរដ្ឋាភិបាលនៃព្រះរាជាណាចក្រ និងការចំណាយសម្រាប់របបអាណាព្យាបាល ជាបន្ទុករបស់ប្រទេស កម្ពុជា។

មាត្រា៧ ៖ ក្រោយពីរៀបចំចិការនៃរាជាណាចក្រកម្ពុជា និងមានការកំណត់តារាងប្រាក់បៀវត្សរ៍សម្រាប់ព្រះរាជា។

មាត្រា៨ ៖ របបទាសភាពត្រូវលប់បំបាត់ចោលនៅលើទឹកដីនៃប្រទេសកម្ពុជាទាំងមូល។

មាត្រា៩ ៖ ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា រហូតមកទល់ពេលនេះ ជាកម្មសិទ្ធិផ្ដាច់មុខរបស់រាជបល្ល័ង្ក។នៅពេលអនាគតអាជ្ញាធរបារាំងនិងខ្មែរ នឹងរៀបចំដីកម្មសិទ្ធិនៅក្នុង ប្រទេសកម្ពុជាវិហារគ្រីស្តសាសនា និង វត្តអារាមព្រះពុទ្ធសាសនា នឹងរក្សាកម្មសិទ្ធិដីធ្លីដែលកំពុងកាន់កាប់ក្នុងពេលបច្ចុប្បន្ន។

មាត្រា១០ ៖ទីក្រុងភ្នំពេញនឹងគ្រប់គ្រងដោយគណៈកម្មការក្រុងដែលមានសមាសភាពដូចតទៅ ៖

| | |
|---|---|
| -អគ្គរេស៊ីដង់ ជាប្រធាន | ០១នាក់ |
| -មន្ត្រី ឬ ពាណិជ្ជករបារាំង | ០៦នាក់ តែងតាំងដោយទេសាភិបាលកូសាំងស៊ីន |
| -ជនជាតិខ្មែរ | ០៣នាក់ |
| -ជនជាតិអាណ្ណាម | ០១នាក់ |
| -ជនជាតិចិន | ០២នាក់ |
| -ជនជាតិឥណ្ឌា | ០១នាក់ |

-ជនជាតិម៉ាឡេ ០១នាក់ ដែលតែងតាំងដោយព្រះរាជាខ្មែរ គឺធ្វើទៅតាមតារាងដែលបាន ស្នើឡើងដោយទេសាភិបាលកូសាំងស៊ីន។

មាត្រា១១ ៖ កិច្ចព្រមព្រៀងនេះបំពេញបន្ថែមលើសន្ធិសញ្ញា ១១ សីហា ១៨៦៣គ.ស. ។ ក្នុងករណីមានការជំទាស់មានតែអត្ថបទជាភាសាបារាំង ទេដែលយកជាការបាន។ កិច្ចព្រមព្រៀងនេះនឹងដាក់ជូនរដ្ឋាភិបាល នៃប្រទេសសាធារណរដ្ឋ បារាំងដើម្បីឱ្យសច្ចាប័ន។ **ដូច្នេះសន្ធិសញ្ញាចុះថ្ងៃ ១៧ មិថុនា ១៨៨៤គ.ស. បានបណ្តាលឱ្យមានប្រតិកម្ម យ៉ាងខ្លាំង ពីសំណាក់ប្រជារាស្ត្រខ្មែរ** ហើយពួកមន្ត្រីបារាំងភាគច្រើន បានយល់ថាព្រះបាទនរោត្តម នេះហើយជាអ្នកដឹកនាំចលនាតស៊ូប្រឆាំងបារាំង នេះ ឯង។ ជាការពិតពីព្រោះគេបានដឹងច្បាស់ថាព្រះបាទនរោត្តម ទ្រង់បានខិតខំគាំទ្រនូវចលនាតស៊ូនេះខ្លាំងណាស់ រហូតដល់ជនជាតិបារាំងមានការជឿជាក់ យល់ថាព្រះអង្គជាអ្នកមេគំនិត ទៀតផង។ ចាប់ពីខែវិច្ឆិកា ឆ្នាំ១៨៨៤គ.ស. ដល់ខែកុម្ភៈឆ្នាំ១៨៨៧គ.ស. ចលនាតស៊ូរបស់អ្នកស្នេហាជាតិខ្មែរបានកើតឡើងពេញទូទាំងប្រទេស។ បារាំងត្រូវលើកទ័ពទៅតស៊ូគ្រប់ទិសទី។ នៅទីក្រុងមានទាហានការពារយ៉ាងខ្លាំងហើយទ័ពបារាំងត្រូវទទួលការខូចខាតយ៉ាងធំណាំព្រោះត្រូវទប់ទល់ការវាយប្រហាររបស់អ្នកស្នេហាជាតិខ្មែរផង ត្រូវស្លាប់ដោយសារជម្ងឺនិងធាតុអាកាសផង។ ក្រោយមកបារាំងបានប្រគល់អំណាចឱ្យព្រះរាជាវិញ ដោយឱ្យមានតែរេស៊ីដង់ ស៊ុប៉េរីយ័រម្នាក់នៅអមព្រះអង្គ។ កិច្ចការរដ្ឋត្រូវប្រគល់ទៅឱ្យមន្ត្រីខ្មែរកាន់កាប់វិញ។ នៅតាមខេត្តមានតែរេស៊ីដង់បារាំង ៤នាក់ប៉ុណ្ណោះ(នៅ កំពត ក្រចេះ កំពង់ធំ និង ពោធិសាត់) ដែលបានទទួលបញ្ជាថាមិនត្រូវទៅជ្រៀតជ្រែកក្នុងកិច្ចការរបស់អ្នកស្រុកហើយត្រូវគោរពទំនៀមទំលាប់ប្រពៃណីនិង សាសនារបស់អ្នកស្រុកថែមទៀត។ ការកែទម្រង់ទាំងឡាយដែល លោក រេស៊ីដង់ស៊ុប៉េរីយ័រ បានស្នើត្រូវបានទទួលសេចក្តីយល់ព្រម ពីព្រះមហាក្សត្រសិនទើបអាចយកទៅអនុវត្តបាន។ លុះព្រះរាជាទ្រង់បានយល់ព្រមតាមនយោបាយថ្មី របស់បារាំងនៅប្រទេសខ្មែរហើយសន្តិភាពក៏មានឡើង។បន្ទាប់មកព្រះអង្គ ទ្រង់យាងទៅជួបមេដឹកនាំការតស៊ូទាំងអស់នៅវត្តព្រៃ ទទឹង ហើយទ្រង់បញ្ជាក់ប្រាប់ថា រដ្ឋការបារាំងបានប្រគល់អំណាចមកឱ្យខ្មែរវិញ ។ ដូច្នេះ ការតស៊ូរបស់អ្នកស្នេហារជាតិក៏ត្រូវបញ្ចប់ត្រឹមពេលនេះដែរ។មេដឹកនាំសំខាន់ៗដែលព្រះអង្គបានយាងទៅជួបមាន៖

ឧកញ៉ាឧទ័យាធិរាជ ចៅហ្វាយស្រុក សំរោងទង ឧកញ៉ា វង្សាឧទ័យទិត ចៅហ្វាយស្រុកភ្នំស្រួច លោកវិបុលរាជកែប នៅគងពិសី វង្សាអគ្គរាជញ៉ឹកនៅកណ្តាលស្ទឹង វិបុលសង្គ្រាម នៅស្អាង ចក្រីម៉ានៅបាទី។ចំណែកឯក្រឡាហោមគង់និង ពិស្ណុលោកឈូក មិនបានអញ្ជើញទៅជួបជុំក្នុងពេលនោះទេ លោកគ្រាន់តែបានចាត់តំណាងឱ្យទៅទូលសុំធ្វើសវនាការជាមួយព្រះរាជាថ្ងៃក្រោយ។ពេលដឹងថាស្រុកមានសន្តិភាពហើយ លោកពិស្ណុលោកឈូកត្រូវគេលួចសម្លាប់ ឯលោកក្រឡាហោមគង់ត្រូវបារាំងបញ្ជាឱ្យ នាហ្មឺនខ្មែរម្នាក់ ទៅបញ្ឆោតឱ្យលោកឡើងកាប៉ាល់បារាំង ហើយលោកត្រូវបារាំងចាប់ចងផ្អោបនឹងបំពង់ភ្លើងកប៉ាល់រហូតដល់អស់ជីវិត។

## ៣.៣. សន្ធិសញ្ញាសៀម-ខ្មែរថ្ងៃទី១ធ្នូឆ្នាំ ១៨៦៣

សៀមមានគំនិតអាក្រក់លោភលន់ចង់បានទឹកដីខ្មែរបន្ថែមទៀត ដោយបង្ខំឱ្យព្រះបាទនរោត្តមចុះហត្ថលេខាដោយសម្ងាត់ជាមួយសៀមយល់ព្រមទទួលស្គាល់ប្រទេសកម្ពុជាជាសាមន្តរដ្ឋរបស់សៀម។

ព្រះបាទនរោត្តមយល់ព្រមប្រគល់ខេត្តមួយចំនួនទៅឱ្យប្រទេសសៀមដូចជា៖ ខេត្តបាត់ដំបង សៀមរាម មង្គលបុរី កំពង់ស្វាយ និងពោធិសាត់។ដោយមិនចង់ឱ្យព្រះអង្គទាក់ទងជាមួយនឹងបារាំងឡើយ។ដូចជា សៀមប្រឹងរកល្បិចមិនឱ្យអគ្គកុងស៊ុលបារាំងប្រចាំនៅសាំងហ្គាពួរចូលមកជួបព្រះបាទអង្គដួងឡើយ កាលពី ព្រះអង្គគង់នៅរាជធានីឧដុង្គ។

## ៣.៤. សន្ធិសញ្ញាបារាំង-សៀមថ្ងៃទី០១ ធ្នូ ឆ្នាំ១៨៦៧គ.ស.

ចាប់តាំងពីឆ្នាំ១៣៥០គ.ស.. មកទំនាក់ទំនងខ្មែរ-សៀមកើតមានជាបន្តបន្ទាប់។ អំណាចរបស់សៀម ជះឥទ្ធិពលមកលើខ្មែរ យ៉ាងខ្លាំងក្លា ក្រោយពីបានបង្កើតរាជាណាចក្រអាយុធ្យាមក។ ខ្មែរបានធ្លាក់ចុះខ្សោយ អំណាចជាបន្តបន្ទាប់ ហើយស្ថិតនៅជារដ្ឋចំណុះរបស់សៀម និងក្រោមអាណានិគម សៀម ចាប់ពីឆ្នាំ ១៧៩៥គ.ស..ដល់១៨៦៣គ.ស.គឺក្នុងរជ្ជកាលរបស់ព្រះពុទ្ធយ៉តហ្វាឬរាមាទី១(១៧៨២គ.ស..-១៨០៩នៃ គ.ស..) រហូតដល់រជ្ជកាលរបស់ស្តេចមង្សុតឬរាមាទី៤(១៨៥១គ.ស.-១៨៦៨គ.ស..)។រីឯខេត្តបាត់ដំបង សៀមរាបនិងស៊ីសុផុន សៀមបាន បន្តរហូតដល់ឆ្នាំ១៩០៧គ.ស. ទើបរួចផុតពីអាណានិគមសៀម។

សន្ធិសញ្ញានៃឆ្នាំ១៨៦៧ គ.ស. បានបង្កើតឡើងនូវស្ថានភាពអស្ថិរភាពមួយ និង បាននាំឱ្យមានការ តវ៉ាដ៏ផ្ទួនៗ ជានិច្ចជាកាលរបស់ព្រះបាទនរោត្តម។ គឺដោយហេតុនេះហើយ បានជាការងារកំណត់ព្រំដែន ខ្មែរ-សៀមដែលបានចាប់ ផ្តើមនៅឆ្នាំ១៨៦៨គ.ស. នោះគឺ នៅក្នុងបរិយាកាសមួយដែលតានតឹង។ បញ្ហាគឺ កាន់តែពិបាកខ្លាំងឡើងថែមទៀត ដោយហេតុថាវាពុំមាន " ព្រំដែនធម្មជាតិ" ទេរវាងសៀមនឹងប្រទេស កម្ពុជា ចំពោះអ្វីដែលពាក់ព័ន្ធ (គឺក្រសួងកងទ័ពជើងទឹកអាណានិគមបារាំងនិងក្រសួងការបរទេសសៀម) ជាដំបូងបានស្នើឡើងនូវការបែងចែកបឹងទន្លេសាបជាពីរ ហើយក្រោយពីការជជែកគ្នាច្រើនលើកច្រើនសា មក **ព្រះចៅអធិរាជរបស់ប្រទេសបារាំង និងស្តេច រាមាទី៥ របស់សៀមបានឡាយព្រះហស្តលើមាត្រាបន្ថែម មួយក្នុងសន្ធិសញ្ញា ឆ្នាំ ១៨៦៧គ.ស.។** ការឡាយ ព្រះហស្តលេខាបានប្រព្រឹត្តទៅនៅទីក្រុងប៉ែរនគរ នាថ្ងៃទី ១៤ ខែកក្កដាឆ្នាំ១៨៧០គ.ស.។ ហេតុការណ៍នេះមានអត្ថន័យ ជាពិសេសគឺថា ការធ្វើនាវាចរនៅទីនោះនឹង រួចផុតពី ការដកហូតពន្ធដារគ្រប់ប្រភេទ។ក្រោយពីការឡាយព្រះហស្តលេខាលើមាត្រានោះមក បញ្ហាថ្មីទៀត បានចោទឡើង ពីព្រោះពួកសៀមបានប្រាថ្នាចង់បានសិទ្ធិលើបណ្តាខេត្តខាងជើងគឺ ម្លូព្រៃ និងទន្លេ រពៅ។ ខេត្តទាំងពីរនេះស្ថិតនៅតាមព្រំប្រទល់បច្ចុប្បន្ននៃប្រទេសលាវនោះ ត្រូវបានកាន់កាប់ដោយពួកសៀម នៅឆ្នាំ ១៨១៣ គ.ស. ការកាន់កាប់គឺបណ្តោះអាសន្នទេ ក៏ប៉ុន្តែ នៅក្នុងរាជ្យរបស់ព្រះបាទអង្គដួង ខេត្តទាំងពីរនោះ ត្រូវបាន ផ្តាច់ជាថ្មីទៀតទៅឱ្យសៀមដោយមន្ត្រីខ្មែរដែលគ្រប់គ្រង។ ដោយហេតុនេះបានជាការងារកំណត់ ព្រំដែននៅក្នុងតំបន់នោះត្រូវបានអាក់ខានទៅ។អ្វីដែលពាក់ព័ន្ធនឹងព្រំដែននៃប្រទេសកម្ពុជាជាមួយនឹងខេត្ត បាត់ដំបង និងខេត្តសៀមរាបនោះវាត្រូវបាន កំណត់ដោយត្រើយនៃផ្លូវទឹកពីរគឺៈ ខាងលិចព្រែកស្វាយដូនកែវ (ដែលស្ថិតនៅពាក់កណ្តាល ផ្លូវរវាងពោធិសាត់ និង បាត់ដំបង) និងនៅខាងកើតគឺ ព្រែកកំពង់ចាម។

នៅក្នុងឆ្នាំ ១៨៧១គ.ស. ទំនាក់ទំនងសៀម-បារាំងបានឡើងតានតឹង។ ពួកសៀម ដែលត្រូវបាន លើកទឹកចិត្តដោយកុងស៊ុល នៃចក្រភពអង់គ្លេស និង របស់ប្រទេសអាឡឺម៉ង់ប្រចាំនៅក្រុងបាងកកនោះបាន ប្រមូលផ្តុំកងទ័ពនៅតាមព្រំប្រទល់ខ្មែរ (នៅខែមីនា ឆ្នាំ ១៨៧១គ.ស.) ។ អំពីរឿងរ៉ាវនេះ វាលេចចេញថា

ប្រទេសសៀមនៅតែចចេសចាត់ទុកព្រះបាទនរោត្តម ថាជារណបរបស់ខ្លួន ហើយថាសង្គ្រាម រវាងបារាំងនឹងព្រុស (អាឡឺម៉ង់) បានធ្វើឱ្យរដ្ឋាភិបាលក្រុងបាងកកគិតថា ៖ "ប្រទេសបារាំងនឹង ធ្លាក់ឋានៈពីប្រជាជាតិដែលធំជាងគេហើយ"។នៅក្នុងបណ្ដាឆ្នាំបន្តៗ មកទៀត ឥទ្ធិពលរបស់អង់គ្លេសទៅលើព្រះរាជវាំងរបស់យុវក្សត្ររាមាទី៥របស់សៀមចេះតែមានតទៅទៀតដែលបណ្ដាលឱ្យរដ្ឋាភិបាលបារាំងព្រួយបារម្ភជាខ្លាំងតែងតែខ្វល់ខ្វាយអំពីតុល្យភាពនៃឥទ្ធិពលនៅអាស៊ីភាគអាគ្នេយ៍នោះ។

សរុបមក ដោយហេតុតែពួកអង់គ្លេស និងពួកអាឡឺម៉ង់បានធ្វើការដោយសម្ងាត់ប្រកបទៅ ដោយកលល្បិចផងនោះជាមួយនឹងព្រះរាជវាំងក្រុងបាងកក និងដោយហេតុនៃបញ្ហាព្រំដែនខ្មែរ-សៀម នោះ បានជាទំនាក់ទំនងរវាងរដ្ឋាភិបាលក្រុងភ្នំពេញ "ដែលការពារ" ដោយប្រទេសបារាំងនឹងរដ្ឋាភិបាល ព្រះចៅរាមាទី៥ គឺតានតឹងគួរសមនៅអំឡុងឆ្នាំ១៨៧៦គ.ស.។ គឺនៅក្នុងលក្ខខណ្ឌទាំងនេះដែលមានវត្តមាននេះជាថ្មីរបស់ព្រះអង្គម្ចាស់ស៊ីវត្ថានៅលើទឹកដីកម្ពុជាបានផុសឡើង គឺនៅដើមខែឧសភា ឆ្នាំ ១៨៧៦គ.ស.។ប្រទេសសៀមដែលគេសង្ស័យថាបាន"រៀបចំឆាក" បានប្រកែកថា ខ្លួនមិនមានគំនិតអាក្រក់បែបនេះទេ។ គេបានប្រកាសទៀតថាគេនឹងបញ្ជូនកងទ័ពមួយកងឱ្យដេញតាមចាប់ព្រះអង្គម្ចាស់ស៊ីវត្ថា។ ក៏ប៉ុន្តែ កងទ័ពទាំងនោះមិនបានចាប់ព្រះអង្គម្ចាស់បានទេ។

## ៤. ការវិវត្តរបបអាណាព្យាបាលពីឆ្នាំ១៩00គ.ស.-១៩៤៥គ.ស.

ចាប់ពីដើមសតវត្សរ៍ទី២០ របបអាណាព្យាបាលបារាំង បានឈានចូលក្នុងដំណាក់កាលនៃការអភិវឌ្ឍ ដោយបានធ្វើកំណែទម្រង់លើស្ថាប័នមួយចំនួន ដែលមានស្រាប់ និងបានបង្កើតថ្មីនូវបណ្ដាស្ថាប័នគ្រប់គ្រង់ (រដ្ឋបាល តុលាការ សន្តិសុខ) ស្ថាប័នបណ្ដុះបណ្ដាលបញ្ញាញាណជាតិ (ខាងអបរំគ្រប់ផ្នែក និងគ្រប់កម្រិត) និងស្ថាប័នវប្បធម៌ (សម្រាប់កសាងកិត្យានុភាពជាតិ)។ ជាបន្តបន្ទាប់ដែល ជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍប្រទេសកម្ពុជានាពាក់កណ្ដាលទី១ នៃសតវត្សន៍ទី២០។

### ៤.១. ស្ថាប័នសន្តិសុខ និងសណ្ដាប់ធ្នាប់សង្គម

- រដ្ឋបាល និងយុត្តិធម៌(ឆ្នាំ១៩០៣គ.ស.)នៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩០៣គ.ស. អគ្គទេសាភិបាលឥណ្ឌូចិនបានចេញសេចក្ដីប្រកាស ស្ដីពីការរៀបចំនគរបាលរដ្ឋបាលនិងយុត្តធម៌ និងនគរបាលក្រុងភ្នំពេញ។
- នគរបាលត្រួតពិនិត្យផ្លូវទឹក (១៩០៥គ.ស.) នគរបាលមួយកងទទួលបន្ទុកត្រួតពិនិត្យផ្លូវទឹកនៅក្នុងប្រទេសកម្ពុជាត្រូវបានបង្កើតឡើងតាមរយៈប្រកាសចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩០៥គ.ស.។
- នគរបាលសុខភាពសត្វពាហនៈ (ឆ្នាំ១៩០៨គ.ស.) លោកអគ្គលេខាឥណ្ឌូចិនចេញបញ្ជាឱ្យលោករ៉េស៊ីដង់ជាន់ខ្ពស់អនុវត្តច្បាប់ចុះថ្ងៃទី២១ខែកក្កដា ឆ្នាំ១៨៨១គ.ស. ស្ដីពីនគរបាលសុខភាពសត្វពាហនៈ ដោយតម្រូវឱ្យសម្លាប់សត្វដែលមានជំងឺឆ្លង និង ឱ្យសងតម្លៃ៣/៤នៃតម្លៃសត្វដែលសម្លាប់នោះទៅឱ្យម្ចាស់ដែលជាអ្នកចិញ្ចឹមតាមការគួរ។

## ៤.២. សារៈមន្ទីរជាតិនិងការជួសជុលព្រះរាជវាំង

បារាំងបានសម្ពោធបណ្ណាល័យជាតិនៅឆ្នាំ១៩២៤គ.ស. និង បណ្ណាសារដ្ឋានជាតិនៅឆ្នាំ១៩២៦គ.ស. ដើម្បីតម្កល់ទុកនូវរាល់សៀវភៅ និង ឯកសារផ្សេងៗ។ ក្រៅពីនេះបារាំងក៏បានអភិវឌ្ឍ ស្ថាប័នសាសនាតាមរយៈកិច្ចការផ្សេងៗដូចជា៖

-ការបង្កើតពុទ្ធសាសនបណ្ឌិតនៅឆ្នាំ១៩៣០គ.ស. ពុទ្ធសាសនបណ្ឌិតជាមជ្ឈមណ្ឌលព្រះពុទ្ធសាសនាធំជាងគេនៅក្នុងសហភាពឥណ្ឌូចិននិង មានសាខាមួយនៅកូសាំងស៊ីន និងមួយទៀតនៅប្រទេសឡាវ។ នៅកន្លែងនេះក៏មានក្រុមជំនុំព្រះត្រៃបៃដក (១៩២៩គ.ស.) និងក្រុមជំនុំទំនៀមទម្លាប់ខ្មែរ (១៩៣៤គ.ស.) ផងដែរ។

-សារមន្ទីរជាតិត្រូវចាប់ផ្តើមរៀបចំនៅឆ្នាំ១៩០៥ នៅក្នុងអាគារព្រះបរមរាជវាំងសម្រាប់ព្រះស៊ីសុវត្ថិ។ នៅឆ្នាំ១៩១៤គ.ស. មានការសម្រេចកសាងសារមន្ទីរជាតិនៅទីតាំងបច្ចុប្បន្ន ហើយពិធីសម្ពោធបានប្រព្រឹត្តទៅនៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩២០គ.ស. ក្រោមអធិបតីភាពរបស់សម្តេចព្រះស៊ីសុវត្ថិ និងមានឈ្មោះតាមអគ្គទេសាភិបាលកូសាំស៊ីនថា សារមន្ទីអាល់បែរ សារ៉ូ។ចាប់ពីឆ្នាំ១៩០៤គ.ស. នយោបាយរបស់បារាំងគឺជួយលើកតម្កើងកិត្យានុភាព នៃរាជវង្សឡើងវិញ តាមរយៈការជួសជុលអាគារមួយនៅក្នុងព្របមរាជវាំង នៅដើមរជ្ជកាលព្រះបាទស៊ីសុវត្ថិ (១៩០៤គ.ស.-១៩២៧គ.ស.) ។

## ៤.៣. ការទទួលបានទឹកដីពីសៀមមកវិញ

ចំពោះទឹកដីដែលត្រូវបាត់បង់ទៅក្នុងដៃសៀមនោះ គេដឹងថាក្នុងឆ្នាំ១៩០៤គ.ស. ប៉ុន្មានខែក្រោយដែលព្រះបាទស៊ីសុវត្ថិបានឡើងសោយរាជ្យប្រទេសសៀមបានបង្វិលខេត្តទាំងនោះទៅឱ្យបារាំងហើយបារាំងក៏បានប្រគល់ឱ្យព្រះអង្គវិញនូវខេត្តត្រាច ឬត្រាត កោះកុង មូលព្រៃ និងទន្លេរពៅ ។ នៅពេលជាមួយគ្នានោះ ខេត្តស្ទឹងត្រែងនិងស្រុកសៀមប៉ាងក៏ត្រូវដកហូតពីប្រទេសលាវហើយប្រគល់មកឱ្យព្រះរាជាខ្មែរវិញដែរ។

តាមសន្ធិសញ្ញាថ្ងៃទី ២៣ ខែមីនា ១៩០៧គ.ស. រដ្ឋាភិបាលសៀមបានប្រគល់ឱ្យបារាំងវិញនូវខេត្តបាត់ដំបង សៀមរាប និង ស៊ីសុផុន ។ ប៉ុន្តែបារាំងត្រូវឱ្យជាថ្នូរទៅវិញនូវដែនដី ដាន់ សៃ (Dan-Sai) និងត្រាច ឬ(ត្រាត)។ ខេត្តទាំង៣ខាងលើ បារាំងបានប្រគល់ឱ្យមកខ្មែរវិញ គួរគប្បីជ្រាបថា ការវិលចូលមកក្នុងមាតុភូមិវិញនូវទឹកដីមួយភាគខាងលិចយ៉ាងសំខាន់ដែលត្រូវ បាត់បង់ទៅតាំងពីសម័យពញាអភ័យ ធិបេស បែន(១៧៩៥គ.ស.) ជាជោគជ័យមួយនៃនយោបាយបារាំងនៅប្រទេសកម្ពុជា ដែលមានចារឹកទុកជាអនុស្សាវរីយ៍នៅត្រង់ទិសខាងត្បូងវត្តភ្នំដូនពេញសព្វថ្ងៃ ។ ការទាមទារយកបានទឹកដីនេះមកវិញ គឺធ្វើឡើងក្នុងពេលដែលលោក Armand Fallières (អាមែន ហ្វាលីយែរ)កាន់តំណែងជាប្រធានក្នុងវិស័យហិរញ្ញវត្ថុ គួរគប្បីរំលឹកឡើងវិញថាចាប់តាំងពីឆ្នាំ១៨៩០គ.ស. មកបញ្ជីចំណូលចំណាយលើប្រទេសកម្ពុជាត្រូវកាន់កាប់ដោយហិរញ្ញិកបារាំងម្នាក់ ។

## ៤.៤. កិច្ចអភិរក្សអង្គរ


(រូបភាពអភិរក្សអង្គរ GoogleSearch)

សាលាបារាំងចុងបូព៌ាប្រទេសរបស់ពួកអ្នកប្រាជ្ញបារាំងចាប់ផ្តើមអភិរក្សអង្គរចាប់ពីឆ្នាំ១៩០៤គ.ស. បន្ទាប់អំពីប្រវត្តិសាស្ត្រ បុរាណវិទ្យា និង វប្បធម៌ខ្មែរ ព្រមទាំងចាប់ផ្តើមនូវកិច្ចអភិរក្សអង្គរចាប់ពីឆ្នាំ១៩០៨គ.ស.បន្ទាប់ពីបានទទួលខេត្តបាត់ដំបង សៀមរាប និងសិរីសោភ័ណនៅឆ្នាំ១៩០៧គ.ស.ពីប្រទេសសៀម។ចាប់តាំងពីពេលនោះមក កិច្ចការរបស់សាលាបារាំងចុងបូព៌ាប្រទេសមិនសូវបានផ្តោតទៅលើបណ្តាប្រទេសនៅអាស៊ីចុងបូព៌ា ទេដោយហេតុថា កិច្ចការរបស់ពួកគេបានផ្តោតជាពិសេសលើកិច្ចអភិរក្សតំបន់ប្រាសាទអង្គរ ដែលជាស្ថានីយ៍បុរាណវិទ្យាធំជាងគេលើលោក។ កិច្ចអភិរក្សអង្គរបានបន្តរហូតដល់ដើមទសវត្សរ៍ឆ្នាំ១៩០៧ គ.ស.(បន្ទាប់ពីសង្គ្រាមបានផ្ទុះឡើងនៅកម្ពុជា។មូលហេតុនៃការបាត់បង់វត្ថុបុរាណពីប្រាសាទអង្គរវត្តសៀវភៅ "Angkor's Temples in the Modern Era" ឬ «ប្រាសាទអង្គរវត្តនៅក្នុងសម័យទំនើប» ក៏បានរៀបរាប់ពីមូលហេតុនៃការបាត់បង់វត្ថុបុរាណពីប្រាសាទអង្គរវត្តផងដែរ។ ដោយសារសង្គ្រាម ការរុំព័ទ្ធដោយរុក្ខជាតិ និងការធ្វើសំបុករបស់សត្វប្រចៀវបានធ្វើឱ្យវត្ថុបុរាណជាច្រើនតោននៅប្រាសាទអង្គរវត្តរងការខូចខាត។ ក្រៅពីនេះ វត្ថុបុរាណដ៏មានតម្លៃទាំងនេះ ក៏ត្រូវបានទាហានជើងទឹកបារាំង ម្នាក់ដែលក្រោយមកបានក្លាយខ្លួនជាបុរាណវិទូ គឺលោក Louis Delaporte (ល្វីដឺឡាព័រ)បានដឹកជញ្ជូនពីប្រទេសកម្ពុជាទៅកាន់ប្រទេសបារាំង។ ការដឹកជញ្ជូននេះធ្វើឡើង នៅពេលលោក Louis Delaporte បានចុះមកបំពេញបេសកម្មនៅកម្ពុជាក្នុងឆ្នាំ ១៨៧៣ គ.ស. ក្រោមការគាំទ្រផ្នែកច្បាប់ និងផ្នែកហិរញ្ញវត្ថុរបស់ The Société de Géographie ឬ «សង្គមភូមិសាស្ត្របារាំង»ហើយការជួញដូរវត្ថុបុរាណនៅប្រទេសបារាំង ក៏ជាមូលហេតុសំខាន់មួយទៀតនៅពីក្រោយ ការនាំយកវត្ថុបុរាណនិងរូបចម្លាក់ពីប្រទេសកម្ពុជា ទៅកាន់ប្រទេសបារាំងផងដែរ។ កិច្ចការការដឹកជញ្ជូន វត្ថុបុរាណទម្ងន់រាប់តោន តាមផ្លូវដ៏លំបាក ដោយគ្មានបច្ចេកវិទ្យាទំនើបដូចសម័យបច្ចុប្បន្នរបស់លោក Louis Delaporte ត្រូវគេចាត់គេទុកថាជា «ការដឹកជញ្ជូនដ៏មហិមា» (Superhuman Transport)។ យ៉ាងណាក៏ដោយ លោក John Burgess (ចនប៊ូគេស)បានកត់សម្គាល់ថា ភាគច្រើនប្រជាជនខ្មែរបានធ្វើការការងារធ្ងន់ៗនិង ពិបាកៗនៅក្នុងការដឹកជញ្ជូនខាងលើនេះបើយោងតាមសៀវភៅរបស់លោក John Burgess មូលហេតុចម្បងមួយដែលបារាំងចង់បានរូបចម្លាក់និងវត្ថុបុរាណពីកម្ពុជា ព្រោះបារាំងឃើញថា នៅក្នុងសារមន្ទីរជាតិរបស់ចក្រភពអង់គ្លេសមានការដាក់តាំងបង្ហាញនូវរូបចម្លាក់ Elgin Marbles និង Rosetta Stone។ ហើយរូបចម្លាក់និងវត្ថុបុរាណពីប្រាសាទអង្គរវត្ត គឺជាវត្ថុមានតម្លៃដ៏កម្រដែលអាចឱ្យបារាំងប្រកួតប្រជែងជាមួយអង់គ្លេសបានក្នុងការសំញែងវត្ថុដ៏កម្រ ទាំងនេះបាន។ សៀវភៅនេះបានឱ្យដឹងទៀតថា ក្រៅពីបារាំង រូបចម្លាក់ឬវត្ថុបុរាណនៅក្នុងប្រាសាទបុរាណអង្គរវត្តមួយចំនួនបានបាត់បង់ ដោយសារអ្នកទេសចរបរទេសមួយចំនួនបានលួចយកទៅតាមខ្លួន ខ្លះត្រូវបានអ្នកស្រុកលួច ហើយខ្លះទៀតក៏បានបាត់បង់ក្រោមការត្រួតត្រារបស់កងទ័ពព្រះចៅអធិរាជជប៉ុន ក្នុងឆ្នាំ ១៩៤១គ.ស. ផងដែរ។លោក John Burgess ថាភាគច្រើននៃ

វត្ថុបុរាណកម្រៗ ដែលយើងឃើញនៅ បរិវេណប្រាសាទអង្គរមិនមែនជាវត្ថុបុរាណពិតទេភាគច្រើនសុទ្ធតែជារបស់ធ្វើថ្មីដាក់ជំនួស ហើយរូបចម្លាក់និងវត្ថុបុរាណពិតត្រូវបានគេប្រមូលទុកដើម្បីអភិរក្ស និងការពារដោយសុវត្ថិភាព។

នៅឆ្នាំ១៩៧០គ.ស.-១៩៩៨គ.ស. ប្រទេសខ្មែរបានធ្លាក់ចូលក្នុងភ្នក់ភ្លើងសង្គ្រាមគ្នាឯងរវាងខ្មែរនិងខ្មែរដែលធ្វើឱ្យវត្ថុបុរាណខ្មែរខូចខាតយ៉ាងដំណំ គឺខូចខាតដោយសារគ្រាប់កាំភ្លើងប្រយុទ្ធគ្នា និងការទំលាក់គ្រាប់បែករបស់អាមេរិកកាំងក្នុងឆ្នាំ(១៩៧០-១៩៧៥គ.ស.) ក្រោយមកទៀតបាត់បង់ដោយឈ្មួញទុច្ចរិតលបជីកកកាយវាយបំបាក់បដិមាក នៅតាមប្រាសាទនានា យកទៅលក់ឱ្យថៃនិងយួនស្ទើរតែរលាយអស់។ក្រោយមកទៀតដោយសារប្រជាជនងើបពីរបបប្រល័យពូជសាសន៍មានការខ្វះខាតអត់ឃ្លានក៏នាំគ្នា ជីកកកាយបន្ថែមទៀតយកទៅលក់ឱ្យឈ្មួញគ្រប់ទីតាំងដែលមានប្រាសាទចាស់ៗនិងតាមអង្គនានាដែលបន្សល់ទុកតាំងពីសម័យបុរាណ ក៏មិនសល់ដែរ។ ដោយមិនបានគិតពីផលប្រយោជន៍ជាតិពីតម្លៃនៃ វប្បធ៌មជាតិខ្លួនឯងធ្វើឱ្យប្រទេសជាតិបាត់បង់កេរ្តិ៍ឈ្មោះ។

នៅក្នុងសម័យបារាំងការជួសជុលមានតិចតួចតែបំផ្លាញអស់ច្រើន ទើបមកដល់សេចក្តីប្រកាសព័ត៌មានរបស់អង្គការយូណេស្កូប្រចាំនៅកម្ពុជាបានបញ្ជាក់ថា កិច្ចប្រជុំអន្តរជាតិនេះនឹងផ្តោតលើបញ្ហាបីយ៉ាងសំខាន់ៗ។ តាមការស្ទាបស្ទង់ខាងបុរាណវិទ្យាឥណ្ឌា បានបន្តការស្តារស្ថាដៃលើប្រាសាទនេះរវាងឆ្នាំ១៩៨៦គ.ស. និង១៩៩២គ.ស.។ចាប់តាំងពីឆ្នាំ១៩៩០គ.ស. អង្គរវត្តបានមើលឃើញនូវកិច្ចប្រឹងប្រែងអភិរក្សបន្តនិងការកើនឡើងយ៉ាងខ្លាំងខាងទេសចរណ៍។ប្រាសាទនេះគឺជាផ្នែកនៃទីកន្លែងកេរ្តិ៍ដំណែលពិភពលោករបស់អង្គរ បានបង្កើតឡើងនៅឆ្នាំ១៩៩២ គ.ស. ដែលបានផ្តល់នូវការឱ្យមូលនិធិខ្លះ និងបានជម្រុញចិត្តឱ្យរដ្ឋាភិបាលកម្ពុជាការពារទីកន្លែងនេះ។គម្រោងការអភិរក្សអប្សរាអាល្លឺម៉ង់ កំពុងធ្វើការដើម្បីការពារពួកទេវតានិងចម្លាក់លៀនស្រាលៗដទៃទៀត ដែលតាក់តែងលើប្រាសាទនេះពីការបំផ្លិចបំផ្លាញ។ ការស្ទាបស្ទង់របស់អង្គការនេះបានរកឃើញថាប្រហែល២០% នៃពួកទេវតាស្ថិតនៅក្នុងល័ក្ខខ័ណ្ឌមិនសូវល្អ ជាចម្បងដោយសារសំណឹកធម្មជាតិនិងការយ៉ាប់យ៉ឺនទៅនៃថ្មប៉ុន្តែដោយឡែកផងដែរ ក៏ធ្វើឱ្យមានកិច្ចប្រឹងប្រែងការស្តារឡើងវិញភ្លាមៗផងដែរ។ ការងារផ្សេងៗពាក់ព័ន្ធនឹងការជួសជុល ផ្នែកដែលបានធ្លាក់មួយចំនួនពីរចនាសម្ព័ន្ធសំណង់ និងការបង្ការពីការបាក់ធ្លាក់បន្ថែមទៀត ទីខាងមុខប៉ែកខាងលិចនៃថ្នាក់លើៗ ជាឧទាហរណ៍ត្រូវបានទប់ទ្រដោយការដាក់រន្ទាតាំងពីឆ្នាំ ២០០២គ.ស. កាលណោះក្រុមជប៉ុនមួយបានបង្ហើយការស្តារនូវបណ្ណាល័យខាងជើងនៃវាំងចំណារខាងក្រៅនៅឆ្នាំ២០០៥គ.ស.។មូលនិធិបូជនីយដ្ឋានពិភពលោកបានចាប់ផ្តើមការងារអភិរក្សលើថែវកូរសមុទ្រទឹកដោះនៅឆ្នាំ២០០៨ គ.ស. បន្ទាប់មកជាច្រើនឆ្នាំក្នុងការសិក្សាពីស្ថានភាព។គម្រោងការនេះបានស្តារនូវប្រព័ន្ធប្រក់ដំបូលខ្មែរតាមបែបបុរាណ និងបានដកចេញនូវស៊ីម៉ង់ដែលបានប្រើនៅក្នុងការប៉ុនប៉ងការស្តារ ដំបូងដែលបានជាលទ្ធផលជាតិអំបិលជ្រៀតចូលរចនាសម្ព័ន្ធសំណង់ពីក្រោយចម្លាក់ស្រាល ដែលធ្វើឱ្យខូចពណ៌និងបំផ្លាញផ្ទៃដែលបានឆ្លាក់ហើយ។ ដំណាក់កាលសំខាន់នៃការងារនេះបានបញ្ចប់នៅឆ្នាំ២០១២គ.ស. និងសមាសភាគចុងក្រោយនឹងជាការបន្ថុបឡើងនៃត្រីសូល៍លើដំបូលនៃថែវនេះនៅឆ្នាំ២០១៣គ.ស.។

## ៤.៥. កំណែទម្រង់ផ្នែកក្នុងរបស់បារាំងក្នុងឆ្នាំ១៩១១គ.ស.

នៅឆ្នាំ១៩១១គ.ស.រដ្ឋាភិបាលបារាំងបានធ្វើដំណើរតម្រង់ទៅ សហភាពឥណ្ឌូចិនតាមរយៈក្រិត្យចំនួន៤របស់ប្រធានាធិបតីដែលបានចែងអំពីៈការកំណត់អំណាចរបស់អគ្គទេសាភិបាលឥណ្ឌូចិនការកំណត់សមាសភាពនិងសមត្ថភាពរបស់ក្រុមប្រឹក្សារដ្ឋាភិបាលឥណ្ឌូចិន ការកំណត់អំណាចរបស់ទេសា ភិបាលកូសាំងស៊ីន និង បណ្តារ៉េស៊ីដង់ជាន់ខ្ពស់ (នៅកម្ពុជា អណ្ណាម តុងកឹង និង លាវ) និងការរៀបចំឡើងវិញនូវថវិកាឥណ្ឌូចិន និង ថវិកាតាមរដ្ឋនីមួយៗនៃឥណ្ឌូចិន។ នេះជារបត់មួយយ៉ាងធំនៃគោលនយោបាយគ្រប់គ្រងរបស់បារាំងនៅកម្ពុជា ពីព្រោះរាល់ប្រកាសរបស់លោករ៉េស៊ីដង់ជាន់ខ្ពស់បារាំង នៅក្នុងកម្ពុជា រហូតដល់ទសវត្សរ៏១៩៤០គ.ស. បានផ្អែកលើក្រឹត្យក្រមទាំងនេះ។

ការបង្កើតប្រព័ន្ធ គ្រប់គ្រងរបបអាណានិគមនិយមបារាំងនៅក្នុងប្រទេសកម្ពុជា បានធ្វើឱ្យប្រព័ន្ធគ្រប់គ្រងបែបប្រពៃណីទំនៀមទម្លាប់នៅក្នុងប្រទេសកម្ពុជាប្រែប្រួលទាំងស្រុង ។ ទំនាក់ទំនងទំនិញបានស្ថិតនៅក្នុងស្ថានភាពគ្រប់គ្រងមួយនៅក្នុងចិត្តសាស្ត្រ និងទំនាក់ទំនងសង្គម ស្ថានភាពនៅក្នុងប្រទេសកម្ពុជាលោកForest (ហ្វរ៉េស) បានគូសបញ្ជាក់រួចហើយថា ហាក់ដូចជាមានប្រព័ន្ធពីរទំនាស់នឹងគ្នាបានមកដល់ហើយបានប៉ះទង្គិចគ្នា" ។ដោយសារតែការប៉ះទង្គិចគ្នា សេដ្ឋកិច្ចកសិករហាក់ដូចជាស្ថិតនៅក្នុងស្ថានភាពពីរយ៉ាងគឺស្ថិតនៅក្នុងស្ថានភាព គ្រាន់តែឧបត្ថម្ភខ្លួនឯង ហើយបានចូលទៅក្នុងសេដ្ឋកិច្ចទីផ្សារ ដោយបង្កើតឱ្យមានទំនិញជា អង្ករ និងពោត ។ ។មូលហេតុនៃឥរិយាបថរបស់កសិករខ្មែរបែបនេះ ក៏ដូចជាកសិករនៃប្រទេសដទៃទៀត នៅលើ សកលលោកដែរ លក្ខណៈពិសេសស្ថិតនៅត្រង់រស់នៅក្រោមរបបសេដ្ឋកិច្ចអាណានិគមនិយម ឬមួយយើងអាចនិយាយបានទៀតថាមកពីការទាញយកដោយបង្ខិតបង្ខំ សេដ្ឋកិច្ចកសិករយកមកដាក់ក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។ កសិករជាអ្នកផលិត ដែលធ្វើសកម្មភាពផលិតកម្មនៅក្នុងលក្ខណៈធម្មជាតិការលេចឡើងនូវស្ថានភាពបែបនេះ នៅក្នុងប្រទេសកម្ពុជា នៅពេលដែលលេចឡើងនូវការបង្កើតប្រព័ន្ធកសិកម្ម កសិដ្ឋាន ប្រព័ន្ធមូលធននិយម) ។ ចំពោះប្រព័ន្ធសេដ្ឋកិច្ចកសិកម្មបែបនេះ កសិករខ្មែរពុំបានត្រៀមខ្លួនទុកជាមុនទេ ទាំងនៅលើចិត្តសាស្ត្រ ទាំងនៅលើចក្ខុវិស័យសំភារៈ (អវត្តមានកម្លាំង និងមធ្យោបាយដើម្បីសម្របសម្រួលឱ្យមានស្ថេរភាពសេដ្ឋកិច្ចទីផ្សារ) ។នៅក្នុងខណៈនេះ លទ្ធផលនៅក្នុងការធ្វើកំណែទម្រង់ទៅលើវិស័យកសិកម្ម ការលេចឡើងនៅលើទីផ្សារអន្តរជាតិ នៅក្នុងប្រទេសកម្ពុជាបានបង្កើតឡើងនូវប្រព័ន្ធ"Hybrid"(ហាយព្រីត)ផលិតផលទំនិញធម្មជាតិនៅក្នុងផលិតកម្មកសិកម្ម ដែលបានទទួលជោគជ័យជាងប្រព័ន្ធ ជាប្រពៃណីទំនៀមទម្លាប់ ដោយឈរលើគោលការណ៍ប្រព័ន្ធថ្មីនេះ នៅក្នុងប្រទេសកម្ពុជាបានបង្កើតឡើង សេដ្ឋកិច្ចកសិករយ៉ាងធំធេងដែលធ្វើសកម្មភាពជាលក្ខណៈធម្មជាតិ និងពាក់កណ្តាលធម្មជាតិមានទំនាក់ទំនងផលិតកម្មទំនិញ សម្រាប់ តំរូវការទីផ្សារ ដែលធ្វើឡើង ដើម្បីការរស់នៅយ៉ាងសាមញ្ញមួយប៉ុន្តែស្ថិតក្រោមទ្រង់ទ្រាយឥទ្ធិពលផ្សេងៗនៅក្នុង រង្វង់សេដ្ឋកិច្ចទីផ្សារធ្វើឱ្យគេលក់នូវកសិផល ដែលជាផលិតផលចាំបាច់របស់គេ " ។នៅក្នុងប្រព័ន្ធ Hybrid តែងតែកើតឡើងនូវទំនាស់រវាងកសិករ និងពួកឈ្មួញចងការប្រាក់ បើនិយាយក្នុងទ្រឹស្តីសេដ្ឋកិច្ចវិញ គឺរវាងផលិតកម្មអន់ថយនៅក្នុងទីជនបទ និងអ្នកដែលមានជាងនៅក្នុងប្រព័ន្ធមូលធននិយមទីក្រុង ។ នៅពេលនោះជាក្រឹត្យក្រមនៅក្នុងសេដ្ឋកិច្ចកសិកម្មលេចឡើងនូវដំណើរ វិវត្តនៃភាពខុសគ្នាពីរនៃកម្មសិទ្ធិកសិករនៅតាមទីជនបទលេចឡើងនូវកម្លាំងស៊ីឈ្នួលធ្វើស្រែ ដែល

លេចឡើងជាពិសេសក្នុងស្រទាប់ប្រជាជនក្រីក្រដែលគ្មានដីធ្លីទំនាស់ទាំងនេះបានលេចឡើងនៅក្នុងប្រទេសកម្ពុជាកាន់តែខ្លាំងឡើង បន្ទាប់ពីបារាំងចាកចេញពីប្រទេសកម្ពុជា ឆ្នាំ១៩៥៣ គ.ស.ហើយបានក្លាយទៅជាបញ្ហាមួយយ៉ាងធ្ងន់ប្រឈមមុខនឹងអ្នកកាន់អំណាច។

## ៤.៦. ដំណើរការអភិវឌ្ឍន៍ប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩១១គ.ស.

បន្ទាប់ពីបានធ្វើកំណែទម្រង់ផ្ទៃក្នុងនៅសហភាពឥណ្ឌូចិន បារាំងបានបង្កើតស្ថាប័នបញ្ញាញាណជាតិ និងកិត្យានុភាពជាតិ ដែលជាស្ថាប័នសាធារណៈសម្រាប់បង្កើនសមត្ថភាពធនធានមនុស្សនៅក្នុងប្រទេសកម្ពុជាជាបន្តបន្ទាប់ដូចខាងក្រោម៖

ទីចាត់ការដំបូងនៃការអប់រំចំណេះដឹងទូទៅត្រូវបានបង្កើតឡើងនៅឆ្នាំ១៩១១គ.ស. ដែលជាការចាប់ផ្តើមនូវការអប់រំទៅតាមវិធីសាស្ត្រនិងជាប្រព័ន្ធនៅកម្ពុជា។ មានការអប់រំបីយ៉ាងនៅសម័យនោះគឺ៖

-ការអប់រំផ្លូវការក្នុងសាលាបារាំង-ខ្មែរ អនុវិទ្យាល័យអាណាព្យាបាលដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៨៩៣គ.ស. និង ក្លាយជាសាលាបឋមសិក្សាជាន់ខ្ពស់នៅឆ្នាំ១៩០៥គ.ស. នោះ បានឡើងជាអនុវិទ្យាល័យស៊ីសុវត្ថិនៅឆ្នាំ១៩១១គ.ស. និង បានក្លាយជាវិទ្យាល័យនៅឆ្នាំសិក្សា១៩៣៥គ.ស.-១៩៣៦គ.ស.។ មានគ្រឹះស្ថានឧត្តមសិក្សាពីរនៅឆ្នាំ១៩៤៨គ.ស. គឺវិទ្យាស្ថានជាតិខាងនិតិសាស្ត្រ នយោបាយ និង សេដ្ឋកិច្ច និង សាលាភូមិន្ទវេជ្ជសាស្ត្រ។

-ការអប់រំតាមប្រពៃណីក្នុងសាលាវត្តបែបថ្មី បន្ទាប់ពីមានការបង្កើតសាលាវត្តកែប្រែថ្មីនៅឆ្នាំ១៩០៨ នៅខេត្តកំពង់ចាម មានព្រះរាជប្រកាសចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩១១គ.ស. ដែលតម្រូវរៀនភាសាខ្មែរនៅគ្រប់វត្តអារាមទូទាំងប្រទេស។ ឪពុកម្តាយដែលមានកូនប្រុសគ្រប់អាយុ៨ឆ្នាំត្រូវបញ្ជូនកូនឱ្យទៅរៀននៅសាលាវត្ត។ ចាប់ពីឆ្នាំ១៩១២គ.ស. អ្នកមិនគោរពតាមព្រះរាជប្រកាសនេះត្រូវការពិន័យ។ សាលាវត្តថ្មីមានជោគជ័យពិតប្រាកដនៅខេត្តកំពត ពីឆ្នាំ១៩២៤គ.ស. ដល់ ឆ្នាំ១៩៣០គ.ស. និង មានការអភិវឌ្ឍទូទាំងប្រទេសចាប់ពីឆ្នាំ១៩៣១គ.ស.។

-ការអប់រំបែបសាសនាក្នុងសាលាបាលី ព្រះរាជប្រកាសចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩១៤គ.ស. បានបង្កើតសាលាបាលីនៅភ្នំពេញសម្រាប់បណ្តុះបណ្តាលព្រះសង្ឃខ្មែរនៅក្នុងប្រទេស និង ទប់ស្កាត់មិនឱ្យទៅបន្តការសិក្សានៅឯប្រទេសសៀម។ សាលាបាលីនេះបានក្លាយជា សាលាបាលីជាន់ខ្ពស់នៅឆ្នាំ១៩២២នៃគ.ស. និង ប្រែឈ្មោះមកជាពុទ្ធកវិទ្យាល័យនៅឆ្នាំ១៩៥៥គ.ស.។

-សាលាលិល្បៈខ្មែរ ឬ សាលារចនាត្រូវបានបង្កើតនៅឆ្នាំ១៩១៧គ.ស. ដើម្បីប្រមែប្រមូលសិល្បករខ្មែរទូទាំងប្រទេសឱ្យមកជួយស្តារវិស័យវប្បធម៌ខ្មែរឡើងវិញ។

-សាលាក្រមការសម្រាប់បណ្តុះបណ្តាលមន្ត្រីដែលបានបង្កើតឡើងនៅឆ្នាំ១៩១៤គ.ស.នោះ បានក្លាយជាសាលារដ្ឋបាលតុលាការខ្មែរនៅឆ្នាំ១៩១៧គ.ស. និងបានក្លាយជាវិទ្យាស្ថានជាតិខាងនីតិសាស្ត្រនយោបាន និង សេដ្ឋកិច្ច នៅឆ្នាំ១៩៤៨គ.ស.

-ច្បាប់ស្តីពីការបង្រ្កាបភាពស្រវឹង នៅទីសាធារណៈ ត្រូវបានប្រកាសឱ្យប្រើដោយប្រកាសរបស់អគ្គទេសាភិបាលចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩១៧គ.ស.

-នគរបាលចរាចរ និង បទបញ្ញាស្តីពីការចរាចរនៅប្រទេសកម្ពុជា សម្រាប់រថយន្តដឹកទំនិញ និង ដឹកអ្នកដំណើរត្រូវបានចុះហត្ថលេខានៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩១៩គ.ស.

-រាជការឃុំត្រូវបានបង្កើតឡើងតាមព្រះរាជប្រកាសចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩១៩គ.ស.។

បារាំងបាន កែប្រែប្រព័ន្ធពន្ធដារមួយដែលមានភាពច្បាស់លាស់ នឹងស្ថិតស្ថេរបានជួយដល់ស្ថានភាពសង្គមនៅក្នុងប្រទេស ហិរញ្ញវត្ថុមូលដ្ឋានមានកំណើនដែលផ្តល់លទ្ធភាពអាចដោះស្រាយបញ្ហាបានច្រើន។ ឧទាហរណ៍ នៅឆ្នាំ១៩០០គ.ស. ចំណូលរួមនៅក្នុងខេត្តកំពង់ចាម មានទំហំត្រឹមតែ ២៣ន់ Piastra មកដល់ឆ្នាំ១៩១១គ.ស.មានទំហំរហូតដល់ ៤៥៦៣ន់ Piastra(ពីយ៉ាសត្រា) ដូចគ្នាដែរចំពោះខេត្តព្រៃវែង ការអភិវឌ្ឍប្រទេសកម្ពុជាក្រោមការគ្រប់គ្រង របស់បារាំងបានបង្កើតឡើង នូវការធ្វើកំណែទម្រង់យ៉ាងស៊ីជម្រៅដែលជំរុញឱ្យសង្គមមានដំណើរអភិវឌ្ឍន៍បើយើងប្រៀបធៀបក្នុងដំណាក់កាល ពី២៥ ឆ្នាំមុន ១៨៨៤ គ.ស.-១៩១០គ.ស.រចនាសម្ព័ន្ធសង្គមទាំងអស់ត្រូវបានកែប្រែមុខមាត់ថ្មីទាំងស្រុង។ នៅក្នុងវិស័យដឹកនាំដែលធ្លាប់តែមានភាពអនាធិបតេយ្យ និងអសមត្ថភាពគ្មានប្រសិទ្ធភាពនៃការិយាល័យ មន្ត្រីរាជការត្រូវបានជំនួសដោយរដ្ឋបាលថ្មីរបស់អាណានិគមនិយម ដែលស្ថិតក្រោមការដឹកនាំរបស់រ៉េស៊ីដង់បារាំងនៅរាជធានី និងនៅតាមខេត្ត ។ គេបានបង្កើតប្រព័ន្ធគ្រប់គ្រងយ៉ាងតឹងរ៉ឹងទៅលើសកម្មភាពរបស់មន្ត្រីរាជការ។ ដោយដាក់តួនាទីមុខងាររបៀបរៀបរយច្បាស់លាស់កំណត់ព្រំដែនអភ័យឯកសិទ្ធិរបស់ពួកគេ ក្នុងការប្រើអំណាចរបស់មន្ត្រីប្រមៃប្រមូលភោគផលពីប្រជាជន ដែលមានតាំងពីយូរមកហើយត្រូវបានលុបបំបាត់ចោលដោយសារតែមានកំណែទម្រង់នៅលើប្រព័ន្ធពន្ធដារ ការបង្កើតឡើងនិងការពង្រឹងច្បាប់ កម្មសិទ្ធិលើដីធ្លីនិងការលុបបំបាត់ចោលប្រព័ន្ធទាសភាព នៅក្នុងប្រទេសបានត្រូវប្រែប្រួលរចនាសម្ព័ន្ធដល់ ឫសគល់បានលេចឡើងនៅក្នុងជួរមហាជននូវស្រទាប់ម្ចាស់កម្មសិទ្ធដីតូចៗ ដែលក្នុងនោះបានចេញមកពីស្រទាប់មុនហៅថា អ្នកជា" និងពីស្រទាប់" ខ្ញុំក្រៅ និង " ខ្ញុំក្នុង " ។នៅលើវិស័យចិត្តសាស្ត្រសង្គម ក៏មានការប្រែប្រួលច្រើនណាស់ដែរការបង្កើតឡើងនូវការចុះបញ្ជីដីធ្លីនាំឱ្យ មានការលុបបំបាត់នូវមធ្យោបាយ ជាប្រពៃណីទំនៀមទម្លាប់នៅក្នុងដំណោះស្រាយរវាងម្ចាស់ដីដោយបានបង្កើតឡើងនូវប្រព័ន្ធច្បាប់ ដែលឧបត្ថម្ភដល់ស្ថានភាពសង្គមប្រកប ដោយឯករាជ្យ និងស្ថេរភាព ជាពិសេសសម្រាប់ម្ចាស់ដីតូចៗ ។រាល់បម្រែបម្រួលទាំងនេះ របៀបរៀបរយផ្ទៃក្នុងបាននាំមកនូវអត្ថន័យមួយចំនួន ដែលបន្តិចម្តងៗបានជំរុញឱ្យមានទីផ្សារ នៅកម្ពុជាបានក្លាយទៅជាប្រភព និងជាផ្លូវឱ្យកម្ពុជាចូលរួមនៅក្នុងប្រព័ន្ធពលកម្មអន្តរជាតិ និងនៅក្នុងប្រព័ន្ធទីផ្សារសកល លោក។ប្រព័ន្ធថ្មី នេះបានប្រែក្លាយទៅជាមជ្ឈមណ្ឌលបម្រែបម្រួលទាំងស្រុងនៅក្នុងសង្គម។បើនៅក្នុងអត្ថន័យមួយតូចគឺ "ស្ថាប័នក្នុងស្រុកសម្រាប់ផ្លាស់ប្តូរទំនិញ និងបើជាអត្ថន័យទូលំទូលាយ គឺ"កូនសោរនៃយន្តការប្រព័ន្ធទំនាក់ទំនងសង្គមនៅក្នុងប្រព័ន្ធថ្មីដែលមានមូលដ្ឋានតាំងសម្ភារៈ នៃការរស់នៅរហូតដល់ទ្រង់ ទ្រាយខ្ពស់ជាប្រភពចំណេះដឹងរបស់មនុស្ស" ។ដូចបាននិយាយពីខាងលើរួចទៅហើយ នៅក្នុងសង្គមខ្មែរជាប្រពៃណីទំនៀមទម្លាប់ មានធាតុដែលជាទំនាក់ទំនងនិងទំនិញ គឺនៅក្នុងការលក់ទិញអចលនវត្ថុ ការដាក់

ដីបញ្ចាំ ទន្ទឹមនឹងនេះដែរ ដូចមានការធ្វើជំនួញស្រូវនៅក្នុងទីក្រុង។ ស្ថានភាពបែបនេះបានលេចឡើងនូវទំនាស់រវាងទំនាក់ទំនងប្រព័ន្ធទីផ្សារថ្មីទៅ នឹងប្រព័ន្ធទីផ្សារបែបប្រពៃណី ទំនៀមទម្លាប់នៅក្នុងប្រទេសកម្ពុជាប៉ុន្តែជាធម្មតាទំនាស់នេះតែងតែកើតមានជានិច្ចនៅគ្រប់ទីកន្លែង ។

## ៤.៧. ដំណើរការអភិវឌ្ឍស្ថាប័នរដ្ឋបាលនិងសន្តិសុខឆ្នាំ១៩១១

ដំណើរការអភិវឌ្ឍស្ថាប័នរដ្ឋបាល និងសន្តិសុខចាប់ពីឆ្នាំ១៩២១គ.ស. ការរៀបចំវិស័យរដ្ឋបាលឡើងវិញ ។នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩២១គ.ស. វិស័យរដ្ឋបាលត្រូវបានរៀបចំឡើងវិញតាមរយៈព្រះរាជប្រកាសលេខ១០២ ដោយមានការបង្កើតខ័ណ្ឌនៅចន្លោះស្រុក និង ឃុំ ពោលគឺរដ្ឋបាលថ្នាក់ខេត្តមានខេត្តស្រុកខ័ណ្ឌ ឃុំ។ ប៉ុន្តែគេបានលុបខ័ណ្ឌចេញវិញនៅឆ្នាំ១៩៣៤គ.ស.។

-ការរៀបចំនគរបាលចល័តនៅឈូងសមុទ្រ ជាកិច្ចការរបស់នគរបាលចល័តតាមឈូងសមុទ្រមានដូចជា ការស្វែងរកជនបរទេសដែលគ្មានលិខិតអនុញ្ញាតស្នាក់នៅ នៅតាមឆ្នេរសមុទ្រជាដើម។

-ការបង្កើតនិងការរៀបចំកងជីវពលឃុំ ឬ នគរបាលជនបទកងជីវពលឃុំ និង នគរបាលជនបទ នៅកម្ពុជាត្រូវបានបង្កើតឡើងតាមរយៈព្រះរាជប្រកាសចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩២៥គ.ស.។ កងជីវពលឃុំស្ថិតនៅក្រោមឪវាទអាជ្ញាធរឃុំ ជាពិសេសមេឃុំ និង ក្រោមការត្រួតត្រាពិនិត្យជាអចិន្ត្រៃយ៍ពីចៅហ្វាយខ័ណ្ឌ។ នៅឆ្នាំ១៩២៦គ.ស. កងជីវពលឃុំក្នុងខេត្តទាំង១២មានចំនួន៣៦៤នាក់។

-ការបង្កើតកងជីវពលឃុំនេះ គឺជាវិធានការនគរបាលដើម្បីពង្រឹងសន្តិសុខនៅតាមឃុំក្រោយពីមានឧប្បត្តិហេតុសម្លាប់លោករ៉េស៊ីដង់បាដែស ក្នុងខែមេសា ឆ្នាំ១៩២៥គ.ស. នៅឃុំក្រាំងលាវ ខេត្តកំពង់ឆ្នាំង។

-ការបង្កើតកងនគរបាលខេត្ត វិបត្តិសេដ្ឋកិច្ចពិភពលោកបានផ្ទុះឡើង នៅសហរដ្ឋអាមេរិកនៅឆ្នាំ១៩២៩គ.ស. ហើយបានជះឥទ្ធិពលអវិជ្ជមានដល់ប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៣០គ.ស.។

កម្រិតជីវភាពរស់នៅរបស់ប្រជាជនត្រូវបានធ្លាក់ចុះអសន្តិសុខកើតមានលើផ្ទៃប្រទេស បណ្តាលមកពីការកើនឡើងនៃអំពើរចោរកម្ម។ ក្នុងទិសដៅរក្សាសណ្តាប់ធ្នាប់សាធារណៈ ការពារប្រជាពលរដ្ឋនិងទ្រព្យសម្បត្តិពិនិត្យលើបទល្មើសនិងបទឧក្រិដ្ឋ តាមរកនិងចាប់ខ្លួនពួកចោរ នាំខ្លួនជនជាប់ចោទនិងអ្នកទោស កងនគរបាលខេត្តបង្កើតឡើងគ្រប់ខេត្តនៃប្រទេសកម្ពុជាតាមរយៈព្រះរាជប្រកាសថ្ងៃទី២៧ ខែ មករា ឆ្នាំ១៩៣១គ.ស.។ការបង្កើតកងនគរបាលខេត្តនេះ គឺជាវិធានការនគរបាលថ្មីថ្នាក់ខេត្តមួយទៀតបន្ទាប់ពីការបង្កើតកងជីវពលឃុំពីឆ្នាំ១៩២៥នៃ គ.ស.។

-ការបង្កើតនគរបាលផ្លូវដែកភ្នំពេញ-បាត់ដំបង

នគរបាលផ្លូវដែកភ្នំពេញ និង បាត់ដំបង ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៣១គ.ស. ដើម្បីបង្ក្រាបបទល្មើសដែលប៉ះពាល់ដល់ទ្រព្យសម្បត្តិបុគ្គល និង សណ្តាប់ធ្នាប់សាធារណៈនៅតាមផ្លូវដែក។

-ការបង្កើតកងនគរបាលទន្លេសាបកងនេះត្រូវបានបង្កើតឡើងតាមរយៈ អនុក្រឹត្យរបស់រ៉េស៊ីដង់ជាន់ខ្ពស់ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៣៣គ.ស. និងត្រូវបានកែសម្រួលនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៣៧គ.ស. ក្នុងគោលបំណងជានានូវការត្រួតពិនិត្យ និង ការពារកន្លែងនេសាទនៅបឹងទន្លេសាប។ កងទន្លេសាបមានទីស្នាក់ការនៅក្រគរ (ពោធិ៍សាត់) ដែលបែងចែកជា៥ តំបន់គឺ ក្រគរ (ពោធិ៍សាត់) កំពង់ឆ្នាំង កំពង់ធំ កំពង់ឃ្លាំង (សៀមរាប) និង បាក់ព្រា (បាត់ដំបង)។

-នគរបាលព្រំដែនសៀមកងកម្លាំងមួយនេះ មានតួនាទីត្រួតពិនិត្យ និងរាយការណ៍ពីស្ថានភាពនៅតាមព្រំដែនខ្មែរ-ថៃ។

# ៥. អាណាព្យាបាលចាស់ និងអាណាព្យាបាលថ្មី

## ៥.១. សៀម និងបារាំងក្នុងបរិបទកម្ពុជា

ការទទួលបានទឹកដីពីសៀមមកវិញដោយសារកិច្ចសហការបារាំង-ខ្មែរ ។សៀមបានប្រគល់ទឹកដីមកអោយខ្មែរវិញចាប់ពីឆ្នាំ ១៨៩០គ.ស. ចំនួន ៤ ដំណាក់កាលៈ

-នៅឆ្នាំ១៨៩០គ.ស. តំបន់ខ្ពង់ខាងលើ (ខេត្តមណ្ឌលគីរីសព្វថ្ងៃ)

-នៅឆ្នាំ១៨៩៣គ.ស. ត្រើយខាងកើតទន្លេមេគង្គ (ខេត្តស្ទឹងត្រែង)



( រូបភាពកងទ័ពបារាំង GoogleSearch )

-នៅឆ្នាំ១៩០៤គ.ស. ខេត្តម្លូព្រៃ និង ទន្លេរពៅ ដែលស្ថិតនៅតាមជួរភ្នំដងរែក និង ក្រាត (ត្រាត)ដែលស្ថិតនៅតាមតំបន់ឆ្នេរសមុទ្រ

-នៅឆ្នាំ១៩០៧គ.ស. ខេត្តបាត់ដំបង សៀមរាប និង សិរីសោភ័ណ។

## ៥.២. យួន និងបារាំងក្នុងបរិបទកម្ពុជា

បារាំងបានមកតាំងអាណាព្យាបាលភាព លើប្រទេសខ្មែរ ជាលើកដំបូងតំណាងបារាំងបានចោទជាចំណោទមួយចំពោះអ្នកប្រវត្តិសាស្ត្រ ដែលតែងតែចោទសួរថា តើព្រះរាជាខ្មែរព្រះបាទនរោត្តមទ្រង់បានហៅបារាំងឱ្យមកគ្រប់គ្រងស្រុកខ្មែរ ឬក៏បារាំងបានបង្ខំព្រះអង្គទទួលយកអាណាព្យាបាលភាពរបស់បារាំង តាមឯកសារសៀមបានអះអាងថាបារាំងបានបង្ខំព្រះបាទនរោត្តមឱ្យធ្វើសន្ធិសញ្ញា ដាក់ប្រទេសខ្មែរក្រោមអាណាព្យាបាលភាពរបស់បារាំងប៉ុន្តែបារាំងបានប្រកែកថាមិនបាន ធ្វើការកៀបសង្កត់អ្វីមួយឡើយ ព្រោះថាប្រទេសខ្មែរជាប្រទេសឯករាជ្យហើយ មានសិទ្ធិធ្វើការចរចាតាមប្រយោជន៍របស់ខ្លួន ។ តើរវាងចម្លើយទាំងពីរនេះមួយណាសមហេតុផលជាង ដូច្នេះមានតែធ្វើការសាកល្បង វិនិច្ឆ័យដោយផ្អែកលើព្រឹត្តិការណ៍ដែលបានកើតឡើង ។យើង ក៏អាចដឹងថាព្រះបាទអង្គដួងទ្រង់មានព្រះរាជបំណងចងស្ពានមេត្រីជាមួយមហាអំណាចអឺរ៉ុប

ណាមួយមានបារាំងជាដើមដោយទ្រង់មានសង្ឃឹមថានឹង យកមហិទ្ធិឫទ្ធិមហាអំណាចនោះមករំដោះប្រទេស ព្រះអង្គឱ្យរួចពីក្រញាំយួន និងសៀម ប៉ុន្តែកាលនោះបារាំង មិនបានធ្វើឱ្យព្រះអង្គបានសម្រេចព្រះរាជ បំណង ទេ ។ ក្រោយមកដោយយកលេសថា ស្តេចយួនបានធ្វើទុកបុកម្នេញលើរូបអ្នកផ្សាយសាសនា ជាតិបារាំងបាន វាយយកកំពង់ផែទូរ៉ាន់ (Tourane ) នៅថ្ងៃទី ១ ខែកញ្ញា ឆ្នាំ១៨៥៨គ.ស. រួចវាយយកបាន បន្ទាយព្រៃនគរ ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ១៨៥៩គ.ស. ។ តាមសន្ធិសញ្ញាថ្ងៃទី ៥ ខែកក្កដា ឆ្នាំ ១៨៦២ គ.ស. ស្តេចយួនបាន ទទួលស្គាល់ជាកម្មសិទ្ធិរបស់បារាំងនូវខេត្តមួយចំនួនភាគខាងត្បូង និងកោះត្រឡាចដែល យួនបានកេង ប្រវ័ញ្ចពីខ្មែរ ។ លុះបានចូលនៅជាប្រទេសជិតខាងខ្មែរហើយ ទើបបារាំងចាប់អារម្មណ៍ យ៉ាងខ្លាំងមកលើ ប្រទេសខ្មែរ ។ រាជការអាណានិគមនិយមបារាំងបានជឿថា ទន្លេមេគង្គជាផ្លូវទឹកមួយ សំខាន់ដែលអាចឱ្យពួក គេជ្រៀតចូលក្នុងប្រទេសចិនខាងត្បូងបាន។ ម៉្យាងទៀតគេត្រូវរកមធ្យោបាយ កំចាត់ឱ្យអស់នូវគ្រោះថ្នាក់ ទាំងឡាយដែល គម្រាមគំហែងលើអាណានិគមនិយមថ្មី របស់ពួកគេជាពិសេសពីសំណាក់ប្រទេសសៀម ដែលបានចងសម្ព័ន្ធ ជាមួយអង់គ្លេសនៅក្រោយខ្នង ។ នៅឆ្នាំ១៨៦១គ.ស. ក្រោយពីបែកបន្ទាយព្រៃនគរ ឧត្តមសេនាវី ឆាន័រ ( Charner ) បានបញ្ជូននាយទាហានម្នាក់ឱ្យទៅក្រុង ឧដុង្គចូលគាល់ព្រះរាជាខ្មែរដើម្បី ក្រាបទូលពីជ័យជំនះរបស់បារាំងពីបំណងបារាំងចង់តាំងទីនៅកូសាំងស៊ីន និងពីសេចក្តីសង្ឃឹមថានឹងអាច ទាក់ទងជាមិត្តជាមួយប្រទេសខ្មែរបានងាយស្រួល ។

នៅឆ្នាំ១៨៦២គ.ស. ឧត្តមនាវីត្រីបូណាដ ( Bonnard ) ទេសាភិបាលដែនដីកូសាំងស៊ីនបានធ្វើ ដំណើរមកប្រទេសខ្មែរដោយ ចង់ដឹងពីស្ថានភាពប្រទេសខ្មែរ ជាពិសេសអំពីក្រុមមន្ត្រីបរិវានៅឧដុង្គអំពី សកម្មភាពពាណិជ្ជកម្ម និងពីទំនាក់ទំនងជាមួយប្រទេសសៀម ។ គាត់ក៏បានចូលគាល់ព្រះបាទនរោត្តម ទ្រង់ បានទទួលគាត់យ៉ាងរាក់ទាក់ គាត់បានទៅមើលប្រាសាទអង្គរ និងបានធ្វើដំណើររហូតដល់ល្បាក់ទឹកខោន ។ ពេលត្រឡប់ទៅព្រៃនគរ វិញបូណាដ ( Bonnard ) បានផ្ញើកំណត់ត្រាទៅរដ្ឋមន្ត្រីក្រសួងទ័ពជើងទឹក និង អាណានិគម Chasse Loup Lou Bat និយាយពីសិទ្ធិរបស់បារាំងលើប្រទេសខ្មែរ ។ បើតាមបារាំងមានសិទ្ធិ លូក ដៃចូលក្នុងផ្ទះរបស់ខ្លួន ខ្មែរព្រោះប្រទេសនេះបានទទួលមរតកសិទ្ធិអធិរាជភាពប្រទេសអណ្ណាមមក លើ ខ្មែរ ដោយមធ្យោបាយរៀចរេវមួយ គឺបញ្ជូនដែនដីកូសាំងស៊ីនជាកម្មសិទ្ធិរបស់បារាំង។ ម្យ៉ាងទៀត គាត់បាន រៀបរាប់ដល់ Chasse Loup Lou Bat (ឆេសឡុបឡូបាត់ )ពីការប្រាថ្នារបស់សៀមមកលើប្រទេសខ្មែរ ហើយ គាត់ បានសង្កត់លើការចាំបាច់របស់បារាំងត្រូវតែការពារឯករាជ្យភាព នៃប្រទេសនេះដែលមានទាក់ទងនិង សន្តិសុខនៃដែនកូសាំងស៊ីន ។ នៅឆ្នាំ ១៨៦៣គ.ស. ក្រោយពីបានតែងតាំងជាទេសាភិបាលដែនដីកូសាំង ស៊ីន ហើយឧត្តមនាវី De La Gradiere (ដឺឡាក្រាឌៀរ )បានបញ្ជូនឱ្យអនុនាវីឯក Doudart De Lagree (ឌូដាតដឺឡាគ្រី) ធ្វើដំណើរតាមកប៉ាល់ មកធ្វើការសង្កេតការណ៍ ផ្សេងៗនៅលើប្រទេសខ្មែរដើម្បីផ្តល់ ព័ត៌មានឱ្យជាក់លាក់ ។ លទ្ធផលនៃ បេសកកម្មចុងក្រោយនេះបានបង្ហាញឱ្យឃើញថា សម្តេចនរោត្តមទ្រង់ ចង់មានព្រះទ័យល្អទៅលើ បារាំង ។ ហើយទោះបីមានបញ្ហាយ៉ាងស្មាក់ស្មើរពី សាលលូបលូបាត ( Chasse Loup Lou Bat ) ក្តីក៏ ទេសាភិបាល ក្រាឌៀរ (De La Gradiere)បានធ្វើដំណើរទៅក្រុង ឧដុង្គនៅខែ សីហា ឆ្នាំ ១៨៦៣នៃ គ.ស. ។ បើតាមបារាំង មូលហេតុដែលទេសាភិបាលបារាំងចូលគាល់ព្រះរាជាខ្មែរ ព្រោះតែ ការជ្រៀតជ្រែករបស់ សៀមក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្មែរ ។ ដូច្នេះគឺដើម្បីកម្ចាត់ឱ្យអស់នូវឧបាយកលសម្ងាត់

ទាំងឡាយរបស់ សៀម ដែលអាចគម្រាមកំហែងដល់ជំហររបស់បារាំងលើទឹកដីឥណ្ឌូចិន ដើម្បីបង្កើតអសន្តិសុខនៅព្រំដែនអាណានិគមថ្មី និងដើម្បីត្រួតពិនិត្យមើលនូវដែនដីខាងក្នុងមួយដែលផ្តល់ប្រយោជន៍ច្រើន ។ ទេសាភិបាល ក្រង់ឡេវ ( De La Gradiere ) បានទទួលហេតុផលទាំងនោះសព្វប្រការដល់ព្រះរាជាខ្មែរ ហើយទូលសូមព្រះអង្គព្រមដាក់ប្រទេសខ្មែរឱ្យបារាំងជួយការពារ ។ សម្តេច មីស ( Miche ) ទ្រង់បាន ដាក់គម្រោងសន្ធិសញ្ញាមួយ ហើយទ្រង់បានធ្វើការពិភាក្សាជាមួយព្រះរាជាខ្មែរ ។ នៅថ្ងៃទី ១១ ខែសីហា ឆ្នាំ ១៨៦៣គ.ស. ទេសាភិបាលក្រង់ឡេវ ( De La Gradiere ) បានចុះហត្ថលេខាក្នុងនាមផ្ទាល់ លើសន្ធិសញ្ញាមិត្តភាពការពារ និងពាណិជ្ជកម្មជាមួយសម្តេច នរោត្តមដែលទ្រង់បានទទួលព្រមដោយ ភាពញញើតញញើមជាច្រើន ។

## ៦. អនិក្រមចំនើបកម្មនិទផលទិបាក

### ៦.១. កំណែទម្រង់ពន្ធដារ

បញ្ញត្តិទាក់ទងនឹងពន្ធដារ បានលុបចោលនូវរបបទារពន្ធតាមភាសី លើកលែងតែភាសីខាងអាភៀន និងស្រានាំចេញ ។ ពន្ធមួយចំនួនក៏ត្រូវបានគេលុបចោលដែរ ជាពិសេសពន្ធលើល្បែងស៊ីសងដែលត្រូវគេហាមឃាត់ក្នុង សម័យនោះ ។ កំណែនធ្វើការជូនរដ្ឋត្រូវរក្សាទុកនៅដដែលប៉ុន្តែថេរវេលាត្រូវបន្ថយមកនៅត្រឹម ៩០ ថ្ងៃក្នុងមួយឆ្នាំ ហើយគេអាចយកប្រាក់ទៅបង់បាន ។ ពន្ធលើផលិតផលខ្លះដូចជា ម្លូ ស្លា ម្រេច ស្ករត្នោត បានបន្ធូរបន្ថយ ។

### ៦.២. កំណែទម្រង់រដ្ឋបាល

ព្រះរាជបញ្ញតិថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ១៩០៥គ.ស. បានកំណត់ថាចៅហ្វាយខេត្តត្រូវស្ថិតក្រោមការត្រួតត្រា ពិនិត្យរបស់រាជការអាណាព្យាបាលបារាំងហើយលែងឡើងទៅរដ្ឋមន្ត្រីណាមួយទៀតហើយ។ រាល់កិច្ចការរាជការត្រូវ សិក្សាពិនិត្យដោយ លោកឧកញ៉ាអគ្គមហាសេនា(រដ្ឋមន្ត្រីទី១)រួចហើយត្រូវបញ្ជូនទៅលោករេស៊ីដង់ស៊ុបប៉េរីយ័រពិនិត្យបន្ថែមទៀត។ព្រះរាជបញ្ញតិ ថ្ងៃទី៣ ខែកក្កដា ១៩០៥គ.ស. បានកំណត់នូវតួនាទី និងធម្មការ និងភារកិច្ចរបស់រដ្ឋមន្ត្រីទាំង៥រូបៈ

-ឧកញ៉ាមហាសេនា មានតួនាទីជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងធម្មការ និង ជាអធិបតីនៃគណៈរដ្ឋមន្ត្រី

-ឧកញ៉ាយមរាជមានតួនាទីជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌

-ឧកញ៉ាវាំង មានតួនាទីជារដ្ឋមន្ត្រីទទួលខុសត្រូវកិច្ចការក្នុងវាំង ខាងហិរញ្ញវត្ថុ និងខាងវិចិត្រ សិល្បៈ

-ឧញ៉ាក្រឡាហោម មានតួនាទី ជារដ្ឋមន្ត្រីក្រសួងទ័ពជើងទឹក ក្រសួងពាណិជ្ជកម្ម ឧស្សាហកម្មនឹងកសិកម្ម

-ឧញ៉ាចក្រី មានតួនាទី ជារដ្ឋមន្ត្រី ខាងសង្គ្រាម សាធារណការ និងការសិក្សាសាធារណៈ។

នៅពេលនោះប្រទេស កម្ពុជា គឺជារបបប្រជាធិបតេយ្យផ្តាច់ការ។ ព្រះមហាក្សត្រមានអំណាចនីតិប្រតិបត្តិ នីតិបញ្ញត្តិ និងតុលាការ។ ព្រះអង្គគឺជាម្ចាស់នៃធនធានទាំងអស់របស់ព្រះរាជាណាចក្រ។

ព្រះអង្គសម្រេចព្រះទ័យលើកលែងពន្ធដារព្រះអង្គប្រកាសសង្គ្រាមនិងដឹកនាំកងទ័ព។នៅជិតព្រះ មហាក្សត្រមានសមាជិកព្រះមហាក្សត្រព្រះរាជវង្សផ្សេងៗដែលប្រជែង នៅក្នុង វិធានមួយចំនួននៃការដាក់ចំនួននៃការដឹកនាំរដ្ឋាភិបាលរបស់ព្រះរាជាណាចក្រ ដោយរាល់តាមលំដាប់ឋានានុក្រមគឺមានៈ

-ឧបយុវរាជឬស្តេចដែលបានដាក់រាជ្យ ស័ក្តិយសនេះពន្យល់បានដោយហេតុការណ៍ថា ប្រទេសកម្ពុជាមិនបានស្គាល់នូវប្រព័ន្ធតឹងរឹង នៃការបន្តវេនដូចជាវាមាននៅក្នុងរបបរាជាធិបតេយ្យបែប បស្ចឹម ប្រទេសនិងជាពិសេសនៅក្នុងរាជាធិបតេយ្យបារាំង ដែលភេទប្រុសបន្តវេនគ្នាពីឪពុកទៅកូន តាមលំដាប់ជេដ្ឋភាព(ភាពជាច្បង) នោះ។ ចាប់ពីពេលនោះ មកបីតារបស់ស្តេចមានងារជាឧបយុវរាជ។ នៅឆ្នាំ១៨៦៣គ.ស. ស័ក្តិយសនេះ គឺបាននៅទំនេរព្រះបាទនរោត្តមបានឡើងលើរាជបល្ល័ង្ករបស់បីតារបស់ព្រះអង្គ។

-ឧបរាជ ស័ក្តិយសគឺត្រូវបានទៅព្រះរាមច្បងរបស់ព្រះមហាក្សត្រ ឧបរាជគឺជាអ្នកស្នងមរតកដោយគិតសព្វគ្រប់ទៅរបបរាជាធិបតេយ្យកម្ពុជាគឺ ជារាជធិបតេយ្យមួយដែលជ្រើសតាំងច្រើនជាងការជ្រើសរើសព្រះមហាក្សត្របានធ្វើឡើងដោយពួកអ្នកធំៗជាងគេនៃព្រះរាជាណាចក្រនៅក្នុងចំណោមព្រះរាជវង្សានុវង្ស។

-ព្រះវររាជនី (គឺជាព្រះរាជាមាតារបស់ព្រះមហាក្សត្រ) ឧបរាជនិងព្រះវររាជនីព្រះអង្គមានដី ព្រះកេរ្តិ៍ដល់ទីរួមខេត្តមួយចំនួនដែលទ្រង់ហូតពន្ធដារ និងគ្រប់គ្រងពេញដោយអធិតេយ្យ។ ដោយសារការជួយខ្នះខ្នែងរបស់មន្ត្រីទាំងឡាយ(មន្ត្រីទាំងឡាយដែលលើកកម្ពស់ដោយសារសម្តេចអង្គ) បង្កើតបានជាអង្គមួយដែលមាននាមថា"សម្រាប់"។ គេកត់ត្រាថានៅក្នុងអត្ថបទទាំងឡាយនៃសតវត្សទី១៩ ពាក្យ"សម្រាប់"គឺមានន័យមិនត្រឹមតែចំពោះអង្គ ដែលរួមផ្សំដោយមន្ត្រីដែលមានងារស័ក្តិសមពីសម្តេចមួយអង្គប៉ុណ្ណោះទេ ប៉ុន្តែក៏មានដីព្រះកេរ្តិ៍របស់ព្រះឧបរាជ និង របស់ព្រះវររាជនីផងដែរ។ "សម្រាប់" ផ្សេងៗដែលក្នុងន័យជាអង្គ រួមផ្សំដោយមន្ត្រីទាំងឡាយត្រូវបានញែកចេញពីគ្នាដោយសារឈ្មោះដែលកំណត់ជាលេខ រៀងតាមភាសាបាលីគឺៈ

-សម្រាប់ឯកៈ ដែលរួមមានមន្ត្រីដែលតែងតាំងដោយព្រះមហាក្សត្រឬប្រតិភូរបស់ព្រះអង្គ

-សម្រាប់ទោះ គឺរួមមានបណ្តាមន្ត្រីដែលអាស្រ័យដោយឧបរាជ ។ ទោះបីជាតំណែង ឧបយុវរាជពុំមានក្តីក៏" សម្រាប់" នៅតែស្ថិតនៅដែរ។

-សម្រាប់ត្រីៈ គឺជាសម្រាប់ដែលមន្ត្រីទាំងឡាយ
អាស្រ័យទៅនឹងឧបរាជ

-សម្រាប់ចត្វាៈ ដែលមន្ត្រីទាំងឡាយអាស្រ័យទៅនឹងព្រះវររាជនី។

## ៦.៣. កំណែទម្រង់សង្គមកម្ពុជា

ស្ថានភាពសង្គមរបស់កម្ពុជា នៅពាក់កណ្តាលសតវត្សទី១៩គឺងាយនឹងពិពណ៌។ក្រុមសង្គមធំៗនៃមនុស្សអ្នកធំជាមួយក្រុមភាគតិចនៃមន្ត្រី និង មួយក្រុមទៀត គឺមហាជននៃប្រជាកសិករដែលត្រូវបានជិះជាន់ដោយក្រុមអ្នកធំ។ គួរជឿដែលថាប្រជាកសិករនៅពេលនោះជាង ៩០% នៃប្រជាជនសរុបរបស់ប្រទេសកម្ពុជា ទើបនឹងមានពន្លកទាំងឡាយរបស់



(សង្គមខ្មែរសម័យបារាំង GoogleSearch)

ភូមិ។នៅក្នុងលក្ខខណ្ឌទាំងនោះ គឺវាពុំមានទេ នូវវណ្ណៈ កណ្ដាលនោះ។ យ៉ាងច្រើនណាស់ វណ្ណៈកណ្ដាលនោះត្រូវតាង ដោយធាតុទាំងឡាយ ដែលមានប្រភពជាបរទេស ដូចជា ឥណ្ឌាហើយ ជាពិសេសនោះគឺ ចិន ដែលពួកគេមានរួចមកហើយនូវផ្ដាច់មុខលើមុខរបរជំនួញនោះ ។ ក៏ប៉ុន្តែនៅក្បែរពួក អ្នកជា គឺមានពួកទាសករដែលមានចំនួនច្រើនខ្លាំងណាស់។

**អំពីបញ្ហានៃទាសភាព** ពួកទាសករស្ថិតនៅក្នុងប្រភេទធំៗបី ទៅតាមប្រភពរបស់ពួកគេៈដំបូងគឺមានទាសករមួយជីវិតរបស់រដ្ឋាភិបាលដែលហៅថា "អ្នកងារ" ។ បានជាធ្លាក់ដល់ ថ្នាក់នេះដោយសារពួកគាត់ ឬ បុព្វការីជនរបស់ពួកគាត់បានប្រព្រឹត្តិបទឧក្រិដ្ឋមួយដល់សង្គមប៉ុណ្ណោះ ក៏ប៉ុន្តែវាឆ្លុះបញ្ចាំងយ៉ាងស្តែងអំពីតថភាពសង្គម។ពួក"អ្នកងារ"ទាំងនេះពុំមានមធ្យោបាយណាមួយដើម្បីរំដោះខ្លួនឡើយ ហើយជំនាន់ជាច្រើនរបស់ពួកគាត់ត្រូវបានបន្តគ្នា ដែលពុំបាននាំមកនូវភាពប្រសើរណាមួយទាល់តែសោះ ចំពោះល័ក្ខខ័ណ្ឌរបស់ពួកគាត់។ ពីឪពុកមកកូន ពីម្ដាយមកកូនស្រី សមាជិកទាំងឡាយនៃគ្រួសារមួយបានទទួល រងភាពខ្ញុំគេយ៉ាងធ្ងន់ធ្ងរបំផុត ដោយវែកពុននូវ ការទទួលខុសត្រូវ ចំពោះកំហុសដែលពួកគាត់មិនបាន ប្រព្រឹត្តិដោយខ្លួនឯងសោះ ហើយជាញឹកញាប់ ដែលគ្មាននរណានឹកចងចាំ អំពីទោសកំហុសនោះទៀតផង ។មួយចំណែកគឺមានពួកទាសករដោយសារបំណុល" ។ ព្រោះថា កាលណានរណាម្នាក់ខ្ចី បំណុលគេ ហើយដែលគាត់មិនអាចសងបាននោះ គាត់ក្លាយជាទាសករ របស់ម្ចាស់បំណុល។ ម៉្យាងទៀត កូនបំណុលដែលគ្មានប្រាក់សង នៅតែស្ថិតនៅក្នុងទាសភាពជាអន្តរកាល គឺព្រោះផលនៃការងាររបស់ពួក គាត់មិនអាចយកមកដោះរួច នូវចំនួនប្រាក់ដែល សងនោះឡើយ។ ម៉្យាងទៀតសមាជិកទាំងអស់របស់ គ្រួសារពួកគាត់គឺជាម្ចាស់ បំណុល ដែលគេអាចខណ្ឌពីគ្នា នឹងអាចលក់ទៅទៀត។ទីបញ្ចប់គឺវាមាន" ពួកកំរោល" ដែលគេចាប់បាននៅក្នុងតំបន់នៃទន្លេខាងលើ នៅពេលវាយប្រយុទ្ធគ្នាចាញ់។ ការប្រតិបត្តិនេះ ពុំមានជួបនឹងការរារាំងណាមួយឡើយហើយពួកស្ត្រី និង ពួកកុមារ ត្រូវបានគេលក់ឡាយឡុង។ គេក៏ត្រូវកត់សំគាល់ផងដែរថា មានឪពុក ម្ដាយជាច្រើនណាស់ ដោយសារតែគាត់ក្រីក្រ ពុំមានប្រាក់នោះ គឺអាចលក់កូនរបស់ពួកគាត់ ជាពិសេសនោះគឺកូនស្រី។ ក៏ប៉ុន្តែ តើទំហំនៃបញ្ហាសង្គមមានប៉ុនណាតាមលោក Collard(កូលឡាដ) (ក្នុងសៀវភៅ " Cambodgiers, Paris, 1925" គឺថាប្រជាជនមួយភាគបីគឺ ពាក់ព័ន្ធជាមួយនឹងពីរភាគបីទៀត ។ ក៏ប៉ុន្តែលោក Dou dart de lagre និយាយថាទាសករ៤ម៉ឺននាក់ សម្រាប់ប្រជាជន សរុប៦សែននាក់។ ក៏ប៉ុន្តែគេមិន ត្រូវនឹកស្មានថា វាសនារបស់ទាសករទាំងនោះដូចគ្នានឹងរបស់ទាសករ រ៉ូម៉ាំង ឬ របស់ទាសករស្បែកខ្មៅនៅសហរដ្ឋអាមេរិក នៅសម័យកាល ដូចគ្នានោះទេ។ គឺវាគួរឱ្យជឿច្រើនផង ដែរថា នៅក្នុងការប្រតិបត្តិពួក ទាសករមានវាសនា ប្លែកតែបន្តិចទេអំពីវាសនារបស់ អ្នកបំរើ នៅតាម គេហដ្ឋាន។ ភាពខុសគ្នាធំរវាង ទាសករ នឹងអ្នកបំរើនៅតាមគេហដ្ឋាន ស្ថិតនៅត្រង់ហេតុ ការណ៍ថា ពួកទាសករពុំមានសិទ្ធិចាកចេញអំពីម្ចាស់របស់ពួកគេឡើយ ហើយម្ចាស់អាចលក់ពួកគេបាន។ ជាទូទៅ ពួកទាសករ គឺជាកម្មករ ក្រៅអំពីការងារនៅគេហដ្ឋាននោះ គឺនៅនឹងដីរបស់ម្ចាស់ពួកគេ។

-បញ្ហាសង្គមកម្ពុជាក្នុងសម័យអាណាព្យាបាលបារាំង

-ប្រទេសកម្ពុជាកើតមានបញ្ហាចោទយ៉ាងធ្ងន់ធ្ងរខាងសង្គម និង នយោបាយ ដូចជា បញ្ហាអនក្ខរភាព បញ្ហាអសន្តិសុខ បញ្ហាធក់ប្លន់ បញ្ហាជម្ងឺ។

**-បញ្ហាអនក្ខរភាព** ភាពក្រីក្រជាមូលហេតុនៃបញ្ហាអនក្ខរភាព ។ ទាំងនៅជនបទ និង ទីក្រុង កុមារខ្លះមិនបានចូលសាលារៀន កុមារខ្លះទៀតចូលរៀនបានមួយរយៈពេល ហើយត្រូវបោះបង់ចោលសាលា ។ កុមារទាំងនេះ ជាកូនអ្នកក្រីក្រ ដែលត្រូវធ្វើការងារខាង កសិកម្ម ពាណិជ្ជកម្ម ឬ សិប្បកម្ម ដើម្បីជួយដោះស្រាយជីវភាពគ្រួសារ ។ កុមារចាប់ពីអាយុ ៦ឆ្នាំឡើង មិនបានចូលរៀននៅសាលារៀនមានប្រមាណ ២៧.៣% ហើយចំនួនអនក្ខរភាពចាប់ពី អាយុ ១៥ឆ្នាំឡើងទៅមានប្រមាណ ៣៤.៧% ។

-អត្រារួមចំណែក គឺជាភាគរយនៃប្រជាជនសកម្ម ធៀបនិងប្រជាជនសរុបចាប់ពីអាយុ៧ឆ្នាំឡើងទៅ អត្រារួមចំណែកក្នុងសកម្មភាពសេដ្ឋកិច្ចនៃស្ត្រីក្នុងជនបទមានកម្រិតខ្ពស់ណាស់ ៦១% ជាពិសេស ចំពោះក្រុមអាយុ ២០-៥៤ឆ្នាំ ។ ដូចនេះស្ត្រីចូលរួមយ៉ាងសកម្មក្នុងសកម្មភាពកសិកម្ម ។

-ឥឡូវនេះបើគេពិនិត្យលើអត្រារួមចំណែកតាមអាយុផ្សេងៗ ចាប់ពី៧ ឆ្នាំឡើងទៅគេឃើញថា អត្រារួមចំណែកទាប ចំពោះក្រុមអាយុ ៧-១៤ឆ្នាំ ហើយក៏កើនយ៉ាងលឿនរហូតដល់ក្រុមអាយុ ៤៥-៤៩ឆ្នាំ ជាទូទៅអត្រារួមចំណែកថយចុះ ចំពោះក្រុមអាយុ ៧-២៩ឆ្នាំ នៅពេលដែលលទ្ធភាពចូលរៀន និង ទទួលការបណ្តុះបណ្តាលកើនឡើង ។

**-ការងារកុមារ** បញ្ហាមួយក្នុងចំណោមបញ្ហាចំបងៗ ដែលប្រទេសកម្ពុជាត្រូវប្រឈមមុខ គឺ ចំនួនកុមារដ៏ច្រើនដែលបម្រើការងារ ។ ជាមួយគ្នានេះ កុមារ និង យុវជនចាប់ពីអាយុ ៧-១៧ ឆ្នាំប្រកបការងារនៅតាមកសិដ្ឋាន គ្រួសារ និង សហគ្រាសឯកជន ដើម្បីបានលុយជួយគ្រួសារ ។

**-ក្រុមទន់**ខ្សោយ**ដោយ**សង្គ្រាម និង នយោបាយក្នុងប្រទេសកម្ពុជា បានធ្វើឱ្យមានផលវិបាកដល់ប្រជាជន។ ទំនាក់ទំនងទាំងនេះ មិនត្រឹមតែបានបង្ខំមនុស្សរាប់ពាន់ ឱ្យចាកចេញពីភូមិកំណើត ឬ ត្រូវគេចចេញពីប្រទេសរបស់ខ្លួន (ជនភៀសខ្លួន)ដើម្បីទៅជ្រកកោននៅប្រទេសផ្សេងៗប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានបន្សល់ទុកនូវស្ត្រី ឯកោរាប់ពាន់នាក់ (ស្ត្រីមេម៉ាយ) និង ជនពិការជាច្រើនរយនាក់ទៀតផង ។

- **ស្ត្រីមេម៉ាយ** នៅប្រទេសកម្ពុជាទូទាំងប្រទេស ក្រោមអាណានិគមបារាំង ស្ត្រីមេម៉ាយមានគ្រប់បណ្តាខេត្ត ដោយសារបាត់បង់ប្តីដោយសារការប្រឆាំងជាមួយបារាំងជាដើមនិងកែនទ័ព ទៅជួយច្បាំងបារាំងនៅក្នុងសង្គ្រាមលោកលើកទី១ ។ នៅជនបទ ស្ត្រីមេម៉ាយបានទទួលការគាំទ្រ ពីគ្រួសារធំដែលមានបុរសជាអ្នករកស៊ីចិញ្ចឹម (កូនប្រុស ឬ កូនប្រសារប្រុស) ។

**-ជនពិការ** សោកនាកម្មមួយ ក្នុងចំណោមសោកនាកម្មជាច្រើន ដែលប្រជាជនកម្ពុជាបានឆ្លងកាត់ក្នុងជម្លោះប្រដាប់អាវុធ ដោយសារសង្គ្រាម បានបន្សល់ទុកជនពិការយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលមានអត្រាខ្ពស់ជាងគេនៅលើពិភពលោក។

-ការផ្លាស់លំនៅនៃប្រជាជនកម្ពុជាក្នុងសម័យអាណាព្យាបាលបារាំងជាចលនាការផ្លាស់លំនៅ ទាំងក្នុងប្រទេស និងក្រៅប្រទេសជាច្រើនដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ទំហំ និងសមាសភាពនៃប្រជាជន។ វិបត្តិការផ្លាស់លំនៅសំខាន់ៗបណ្តាលមកពីសង្គ្រាម ទុរ្ភិក្ស ។ ហើយជនភៀសខ្លួនមួយចំនួនធំ បានតាំងលំនៅជាអចិន្ត្រៃយ៍ក្នុងប្រទេសទី ៣ និង ខ្លះទៀតបានតាំងលំនៅបណ្តោះអាសន្នក្នុងប្រទេសជិតខាង ហើយក៏បានធ្វើមាតុភូមិនិវត្តន៍នៅពេលដែលស្ថានភាពជម្លោះមានស្ថានភាពស្ងប់ស្ងាត់ទៅវិញ ។

**-ការផ្លាស់លំនៅក្នុងស្រុក**នៅប្រទេសកម្ពុជា ក្នុងការគ្រប់គ្រងរបស់បារាំងខ្មែរយើងបានធ្វើការភៀសខ្លួន គេចចេញពីការយាយី ធ្វើទុកបុកម្នេញពីសំណាក់បារាំងដល់ខ្មែរ បានប្រឆាំងបារាំងក្នុងការដាក់អាណា

និគមមកលើប្រទេសកម្ពុជា ។ បារាំងបានសម្លាប់អ្នកតស៊ូ ដែលចង់បានឯករាជ្យ ក្នុងការបះបោរចង់បានសេរីភាព ធ្វើឱ្យប្រជាជន មានការផ្លាស់ប្តូរពីទីកន្លែងមួយទៅទីកន្លែងមួយទៀតឥតឈប់ឈរ ។នៅសម័យដែលបារាំងបានដាក់អាណានិគមមកលើប្រទេសកម្ពុជា គឺ ស្របពេលដែលប្រទេសបារាំងបានជួបនិង សង្គ្រាមលោកលើកទី១ និង សង្គ្រាមលោកលើកទី២ ដែលពេលនោះបារាំង បានកេណ្ឌប្រជាជនខ្មែរឱ្យទៅជួយច្បាំងបារាំង ដែលបានធ្វើឱ្យប្រជាជនកម្ពុជាទទួលរងនូវការបាត់បង់កម្លាំងអភិវឌ្ឍន៍ប្រទេស ជាពិសេសគឺ មានស្ត្រីមេម៉ាយ ដែលបានទទួលបន្ទុកយ៉ាងច្រើននៅក្នុងគ្រួសារ ។

## ៦.៤. កំណែទម្រង់វប្បធម៌


(សាលាវត្តសម័យបារាំង)

ប្រជាជនខ្មែរនាពេលនោះតែងតែបញ្ជូនកូនចៅឱ្យទៅរៀននៅវត្តព្រះពុទ្ធសាសនាដែលជាមជ្ឈមណ្ឌល ដ៏សំខាន់សម្រាប់ការអប់រំ។ប៉ុន្តែគួរឱ្យស្តាយណាស់ ដែលកុមារីមិនត្រូវបានគេអនុញ្ញាតឱ្យចូលទៅសិក្សា ជាមួយកុមារាដោយសារតែបញ្ហាទំនៀម ទម្លាប់លើកលែងតែក្នុងព្រះរាជ ដំណាក់នៃរាជវាំងតែប៉ុណ្ណោះ។ តែទោះជាយ៉ាងនេះក្តី វត្តអារាមនៅតែជាកន្លែងសម្រាប់អប់រំបណ្តុះបណ្តាលដ៏ប្រសើរដែលមាន ព្រះសង្ឃជាគ្រូអាចារ្យសម្រាប់បង្ហាត់បង្រៀន។ ព្រះសង្ឃខ្មែរនាពេលនោះសុទ្ធតែមានសេចក្តីមេត្តាយ៉ាងក្រៃលែងក្នុងការប្រឹងប្រែង បង្ហាត់បង្ហាញកុមារទាំង ឡាយលុះត្រាតែចេះអាន ចេះសរសេរល្មម អាចប្រើការបាន ទើបអនុញ្ញាតឱ្យវិលត្រឡប់មកផ្ទះវិញ ដើម្បីប្រកបអាជីវកម្មតទៅថ្ងៃមុខ ។

នៅសម័យបារាំង ដោយសារតែសាលារៀនទំនើបបារាំងមិនបាន សាយភាយដល់និគមជនបទ ស្រុកភូមិទូទាំងប្រទេស ប្រជាជនខ្មែរនៅតែបញ្ជូនកូនចៅឱ្យទៅសិក្សានៅតាមវត្តដដែល តែសាលាវត្តនេះមានលក្ខណៈខុសពីមុន ដោយត្រូវបានបារាំងបំពាក់នូវគរុកោសល្យថ្មីបែបបស្ចិមប្រទេសបន្ថែមលើការសិក្សាតាមផ្លូវព្រះធម៌។ ទោះជាយ៉ាងណាក៏ដោយ ក៏សាលាវត្តបែបថ្មីក្នុងគ្រាដំបូង មិនទាន់ទទួលបានការពេញនិយមភ្លាមៗនោះទេ គឺមានន័យថា ការចាប់ផ្តើមថ្មីដែលជាជំហានដំបូងនៃការ កែទម្រង់ការសិក្សានេះ មិនទាន់បានទទួលជោគជ័យភ្លាមៗនោះទេ។[5]

- **ការវិវត្តរបស់សាលាវត្ត** សាលាវត្តត្រូវបានចាត់ទុកជាកន្លែងអប់រំមូលដ្ឋាន នៅតាមភូមិស្រុកនានា ហើយកាលបរិច្ឆេទ នៃការកែប្រែសាលាវត្តប្រហែលជាធ្វើនៅឆ្នាំ១៩០៨គ.ស. គឺរយៈពេលពីរឆ្នាំក្រោយពេលក្រុមប្រឹក្សានៃការសិក្សាបានដាក់ចេញគោលការណ៍នៅឆ្នាំ១៩០៦គ.ស. ថា "នៅប្រទេសកម្ពុជា សាលាវត្តគឺជាមូលដ្ឋានធំនៃការចាត់ចែងផ្នែកសិក្សាធិការ" ។[6]

នៅរវាងឆ្នាំ១៩០៨គ.ស. រេស៊ីដង់បារាំងប្រចាំខេត្តកំពង់ចាមម្នាក់ឈ្មោះលោក បូឌ័ង ព្រមទាំងសហការីរបស់លោកឈ្មោះ មេណោទ្រីយេ បានយកវត្តមួយនៅខេត្តនោះមកបណ្តុះបណ្តាលវិធីសាស្ត្រថ្មីដល់

[5] -មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ ឆ្នាំ១៩៨៥
[6] -ឃឹន សុខ ប្រវត្តិសាស្ត្រខ្មែរឆ្នាំ២០០៣

គ្រូដែលជាព្រះសង្ឃ។ ដំហានដំបូង នេះមិនបានទទួលជោគជ័យនោះទេ ធ្វើឱ្យបារាំងមិនសប្បាយចិត្តនោះឡើយ ហើយថែមទាំងបន្ទោសដល់ព្រះសង្ឃដែលជាគ្រូអាចារ្យទៀតផង។[7]

នៅថ្ងៃទី១១ មេសា ១៩១២គ.ស. មានព្រះរាជបញ្ញត្តិមួយបានកំណត់ចំពោះឪពុកម្តាយគឺ ត្រូវតែបញ្ជូនកូនចៅឱ្យទៅរៀននៅសាលាវត្តបើមិនដូច្នោះទេនឹងត្រូវទទួលពិន័យ ។ តាមព្រះរាជបញ្ញត្តិនេះ បានកំណត់ទៀតថា "ឪពុកម្តាយដែលមិនបញ្ជូនកូនទៅរៀននៅសាលាវត្តដោយ ពុំមានបុព្វហេតុត្រឹមត្រូវ គឺត្រូវជាប់ពិន័យជាប្រាក់១ព្យ៉ាស(១រៀល)នៅលើកទី១ ហើយប្រាក់ពិន័យនេះនឹងត្រូវឡើង ទៅជា២ព្យ៉ាស បើនៅតែមិនព្រមធ្វើតាមព្រះរាជបញ្ញត្តិ"។[8] នៅពេលក្រោយមកក៏មាន សារាចរមួយឱ្យអភិបាលខេត្តចេញទៅផ្សព្វផ្សាយជំរុញបន្ថែមស្តីពី ការសិក្សានេះ។ កាលណាប្រជាជននៅតែមិនព្រមបញ្ជូនកូនឱ្យទៅរៀនទៀតនោះ គេត្រូវយកព្រះរាជបញ្ញត្តិមកអនុវត្ត។ ដោយ សារការបរាជ័យលើកទី១នេះហើយ ទើបបារាំងមានគំនិតបង្កើតនូវ សាលាមួយដែលអាចជួយបំពេញ នូវកង្វះខាតនេះបាន។ សាលាអនុវត្តន៍ទី១ត្រូវបានគេបង្កើតឡើង នៅថ្ងៃទី៤ខែមីនាឆ្នាំ១៩២៤គ.ស. នៅខេត្តកំពត។ នៅសាលានេះគេបាននិមន្តព្រះសង្ឃដែលត្រូវមាននាទី បង្រៀន ឱ្យទៅរៀនវិធីសាស្ត្រ គំរូៗនានាដើម្បី យកទៅបង្រៀនបន្តឱ្យសិស្សានុសិស្សនានាដែលទៅ ចូលរៀន នៅសាលាវត្តបែបថ្មី។ ម៉្យាងវិញទៀតវគ្គសិក្សានេះ មានរយៈពេលតែ៩ខែប៉ុណ្ណោះ។ នៅក្នុងរយៈពេលនោះព្រះសង្ឃត្រូវរៀនតាមកម្មវិធីដូចជា រៀនធ្វើសំបុត្រផ្សេងៗ រៀនអាន គិតលេខ និងប្រើប្រាស់រង្វាស់រង្វាល់ រៀនប្រវត្តិសាស្ត្រកម្ពុជា ព្រមទាំងរៀនអំពីវិធីបង្ការរោគនានា។ ហេតុនេះបានជាចំនួនសាលាវត្តបែបទំនើបនេះបាន កើនចំនួនបន្តិច ម្តងៗនៅក្នុងខេត្តកំពត។ ជាក់ស្តែងនៅឆ្នាំ១៩២៤គ.ស. មានសាលាវត្តបែបនេះតែ១ប៉ុណ្ណោះ តែដល់ឆ្នាំ១៩៣០គ.ស. សាលាបែបនេះក៏កើន រហូតដល់ទៅ៥៨កន្លែង។

## ៦.៥. ចលនាជាតិនិយម


(ចលនាជាតិនិយមខ្មែរប្រឆាំនឹងបារាំង)

នៅឆ្នាំ ១៩៣០គ.ស. ចលនាប្រជារាស្ត្របានរួបរួមជាមួយក្រុមដែលមាននិន្នាការខាងកុម្មុយនិស្ត។ បន្ទាប់ពីការមកដល់នៃរបបយោធានិយមជប៉ុន ក្រុមនេះបានក្លាយទៅជារណសិរ្សអ្នកស្នេហាមាតុភូមិខ្មែរ ឬហៅថាខ្មែរឥស្សរៈ។ស្ថានភាពរង្គោះរង្គើខាងសេដ្ឋកិច្ច និងសង្គមនៃប្រទេសផ្តល់ឱ្យរណសិរ្សខ្មែរឥស្សរៈ ពង្រីកមូលដ្ឋាននយោបាយ និងពង្រីកចម្បាំងឈ្លបទៅលើពួកអាណានិគម។ ទោះបីជាមានប្រតិបត្តិការការបង្ក្រាបដ៏សាហាវអំពីកងទ័ពបារាំងក៏ដោយ ក៏កងកម្លាំងខ្មែរឥស្សរៈ បានវាយប្រហារតបវិញធ្វើឱ្យបារាំងខូចខាតយ៉ាងដំណំ។ "ទោះបីជាមានចំណុចមួយចំនួនគ្មានសមភាពជាមួយប្រទេសអាណាព្យាបាល និង ប្រទេសក្រោម អាណាព្យាបាលក៏ដោយ ក៏វាអាចក្លាយជាកម្លាំងមួយក្នុងការរារាំងឥទ្ធិពល និងធ្វើឱ្យ ឥទ្ធិពល សៀមមក លើខ្មែរបានថយចុះ។ មានន័យថា ប្រទេសកម្ពុជាយើង នៅតែបន្ត ការពារផែនទីនៅ

[7] -ជា សោភារី និងហ៊ុយ ស៊ីវង ២០០៧
[8] -ឃីន សុខផ្កាំ ប្រវត្តិសាស្ត្រខ្មែរ២០០៣

លើពិភពលោករហូត មកដល់សព្វថ្ងៃហ្នឹង គឺដោយសារតែវត្តមានរបស់ពួកបារាំង។ ចលនាជាតិនិយមខ្មែរនៅតែស្ងៀមស្ងាត់បើប្រៀបធៀប ក្នុងកំឡុងសម័យការគ្រប់គ្រងរបស់បារាំង ភាគច្រើនដោយសារតែឥទ្ធិពលការអប់រំទន់ខ្សោយ ដែលធ្វើឱ្យ អត្រាចេះអក្សរនៅទាបហើយបានបន្ថយបង្អាក់ ចលនាជាតិនិយមមិនអាចឱ្យមានដូចជាចលនាដែលធ្វើនៅប្រទេសវៀតណាម។ យ៉ាងណាមិញ ចំណោមឥស្សរជនខ្មែរដែលរៀនសូត្រនៅបារាំង ដែលមានគំនិតប្រជាធិបតេយ្យបែបលោកខាងលិច និងការចង់គ្រប់គ្រងខ្លួនឯង ក៏ដូចជាការស្តារឡើងវិញនូវបូជនីយដ្ឋាននានារបស់បារាំងដូចជាអង្គរវត្តបានបង្កើតឱ្យមានអារម្មណ៍មានមោទនភាពនិងធ្វើឱ្យយល់ដឹងអំពីឋានៈជា មហាអំណាចមួយរបស់កម្ពុជាក្នុងអតីតកាល។ ក្នុងការអប់រំរៀនសូត្រ ក៏ធ្លាប់មានការអាក់អន់ចិត្តធំឡើងៗចំណោមពួកនិស្សិតខ្មែរ ដោយសារតែពួកជនជាតិភាគតិចយួន បានកាន់តំណែងកាន់តែធំឡើងៗ។ នៅពេលនោះ ការអាក់អន់ចិត្តដោយសារតែពួកសិស្សនិសិត្សយួនត្រូវបានគេអនុគ្រោះដែលជាហេតុនៅក្នុងញត្តិមួយ ថ្វាយទៅព្រះបាទមុនីវង្សនៅទសវត្សឆ្នាំ១៩៣០គ.ស. ពួកខ្មែរឥស្សរជនចេះដឹងថ្មីៗជាច្រើនបានបញ្ចប់ការសិក្សាផ្នែកប្រវត្តិសាស្ត្រខ្មែរនៅវិទ្យាល័យស៊ីសុវត្ថិឯភ្នំពេញ។សំខាន់ ពួកអ្នកជាតិនិយមភាគច្រើនដំបូងឡើយជាពួកសមាជិកខ្មែរក្រោម ក៏ជាសមាជិកនៃជនជាតិភាគតិចខ្មែរដែលរស់នៅវៀតណាមដែរ។នៅឆ្នាំ១៩៣៦គ.ស. សឺង-ង៉ុកថាញ់ និង ប៉ាច-ឈឿន បានចាប់ផ្តើមចេញផ្សាយដោយកាសែតនគរវត្តដែលជាសារព័ត៌ មានប្រឆាំងអាណានិគមជាភាសាបារាំង ហើយនៅពេលនោះក៏ជាសារព័ត៌មានមួយប្រឆាំងយួនដែរ។វាបានបន្ទោសនយោបាយអាណានិគមបារាំងដោយឥរិយាបថព្រងើយកន្តើយចំពោះអំពើពុករលួយព្រឹទ្ធិកម្មរបស់ខ្លួន (ការចងការអាករ) នៅតាមតំបន់ជនបទនានា ការត្រួតត្រារបស់បរទេសខាងសេដ្ឋកិច្ចហើយនិងបានរិះគន់ផងដែរ ពួកយួនចំពោះចក្រពត្តិនិយមពីអតីតកាលរបស់ខ្លួន និងតំណែងឯកសិទ្ធិនៅឥណ្ឌូចិន។ ចលនាទាមទារឯករាជ្យតូចៗ ជាពិសេសខ្មែរឥស្សរៈ បានចាប់ផ្តើមរីកធំធាត់ឡើងក្នុងឆ្នាំ ១៩៤០ គ.ស. ចំណោមពួកខ្មែរនៅប្រទេសសៀម ដែលពួកគេខ្លាចបារម្ភថាសកម្មភាពរបស់ខ្លួននឹងនាំឱ្យមានការដាក់ទោសទណ្ឌ បើសិនជាពួកគេប្រព្រឹត្តធ្វើនៅក្នុងប្រទេសកំណើតរបស់ខ្លួន។

## ៦.៦. គណបក្សនយោបាយ

នៅឆ្នាំ ១៩៤៦គ.ស. បារាំងបានអនុញ្ញាតឱ្យប្រជាជនខ្មែរបង្កើតគណបក្សនយោបាយ និងប្រារព្ធការបោះឆ្នោតសម្រាប់សភាប្រឹក្សា ដែលនឹងផ្តល់ប្រឹក្សាដល់ព្រះមហាក្សត្រលើសេចក្តីព្រាងរដ្ឋធម្មនុញ្ញរបស់ប្រទេស។ គណបក្សសំខាន់ៗពីរត្រូវបានដឹកនាំ ដោយព្រះអង្គម្ចាស់ក្នុងខ្សែរាជវង្ស។ គណបក្សប្រជាធិបតេយ្យដឹកនាំដោយព្រះអង្គម្ចាស់ (អ្នកអង្គម្ចាស់) ស៊ីសុវត្ថិ-យុត្តិវង្ស ។ កំណែទម្រង់ប្រជាធិបតេយ្យ និងរដ្ឋាភិបាលអាស្រ័យសភា។ អ្នកគាំទ្រគណបក្សនេះគឺជាពួកគ្រូបង្រៀន ពួកមន្ត្រីរាជការក្នុងស្រុក ពួកសមាជិកនៃសមណភេទពុទ្ធសាសនាសកម្មៗខាងនយោបាយ និងអ្នកដទៃៗផ្សេងទៀត ដែលគោលគំនិតរបស់ពួកគេត្រូវរងឥទ្ធិពលយ៉ាងខ្លាំងដោយសារការអំពាវនាវជាតិនិយមនៃ សារព័ត៌មាន "នគរវត្ត" មុនពេលត្រូវបានបិទដោយពួកបារាំងនៅឆ្នាំ ១៩៤២គ.ស.។ ពួកអ្នកប្រជាធិបតេយ្យមួយចំនួនបានពេញចិត្តពេញថ្លើមជាមួយនឹងមធ្យោបាយហិង្សាមួយចំនួនរបស់ខ្មែរឥស្សរៈ និងគណបក្សសេរីនិយម ដែលដឹកនាំដោយព្រះអង្គម្ចាស់នរោត្តម-នរិន្ទដេត (Norodom Norindeth) តំណាងឱ្យចំណាប់អារម្មណ៍នៃពួកឥស្សរជនចាស់ៗនៅតាម

ជនបទ រួមមានពួកម្ចាស់ដីធំៗជាដើម។ ពួកគេចូលចិត្តការបន្តទម្រង់ទំនាក់ទំនងអាណានិគមជាមួយបារាំងដាង ហើយគាំទ្រកំណែទម្រង់ប្រជាធិបតេយ្យសើៗ។ ការបោះឆ្នោតសភាប្រឹក្សាបានប្រារព្ធឡើងនៅខែ កញ្ញា ១៩៤៦ គ.ស. ពួកអ្នកប្រជាធិបតេយ្យបានឈ្នះ ៥០កៅអី ក្នុងចំណោម ៦៧ កៅអី។ជាមួយចំនួនភាគច្រើនដែលមិនប្រែប្រួលក្នុងសភា ពួកអ្នកប្រជាធិបតេយ្យបានព្រាងរដ្ឋធម្មនុញ្ញ យកគំរូតាមច្បាប់រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋបារាំងទីបួន។ អំណាចត្រូវបានប្រមូលផ្តុំនៅក្នុងកណ្តាប់ដៃនៃរដ្ឋសភាជាតិដែលបានបោះឆ្នោតដោយប្រជាជន។ ព្រះមហាក្សត្របានប្រកាសរដ្ឋធម្មនុញ្ញថ្មីដោយស្វាក់ស្ទើរនៅថ្ងៃទី ៦ ឧសភា ១៩៤៧គ.ស កាលណោះបានទទួលស្គាល់ព្រះអង្គត្រឹមជា "ព្រះប្រមុខរដ្ឋក្នុងចិត្ត" បានកាត់បន្ថយទ្រង់ចេញពីលក្ខខណ្ឌនៃព្រះមហាក្សត្រអាស្រ័យរដ្ឋធម្មនុញ្ញ ហើយដែលបានបន្សល់ទុកនូវភាពមិនច្បាស់លាស់នូវទំហំដែលព្រះអង្គអាចដើរតួនាទីសកម្មនៅក្នុងឆាកនយោបាយជាតិ។ ព្រះបាទនរោត្តមសីហនុអាចនឹងបានប្រែភាពមិនច្បាស់លាស់នេះទៅជាគុណសម្បត្តិរបស់ព្រះអង្គនៅប៉ុន្មានឆ្នាំក្រោយមកទៀត។

នៅក្នុងការបោះឆ្នោតសភាជាតិខែ ធ្នូ ឆ្នាំ ១៩៤៧គ.ស. ពួកអ្នកប្រជាធិបតេយ្យបានឈ្នះឆ្នោតចំនួនភាគច្រើនក្រៃលែង។ ទោះបីដូច្នេះក៏ដោយ ក៏មានការខ្វែងគំនិតគ្នានៅខាងក្នុងគណបក្សដែលពុំអាចគ្រប់គ្រងបានឡើយ។ស្ថាបនិករបស់បក្សទ្រង់ស៊ីសុវត្ថិ-យុត្តិវង្សបានសុគតនិងមិនមានអ្នកដឹកនាំមួយណាច្បាស់លាស់ទេដែលលេចធ្លោដើម្បីស្នងតំណែងបន្តពីទ្រង់។ កំឡុងសម័យឆ្នាំ ១៩៤៨គ.ស.- ១៩៤៩គ.ស. ពួកអ្នកប្រជាធិបតេយ្យបានប្រែជារួបរួមគ្នាតែមួយនៅក្នុងការប្រឆាំងទៅ នឹងការតែងច្បាប់ដែលបានគាំទ្រដោយព្រះមហាក្សត្រ រឺក៏ ពួកអ្នកត្រូវចាត់តាំង។ បញ្ហាដ៏សំខាន់មួយគឺបដិសណ្ឋារកិច្ចដើម្បីឯករាជ្យរបស់ព្រះអង្គ នៅក្នុងសហភាពបារាំងដែលបានស្នើសុំសន្ធិសញ្ញាពង្រាង ដែលបានផ្តល់ដោយពួកបារាំងនៅចុងឆ្នាំ១៩៤៨គ.ស. បន្តបន្ទាប់ពីការរំលាយសភាជាតិនៅខែ កញ្ញា ឆ្នាំ១៩៤៩គ.ស. កិច្ចព្រមព្រៀងលើកតិកាសញ្ញាបានរំកិលទៅមុខតាមរយៈការដោះដូរចុតហ្មាយរវាងព្រះបាទនរោត្តមសីហនុនិង រដ្ឋាភិបាលបារាំង។មានប្រសិទ្ធិភាពនៅប៉ុន្មានពីរខែក្រោយមកទៀត ទោះបីជាសច្ចាប័នរបស់សភាជាតិអំពីសន្ធិសញ្ញា មិនមានភាពរឹងមាំម្តងណាក៏ដោយ។

នៅឆ្នាំ ១៩៥១គ.ស. សឺងង៉ុកមិញ ថែមទាំងបានបង្កើតចលនាប្រដាប់អាវុធមួយ ដោយដាក់ឈ្មោះថា សមាគមខ្មែរឥស្សរៈ ទៀតផង ដែលជាហេតុនាំឱ្យមានការភ័ន្តច្រឡំ មិនដឹងមួយណាជាខ្មែរឥស្សរៈកុម្មុយនិស្តនិងមួយជាខ្មែរឥស្សរៈនិយមថៃ។ នៅឆ្នាំដដែលនេះដែរ វៀតណាមបានសម្រេចបំបែកបក្សកុម្មុយនិស្តឥណ្ឌូចិនឱ្យទៅជាបក្សកុម្មុយនិស្តផ្ទាល់របស់ប្រទេសនីមួយៗវិញ។ ក្រុមខ្មែរកុម្មុយនិស្តក៏សម្រេចបង្កើតបក្សកុម្មុយនិស្តផ្ទាល់របស់ខ្លួន ដោយដាក់ឈ្មោះថា បក្សប្រជាជនបដិវត្តន៍ខ្មែរ។ បក្សនេះដឹកនាំដោយគណៈកម្មាធិការមជ្ឈិមបក្សបណ្តោះអាសន្នមួយដែលមាន សឺងង៉ុកមិញ ជាប្រធាន ទូ សាមុត ជាអនុប្រធាន និង សៀវ ហេង ជាអគ្គលេខាធិការ។ ក៏ប៉ុន្តែ ពីឆ្នាំ១៩៥១គ.ស. រហូតដល់ឆ្នាំ១៩៦០គ.ស. ក្រុមខ្មែរកុម្មុយនិស្តមិនបានរៀបចំធ្វើសន្និបាតបង្កើតបក្សជាផ្លូវការទេ ដែលជាហេតុនាំឱ្យបក្សប្រជាជនបដិវត្តន៍ខ្មែរមិនមានភាពឯករាជ្យដាច់ស្រឡះពីបក្សកុម្មុយនិស្តឥណ្ឌូចិន។ សូម្បីតែលក្ខន្តិកៈរបស់បក្សក៏វៀតណាមជាអ្នកសរសេរឱ្យដែរ រួចទើបយកមកបកប្រែជាភាសាខ្មែរ។ ទោះជាយ៉ាងនេះក៏ដោយ គណបក្សប្រជាជនកម្ពុជា ដែលបច្ចុប្បន្នជាគណបក្សកាន់អំណាចនៅកម្ពុជា បានកំណត់យកបក្សប្រជាជនបដិវត្តន៍ខ្មែរថាជាប្រភពដើមរបស់ខ្លួន ហើយកំណត់យកថ្ងៃទី២៨ មិថុនា ឆ្នាំ១៩៥១គ.ស. ថាជាថ្ងៃកំណើតបក្ស។នាថ្ងៃទី១៣ មេសា ឆ្នាំ១៩៤៦

គ.ស. សម្តេចព្រះនរោត្តមសីហនុ បានអនុញ្ញាតឱ្យបង្កើតគណៈនយោបាយនៅកម្ពុជាតាម សំណើរបស់ក្រុមបញ្ញាវន្តត្រឡប់មកពីប្រទេសបារាំង ដែលមានអ្នកអង្គម្ចាស់យុត្តិវង្សជាមេក្រុមដឹកនាំ។ ដើម្បីឱ្យប្រទេសកម្ពុជាមានកំណែទម្រង់ថ្មី ខាងផ្នែកនយោបាយគឺរៀបចំឱ្យមានរដ្ឋធម្មនុញ្ញ។ នាសម័យបោះឆ្នោតជ្រើសរើសសភានៅថ្ងៃទី១ កញ្ញា ឆ្នាំ១៩៤៦គ.ស. គណៈប្រជាធិបតេយ្យបានទទួលជ័យជំនះដោយទទួលបានអាសនៈ ៥០ កន្លែងក្នុងចំណោមអាសនៈ៦៧កន្លែង។ តាមរយៈលទ្ធផលនៃការបោះឆ្នោតនេះ ប្រធានគណបក្សប្រជាធិបតេយ្យគឺអ្នកអង្គម្ចាស់ស៊ីសុវត្ថិយុត្តិវង្ស ត្រូវតែងតាំងដោយព្រះមហាក្សត្រជានាយករដ្ឋមន្ត្រី។ សភាដែលត្រូវបានបង្កើតឡើងដោយការបោះឆ្នោតនេះ ជាសភាធម្មនុញ្ញ គឺទទួលភារកិច្ចតាក់តែងច្បាប់រដ្ឋធម្មនុញ្ញ។រដ្ឋធម្មនុញ្ញនេះត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី៦ ឧសភា ឆ្នាំ១៩៤៧គ.ស.។ ការបោះឆ្នោតជាថ្មីស្របតាមច្បាប់បោះឆ្នោតក្រមលេខ ៣៦៣ ន.ស ចុះថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ១៩៤៧គ.ស. បានប្រព្រឹត្តទៅនាខែធ្នូ ឆ្នាំ ១៩៤៧ គ.ស. គណបក្សប្រជាធិបតេយ្យបាន ទទួលសន្លឹកឆ្នោតច្រើនជាងបក្សសេរីភាព ដឹកនាំដោយព្រះអង្គម្ចាស់នរោត្តមនរិន្ទដេត គឺ៤៤កន្លែងក្នុងចំណោមអាសនៈ៦៥កន្លែង។ គណបក្សប្រជាធិបតេយ្យដែលជាគណបក្សកាន់អំណាចជួបវិបត្តិជាបន្តបន្ទាប់ដូចជា៖

-មេដឹកនាំគឺអ្នកអង្គម្ចាស់យុត្តិវង្សទទួលមរណភាព។

-ចាប់ពីឆ្នាំ ១៩៤៨ គ. ស វិបត្តិស្តែងចេញជាទំនាស់ពីរគឺ៖

ទំនាក់ទំនងរដ្ឋាភិបាល និងសភាមិនល្អដោយតំណាងរាស្ត្រច្រើនរំលោភលើការងារប្រតិបត្តិ និងបានធ្វើឱ្យសកម្មភាពរដ្ឋាភិបាល ចុះខ្សោយដោយសារអន្តរាគមន៍នានា

ទំនាក់ទំនងរវាងគណៈបក្សប្រជាធិបតេយ្យនិងព្រះមហាក្សត្រ បង្កើតទំនាស់ដែលធ្វើឱ្យឆាកនយោបាយត្រូវអាប់អួរ។ការបោះឆ្នោត នៅខែកញ្ញា ឆ្នាំ១៩៥១គ.ស. គណបក្សប្រជាធិបតេយ្យបានទទួលជ័យជំនះដោយសារសមាជិកភាគច្រើននៅក្នុងរដ្ឋសភា។ ថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៥១គ.ស. រដ្ឋាភិបាលថ្មីត្រូវបានសភាអនុម័ត។សមាសភាពនៃរាជរដ្ឋាភិបាលនេះសុទ្ធតែជាសមាជិក នៃគណៈបក្សប្រជាធិបតេយ្យទាំងអស់ ចាប់ពី ខែមិថុនា ឆ្នាំ ១៩៥២គ.ស. មកវិបត្តិបានកើនមានឡើងហើយរាជរដ្ឋាភិបាលរបស់គណបក្សប្រជាធិបតេយ្យត្រូវរលាយ ហើយព្រះរាជាបានឡើងកាន់អំណាចនីតិប្រតិបត្តិ។ការលំបាកថ្មីៗខាងផ្នែកនយោបាយនាំឱ្យព្រះអង្គដឹកនាំសភា និងចាត់វិធានការពិសេសនានា ដោយមានអំណាចគ្រប់ប្រភេទព្រះអង្គបានបន្ត "រាជបូជនីយកិច្ចទាមទារឯករាជ្យ" ។

### ៦.៧. ផលវិបាកនៃអភិក្រមទំនើបកម្ម

#### ៦.៧.១. បញ្ហាសេដ្ឋកិច្ច



រទេះដំរីសម័យអាណានិគមបារាំង

ស្ថានភាពសេដ្ឋកិច្ចនៃប្រទេសកម្ពុជាក្នុងកំឡុងឆ្នាំ ១៨៦០-១៨៨០គ.ស. ដោយសារ របាយការណ៍ របស់បណ្ឌាលោក ស៊េដង់បារាំង Moura (ដែលធ្វើជាអ្នកតំណាងរបស់ប្រទេសបារាំងនៅប្រទេសកម្ពុជាពី ខែមករា១៨៧០គ.ស.ដល់ ១៨៧៦គ.ស. រួចមកពីខែវិច្ឆិកា១៨៧៦គ.ស. ដល់ ១៨៧៩ គ.ស. និងលោក Aymonier( លោក អាយមូនីញ៉េរ ) (ដែលលោកមានតំណាងដូចគ្នានោះពីឆ្នាំ ១៨៧៩គ.ស.ដល់១៨៨១

គ.ស.)។ រដ្ឋាភិបាលបារាំងមិនបានយកចិត្តលើ វិស័យសេដ្ឋកិច្ចរបស់ប្រទេសខ្មែរ នោះឡើយធ្វើឱ្យសេដ្ឋកិច្ចប្រទេសខ្មែរធ្លាក់ដល់ចំណុចសូន្យ។ ជារៀងរាល់ឆ្នាំពួកអ្នករដ្ឋបាលបារាំង ទាំងអស់ មិនខ្វល់ខ្វាយគឺអវត្តមានស្ទើរតែទាំងស្រុង នៃមធ្យោបាយគមនាគមន៍(ក្រៅអំពីទន្លេ និងបឹង) គឺជាឧបសគ្គយ៉ាងធំដល់ការអភិវឌ្ឍសេដ្ឋកិច្ច។ចំពោះផ្លូវថ្នល់វិញ គឺនៅអំឡុងឆ្នាំ ១៨៧៦ គ.ស. មានផ្លូវដែល រថយន្តបើកបានតែមួយខ្សែគត់គឺរវាង ឧត្តុង្គ និងកំពត។មានផ្លូវបែកមួយទៅកាន់ភ្នំពេញ ដែលត្រូវបានស្ថាបនាឡើងក្នុងរាជរបស់ព្រះបាទអង្គឌួង។យោងតាមសក្ខីភាពជាច្រើន គឺថា "បណ្តាញផ្លូវថ្នល់" នៅក្នុងរជ្ជកាលព្រះបាទអង្គឌួង គឺត្រូវបានថែទាំប្រសើរច្រើនជាងនៅក្នុងរជ្ជកាលក្រោយៗ ដូច្នេះវាមានការខូចខាតថ្នល់ និងស្ពាននៅក្នុងឆ្នាំដំបូងៗ នៃរាជ្ជកាលព្រះបាទនរោត្តម។ ការខូចខាតនេះ ទំនងជា មកអំពីចលាចលក្នុងប្រទេសដែលបានកំណត់សម្គាល់នូវការលេច ឡើងនៃ រាជាអង្គនេះ (ហើយលើសពីនេះ ទៀតចលនាទាំងនោះ បានបន្តយ៉ាងដាច់ៗពីគ្នាហូតដល់ចុង សតវត្សទី ១៩ នោះតែម្តង)។នៅជាគ្រឹះនៃសេដ្ឋកិច្ចកម្ពុជាដូចជាគេបានដឹងឮនោះ គឺកសិកម្មអាជីវកម្ម ព្រៃឈើ និងនេសាទ។ ចំពោះកសិកម្មនោះ លោកThomas Caraman (លោក ថូ ម៉ាស់ការ៉ាម៉ាន់)បានប៉ាន់ប្រមាណនៅឆ្នាំ ១៨៧៤គ.ស.ថាផ្ទៃដីដាំដុះបានតាំងត្រឹមតែ១ភាគ៣ ប៉ុណ្ណោះនៃក្រឡាផ្ទៃរបស់ប្រទេស។ លោកបានបន្ថែមថាដំណាំ(ដែល មានដំណាំស្រូវដាំនៅក្នុងតំបន់ទំនាបដែលលិចទឹក) ត្រូវបានគេដាំដោយពុំប្រើជី និងពុំមានបច្ចេកទេស ហើយដោយហេតុនេះ ទិន្នផលក៏បានទាបដែរ។ ចំពោះអាជីវកម្មព្រៃឈើពួកអ្នករដ្ឋបាលបារាំង បានកត់ត្រាថា ការកាប់ឈើគឺសេរីតែម្តង និងដោយពុំមានរដ្ឋាបាលព្រៃឈើទេការធ្វើអាជីវកម្ម ព្រៃឈើពុំមានកម្មវិធីណាមួយច្បាស់លាស់ឡើយ។ កសិកម្មនិងអាជីវកម្មព្រៃឈើនេសាទ មានតួនាទីសំខាន់ណាស់នៅក្នុងសេដ្ឋកិច្ចកម្ពុជា នៃ សតវត្ស ទី ១៩។ នៅលើបឹងទន្លេសាប ចំនួនមនុស្សពី ១២០០០ទៅ ១៤០០០នាក់ដែលមានចាម និងវៀតណាម យ៉ាងច្រើន។ ផលិតផលនៃព្រៃឈើនិងនេសាទបានផ្គត់ផ្គង់ វិស័យពាណិជ្ជកម្មដែលមានកម្រិតតិចតួចបំផុតហើយ ពាណិជ្ជកម្មនេះប្រព្រឹត្តជាសំខាន់ឆ្ពោះទៅកាន់ កូសាំងស៊ីន ខាងក្រោម និងកំពង់ផែព្រៃនគរ ។ ក៏ប៉ុន្តែតាំង ពីឆ្នាំដំបូងៗ នៃអាណាព្យាបាលបារាំង ក៏បានខិតខំពង្រីកទំនាក់ទំនង ពាណិជ្ជកម្ម ជាមួយនឹងតំបន់ទាំងឡាយនៃ ទន្លេខាងលើជាមួយនឹងប្រទេសលាវ (ជានិច្ចកាលគឺជាទេវកថាដដែលថា"ទន្លេមេគង្គមាគ៌ាឆ្ពោះទៅកាន់ប្រទេសកាន់ប្រទេសចិន") ។ កប្បាសគឺជាផលិតផលសំខាន់របស់កម្ពុជាដែលនាំចេញទៅកាន់កូសាំងស៊ីន។

នៅឆ្នាំ ១៨៧៦គ.ស. ការនាំចេញកប្បាសបានកើនឡើងដល់ ៣ ៨០០តោននៃកប្បាសមិនទាន់យកគ្រាប់ចេញ និង ១១០តោនដែលយកគ្រាប់ចេញហើយបន្ទាប់មកគឺ ម្រេច លូ សូត្រ ក្រវាញ ជ័រទឹក ស្ករអំពៅក្រមួន និង ឈើផ្សេងៗ។ កាលណោះប្រទេសកម្ពុជាក៏នាំចេញ ផងដែរនូវសាច់គោនិង ត្រីឆ្អើរ ក៏ដូចជាផលិតផល សិប្បកម្ម ជាពិសេស អង្ករ អំបិល ស្លឹកម្លូ ផ្លែឈើ និង ខ្សែពួរ។ ផលិតផលទាំងនោះ គឺមកពី (ពិសេសអង្ករ) កូសាំងស៊ីន។ ហេតុដូចម្តេចបានជានាំចូលអង្ក ពីព្រោះថាកាលនោះ ប្រទេស កម្ពុជាបានបាត់បង់ខេត្ត ហើយ ។ប្រទេសកម្ពុជាបានទទួលផលិតផល ចេញពី រោងចក្រមួយចំនួននិង ផលិតផលប្រណីតដែលធ្វើជាកម្មវត្ថុនៃ វិច្ឆេទកម្មសេដ្ឋកិច្ចយ៉ាងខ្លាំងក្លា ដែលនាំឱ្យ ពួកនាយទុនកុំប្រាឌ័រ ធ្វើមានធ្វើបានយ៉ាងសម្បើម។

នៅក្នុងកំឡុងឆ្នាំ១៨៧០គ.ស. វាមានការធ្វើឱ្យខ្លាំងក្លាឡើងនៃពាណិជ្ជកម្ម ដោយសារវិធានការមួយចំនួនដែលក្រុមប្រឹក្សា នៃអ្នករដ្ឋបាលបារាំងបានចាត់ឡើង។ វិធានការទាំងនោះគឺៈ នៅខែមិថុនា ឆ្នាំ ១៨៦៨

គ.ស. ពន្ធអាករដែលដាក់ទៅលើ បុរសនីមួយៗ ដែលធ្វើការនៅលើទូករបស់អាណ្ណាម ដែល រកស៊ីនៅក្នុងពាណិជ្ជកម្មឬការនេសាទនៅលើទន្លេមេគង្គ ឬនៅលើផ្នែកកម្ពុជា នៃទន្លេសាប គឺត្រូវបានលុបចោល។ វិធានការនេះមានផលបច្ច័យគឺ ការដុះដាលនៃនេសាទ និងទំនាក់ទំនងពាណិជ្ជកម្ម នៅក្នុងតំបន់នេះ និងទន្លេសាប ដែលកាល នោះបានចោទជាបញ្ហាយ៉ាងច្រើនសន្ធឹកសន្ធាប់។ក្រៅពីនេះ នៅខែមិថុនា ១៨៧៤គ.ស. គេបានយល់ព្រមមិនដកហូតពន្ធអាករនៃការសំចតសម្រាប់ ផលិតផល ទាំងឡាយដែលមកពីតំបន់បាត់ដំបង និងសៀមរាប ដែលឆ្ពោះទៅកាន់កូសាំងស៊ីន ។ រឿងនេះមិនបានផលចំណេញសម្រាប់ សេដ្ឋកិច្ចដែលជារបស់កម្ពុជាសុទ្ធសាធនោះឡើយ។ជាការពិត នៅអំឡុងទសវត្ស១៨៧០គ.ស. លទ្ធភាពសេដ្ឋកិច្ចដ៏ សំបូរបែបរបស់ប្រទេសកម្ពុជា មិនទាន់បានធ្វើអាជីវកម្មនៅឡើយ។

នៅខែសីហា ១៨៧៤គ.ស. លោក Aymonier (លោកអាយ ម៉ូនីញេរ)បានធ្វើរបាយការណ៍មួយ។ តាមរយៈរបាយការណ៍នោះ លោកបានបន្ទោសរដ្ឋាភិបាល ក្នុងការដែលមិនយកចិត្តទុកដាក់អំពីកិច្ចការផ្ទៃក្នុងរបស់ព្រះរាជាណាចក្រខ្មែរ។ សម្រាប់ លោកយល់ឃើញថា ដំណោះស្រាយតែមួយគត់ដែលត្រូវអនុញ្ញាតិឱ្យមាននូវសន្ទុះសេដ្ឋកិច្ចនៃប្រទេស កម្ពុជានោះ គឺការបញ្ចូលសុទ្ធសាធនិងសាមញ្ញ នៃរាជាណាចក្រមួយនេះ ទៅក្នុងដែនដីអាណានិគមកូសាំងស៊ីនរបស់បារាំង។ រឿងនេះបានតម្រូវឱ្យគេរក្សាទុកសម្រាប់ ព្រះមហាក្សត្រនូវ"ឋានន្តរៈមួយដែលពុំមានអំណាចអ្វីទាំងអស់"។ចំពោះហេតុការណ៍នេះគឺបានកើតមានឡើងនូវពន្លកនៃ"ពលប្រហារនៅខែមិថុនា១៨៨៤គ.ស." ។បន្ទាប់ពីពួកបារាំងបានបង្កើតដំបូងនូវវត្តមានជាស្វយ័តនៅកម្ពុជានៅឆ្នាំ ១៨៦៣ គ.ស. ពួកបារាំងបានយល់ថាសុបិនរបស់ពួកគេថាកម្ពុជានឹងអាចក្លាយជា សិង្ហបុរីកូសាំងស៊ីន គឺជាការភាន់ ច្រឡំមួយ ហើយថាកម្ពុជាគ្មានទ្រព្យសម្បត្តិដែលបានលាក់បាំងនោះទេ។ ចាប់តាំងពី ពេលនោះមក សេដ្ឋកិច្ចកម្ពុជាក៏មិនបានធ្វើទំនើបកម្មគួរឱ្យគត់សម្គាល់នោះទេ។ បារាំងបានប្រមូលពន្ធដារដោយមានប្រសិទ្ធិភាព ក៏ប៉ុន្តែផ្សេងៗពីនោះ បាននាំមកវិញនូវការផ្លាស់ប្តូរតិចតួចចំពោះសេដ្ឋកិច្ចក្នុងភូមិស្រុករបស់ខ្មែរ ។ការរើសអើងទល់នឹងជនជាតិមិនមែនយួនដោយពួកបារាំងបានបន្ត ជាពិសេសទោះបីជាដឹង ថាជនជាតិខ្មែរបានបង់ពន្ធដារខ្ពស់បំផុតនៅកូសាំងស៊ីនក៏ដោយ។ នៅឆ្នាំ ១៩២៥គ.ស. ការបះបោរពន្ធដារ មួយបាននាំមកកសិករស្រុកស្រែចម្ការរាប់ម៉ឺននាក់មកដល់ភ្នំពេញដើម្បីធ្វើញត្តិឱ្យព្រះបាទស៊ីសុវត្ថិមុនីវង្សឱ្យមានបន្ធូរបន្ថយពន្ធដារ។ ពួកបារាំងពួកគេយល់ថាខ្មែរជាជនជាតិមួយស្ងៀមស្ងាត់និងសោះអង្គើយដែលមិនអាចរៀបចំការតវ៉ាដែលគួរឱ្យតក់ស្លុត បាននោះទេ ។ ទោះបីជាមានការតវ៉ា ដូច្នោះមែនក៏ព្រះបាទស៊ីសុវត្ថិ-មុនីវង្ស មិនអាចដោះស្រាយអ្វីបានឡើយ ។ នៅឆ្នាំ ១៩២៥គ.ស. ពួកអ្នកស្រុកបានសម្លាប់អភិបាលបារាំងម្នាក់ ( រ៉េស៊ីដង់ ) ដែលបានគំរាមគំហែងចាប់ខ្លួនពួកអ្នក ល្មើសច្បាប់ពន្ធដារ ។វិស័យសេដ្ឋកិច្ចមួយចំនួនត្រូវបានអភិវឌ្ឍក្រោមការគ្រប់គ្រងរបស់បារាំងពួកបារាំងបានសាងផ្លូវថ្នល់ និងផ្លូវដែកមួយចំនួនលើទឹកដីកម្ពុជា។ ហេដ្ឋារចនាសម្ព័ន្ធនិងកិច្ចការសាធារណៈត្រូវ បានអភិវឌ្ឍក្រោមការដឹកនាំរបស់បារាំង និងផ្លូវដែកត្រូវបានសាងសង់ឡើងនៅក្នុងទឹកដីកម្ពុជា។ គួរឱ្យកត់សម្គាល់ខ្លាំងបំផុត ពេលនោះផ្លូវដែករាប់គីឡូម៉ែត្រពីរបីខ្សែដែលទាក់ទងគ្នាបានដាក់ឱ្យប្រើ ផ្លូវមួយខ្សែដ៏សំខាន់បានភ្ជាប់ភ្នំពេញទៅនឹងព្រំដែនថៃតាមរយៈខេត្តបាត់ដំបង។ ការដាំដុះកៅស៊ូ និង ពោតដែលជាដំណាំសំខាន់ខាងសេដ្ឋកិច្ច ហើយភ្លាមនោះដែរខេត្តបាត់ដំបង និងខេត្តសៀមរាបបាន ក្លាយជាចានបាយនៃកូសាំងស៊ី ។ កំឡុងទសវត្សឆ្នាំ ១៩២០គ.ស. កម្ពុជាបានចំណេញនៅពេលដែលកៅស៊ូ និងពោតមានតម្រូវការច្រើនក៏ប៉ុន្តែបន្ទាប់ពី

សេដ្ឋកិច្ចធ្លាក់ចុះនៅឆ្នាំ១៩២៩គ.ស.កម្ពុជាក៏បានរងគ្រោះជា ពិសេសក្នុងចំណោមអ្នកដាំដំណាំស្រូវ ដែលមានប្រាក់ចំណូលរបស់ពួកគេធ្លាក់ចុះ ដែលធ្វើឱ្យពួកគេកាន់ តែឆាប់ក្លាយជាជនរងគ្រោះ នៃពួកអ្នកចងការប្រាក់ជារៀងរហូត ។ឧស្សាហកម្មបានរៀបជាដំបូងដើម្បីដំណើរវត្ថុធាតុដើមសម្រាប់ ការប្រើប្រាស់ក្នុងស្រុក ឬ សម្រាប់នាំចេញ ។ អន្តោប្រវេសន៍បានទៅដល់កម្ពុជាដ៏ច្រើនសន្ធឹកសន្ធាប់ ហើយកម្ពុជាក៏ប្រែជាមាន ជនជាតិចម្រុះជាច្រើន ។ ពេលនោះនៅភូមា និងម៉ាឡេស៊ី ដែលប្រទេសទាំងពីរស្ថិតក្រោមការគ្រប់ គ្រងរបស់ប្រ៊ីតថេន(អង់គ្លេស) ជនបរទេសបានគ្រប់គ្រងកម្លាំងដំណើរការនៃសេដ្ឋកិច្ច។ ជនជាតិយួន ថ្វីត្បិតថាតួនាទីបុព្វសិទ្ធិរបស់ពួកគេ គ្រាន់តែជាពួកពលករខាងដាំដុះកៅស៊ូក៏ដោយ។ចំពោះ ជន អន្តោប្រវេសន៍យួនក៏បានចាប់ផ្តើមដើរតួសំខាន់ នៅក្នុងសេដ្ឋកិច្ចអាណានិគមជាអ្នកនេសាទ និងអ្នក ជំនួញ។ ចិនបានកំពុងតែរស់នៅកម្ពុជាអស់រយៈពេលជាច្រើនសតវត្ស ហើយពួកគេបានគ្រប់គ្រង ពាណិជ្ជកម្ម តាំងពីមុនការមកដល់របស់បារាំងទៅទៀត ។ ក្រោមការគ្រប់គ្រងរបស់បារាំង ស្ថានភាព នេះនៅដដែល ក៏ប៉ុន្តែពួកបារាំងបានដាក់កំហិតលើពួកចិន ។ យ៉ាងណាក៏ដោយ ពួកឈ្មួញ និង ធនាគារិកចិននៅកម្ពុជាបានអភិវឌ្ឍបណ្តាញពាណិជ្ជកម្មជាច្រើនដែលលាតសន្ធឹងទូទាំងឥណ្ឌូចិនរហូត ដល់ប្រទេសចិនផងដែរ ប៉ុន្តែតំណែងជាន់ខ្ពស់ត្រូវបានប្រគល់ឱ្យទៅពួកបារាំង ។កម្ពុជាដើមឡើយត្រូវបាន គេប្រើជាទឹកដីទ្រនាប់របស់បារាំង នៅចន្លោះដែនដីអាណានិគមយួន សំខាន់ៗ និងសៀម(ក្រោយមកពួកអាណានិគមយកទឹកដីសៀមជាទឹកដីទ្រនាប់វិញដែលមិនមានពួកអាណានិគមណាមួយមកត្រួតត្រាឡើយ) កម្ពុជាដើមឡើយត្រូវបានចាត់ទុកថាជាតំបន់សំខាន់ខាងសេដ្ឋកិច្ចមួយនោះ ។ ថវិការដ្ឋាភិ បាលអាណានិគមដើមឡើយត្រូវពឹងផ្អែកយ៉ាងខ្លាំងលើការប្រមូលពន្ធនៅកម្ពុជាជាប្រភពសំខាន់នៃប្រតិលាភ និងប្រជាជន កម្ពុជាបានបង់ពន្ធខ្ពស់បំផុត ក្នុងម្នាក់ៗចំណោមដែនដីអាណានិគម បារាំងនៅឥណ្ឌូចិន។រដ្ឋបាលទន់ខ្សោយ និងជួនកាលមិនរឹងមាំក្នុងការគ្រប់គ្រង របស់បារាំងនៅកម្ពុជាមានន័យថា ហេដ្ឋារចនាសម្ព័ន្ធ និងនគរូបនីយកម្មបានធំឡើងក្នុង អត្រាតិចជាងវៀត ណាម និងរចនាសម្ព័ន្ធសង្គមកាលពីសម័យមុននៅក្នុងភូមិនៅតែមានសេសសល់ ។ យ៉ាងណាមិញ ដូចគ្នាការគ្រប់គ្រងរបស់បារាំងបានតម្រែតម្រង់បន្ទាប់ពីសង្គ្រាមបារាំង-សៀម ការអភិវឌ្ឍចាប់ផ្តើម យឺតៗនៅកម្ពុជាដែលដំណាំស្រូវ និងម្រេចបានអនុញ្ញាតឱ្យសេដ្ឋកិច្ចលូតលាស់ជឿនលឿនឡើង ។ គ្រានោះដែរឧស្សាហកម្មរថយន្តបារាំងបានលូតលាស់ យ៉ាងខ្លាំង។ចម្ការកៅស៊ូដូចមានខ្លះរួចទៅហើយនៅ កូសាំងស៊ីន និងអណ្ណាមត្រូវបានកសាងឡើង និងដំណើរការដោយពួកវិនិយោគបារាំង ។ ពិពិធកម្មសេដ្ឋកិច្ចបានបន្តពេញមួយទសវត្សឆ្នាំ ១៩២០គ.ស. នៅពេលនោះដំណាំពោត និងកប្បាសក៏ត្រូវបានគេដាំដុះ ហើយដែរ ។ ទោះបីជាការពង្រីក និងការវិនិយោគខាងសេដ្ឋកិច្ច ប្រជាជន កម្ពុជានៅតែបន្តបង់ពន្ធខ្ពស់ នៅឆ្នាំ ១៩១៦គ.ស. ពួកបាតុករបានផ្ទុះការទាមទារឱ្យបន្ធូរបន្ថយការបង់ពន្ធដារ ។

## ៦.៧.២. បញ្ហាវប្បធម៌

បដិវាទកម្មរវាងវប្បធម៌ពីការផ្សាំវប្បធម៌ខ្មែរ ជាមួយវប្បធម៌បារាំងដើម្បីងាយស្រួលបម្រើការឱ្យរដ្ឋការបារាំងបានបង្កើតគ្រឹះស្ថាន សិក្សាខ្លះៗដូចជា៖

-នៅឆ្នាំ ១៩១១គ.ស. មានសាលាបឋមសិក្សា ចំនួន ៣០ ដល់ឆ្នាំ១៩៣៧ មាន ៨១៣ សាលា

-នៅឆ្នាំ ១៩១១គ.ស. មានអនុវិទ្យាល័យ ស៊ីសុវត្ថិចំនួន ០១ ដល់ឆ្នាំ១៩៣៥ ក្លាយជាវិទ្យាល័យ

-នៅឆ្នាំ ១៩១១គ.ស. មានសាលាអប់រំបច្ចេកទេស សិល្បៈ និងសាលារចនា

-នៅឆ្នាំ ១៩៣៧គ.ស. មហាវិទ្យាល័យ ឥណ្ឌូចិនហាណូយ មាននិស្សិត ៦៣១នាក់ក្នុងនោះមាន ព្រះរាជក្រិត្យចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩០៨គ.ស. បានបញ្ចូលរបបសេដ្ឋកិច្ចសេរីនិយម មកក្នុងប្រទេសកម្ពុជា ប៉ុន្តែពុំបានផ្តល់ផលប្រយោជន៍អ្វីដល់រាស្ត្រខ្មែរទេ បែរជាហុចផលដ៏ច្រើន ដល់បារាំង និងជនជាតិចិនទៅវិញ។ឥទ្ធពលបិតាធិបតីមិនមែនពីឥណ្ឌាទាំងស្រុងទេគឺមកពីទំនៀមទំលាប់ចិនដែរឥទ្ធិពលបារាំងមានវិស័យច្បាប់ ដូចជា ស្ថាប័នរដ្ឋាល សេដ្ឋកិច្ច ហិរញ្ញវត្ថុ វប្បធ៌មអរិយធ៌ម ប្រែប្រួល ទៅតាមបារាំង ដោយៈ

-លើកដំកើង និស្សិត បញ្ញាវ័ន្ត អភិជន ខ្មែរ

-បច្ចេកទេស ប្រដាប់ប្រើប្រាស់ប្រចាំថ្ងៃទំនើបៗទាន់សម័យ

-វិទ្យាសាស្ត្រ វេជ្ជសាស្ត្រ ឪសថសាស្ត្រ កសិកម្ម ឧស្សាហកម្ម ។

-នៅឆ្នាំ ១៩៣៩គ.ស. បុគ្គលិកពេទ្យមធ្យម មានបារាំង ០៥ នាក់ក្នុងនោះមាន ខ្មែរ០៨នាក់និងបុគ្គលិកពេទ្យទូទៅ ១៥០ នាក់។

នៅឆ្នាំ១៩៥០គ.ស. វប្បធ៌មខ្មែរគឺ ការអានសៀភៅ ទស្សនាវដ្តី បរទេស ខ្មែររៀនភាសារបារាំង និងអក្សរឡាតាំង ក្រៅពីនេះខ្មែរនាំគ្នាមើលខ្សែភាពយន្ត បារាំង អាមេរិក អ៊ីតាលីជាដើម។អ្នកដែលទទួលការអប់រំតាមបែបខ្មែរសុទ្ធសាត គឺចូលចិត្តមើលខ្សែភាពយន្តឥណ្ឌានិងខ្មែរ អ្នកដែលរៀននៅវិទ្យាល័យ មានគូប្រចាំចិត្ត និងមានទស្សនៈជឿនលឿនក្នុងទំនាក់ទំនងរវាងស្រី និងប្រុស ដូចជាការទទួលស្គាល់សេរីភាពរបស់បុគ្គល។បារាំងពុំបានយកចិត្តទុកដាក់ទៅលើសិទ្ធិមនុស្ស នៅក្នុងប្រទេសខ្មែរឡើយក្នុងសម័យ បារាំងដាក់នឹមអាណានិគមក្នុងអំឡុងឆ្នាំ ១៨៦៣គ.ស.-១៩៥៤គ.ស.។ ក្នុងឆ្នាំ១៨៦៣គ.ស. -១៨៨៤គ.ស. បារាំង ជាអាណាព្យាបាលលើប្រទេសខ្មែរនៅក្នុងឆ្នាំ១៨៨៤គ.ស.-១៩៥៣គ.ស. បារាំងបានដាក់នឹមអាណានិគម លើប្រទេសខ្មែរ។ការដកអំណាចទាំងស្តេច និងដកសិទ្ធប្រជារាស្ត្រខ្មែរទូទាំងប្រទេស។ ជាពិសេសស្ត្រីដែលធ្លាប់ជាមាតាធិបតេយ្យនៃសង្គមខ្មែរត្រូវចុះថយឥទ្ធិពលគឺស្ថិតនៅក្នុងភាពបំបិទសិទ្ធសេរីភាពក្នុង ប្រពៃណីទំនៀមទំលាប់របស់ខ្មែរ ដែលខ្មែរធ្លាប់ គោរព ហើយចង់លុបបំបាត់ប្រពៃណីទំនៀមទំលាប់របស់ខ្មែរព្រមទាំងមិនឱ្យរៀនអក្សរខ្មែរថែមទៀត ដូចជាបង្កើតសាលារៀនឱ្យកូនខ្មែររៀនអក្សរ ឡាតាំងពុំបានបង្កើតសាលារៀនឱ្យកូនខ្មែររៀនអក្សរខ្មែរទេគឺមានតែបន្តិចបន្តួច កូនខ្មែរភាគច្រើនគឺរៀន នៅតាមវត្ត អារាមឬចូលបួសរៀនជាសង្ឃតែម្តង។ក្នុងការរៀនសូត្រភាគច្រើនរៀនបានតែកូនប្រុស ចំណែកឯកូនស្រី ពុំសូវបានរៀនទេ ពីព្រោះខ្វះសាលាដែលនៅជិតផ្ទះ ដូច្នេះស្ត្រីពុំមានចំណេះដឹង ជ្រៅជ្រះ ហើយក៏ពុំសូវមានសិទ្ធិសេរីភាពទេនៅក្នុងសម័យបារាំង។

នៅឆ្នាំ ១៩៤៣គ.ស. រដ្ឋអំណាចបារាំង មានផែនការផ្លាស់ប្តូរភាសាខ្មែរ ដោយបង្រៀនភាសា ឡាតាំងជំនួសវិញដែលនាំឱ្យព្រះសង្ឃខ្មែរ មានការប្រឆាំងបះបោរយ៉ាងខ្លាំងទៅនឹងផែនការ របស់ពួកបារាំង (ដូចជាការកើតឡើងនូវសង្គ្រាមឆ័ត្រ)។

-បារាំងបានបង្កើតសាលា ហ្វ្រង់ស្វាបូដ្វាំង ១៩២៨គ.ស.

-បារាំងបានបង្កើតសាលា ឌូដាជីឡាក្រេ ១៩៣៧គ.ស.

-បារាំងបានបង្កើតសាលា សុធារស ១៩៣៦គ.ស.

ដើម្បីឱ្យងាយស្រួលក្នុងការកសាងមនុស្សសម្រាប់បម្រើការឱ្យរដ្ឋបាល អាណាព្យាបាល**បារាំង** បានបង្កើតឱ្យមានគ្រឹះស្ថានសិក្សាខ្លះៗដូចជា៖

**-សាលាបឋមសិក្សា៖** នៅឆ្នាំ ១៩១១គ.ស. មានសាលា ៣០នៅឆ្នាំ ១៩៣៧ មាន៨១៣ ។

**-សាលាមធ្យមសិក្សា៖** នៅឆ្នាំ ១៩១១គ.ស. មាន**អនុវិទ្យាល័យស៊ីសុវត្ថិ**មួយ ។ នៅឆ្នាំ ១៩៣៥ គ.ស. អនុ វិទ្យាត្រូវបានបង្កើតឱ្យទៅជាវិទ្យាល័យស៊ីសុវត្ថិ ។

**-សាលាបច្ចេកទេស៖**នៅឆ្នាំ១៩១៧គ.ស.មានសាលាអប់រំខាងសិល្បៈនិងសិប្បកម្មគឺ**សាលា រចនា**

## ៦.៧.៣. បញ្ហាជនជាតិចិននៅកម្ពុជា

ជនជាតិចិនដែលរស់នៅស្រុកខ្មែរនៅសម័យបារាំងមានចំនួនច្រើន តាំងពីឆ្នាំ ១៨៦៣គ.ស. មកម្លេះ ហើយចំនួននេះកើនឡើងថែមទៀតរហូតដល់ ១០៦៧៨៤ នាក់នៅឆ្នាំ ១៨៧៤គ.ស.បើធៀបនឹង ប្រជាជនខ្មែរក្នុងសម័យនោះ ស្មើ ១០% នៃប្រជាជនខ្មែរទាំងអស់ ។ជនជាតិចិនគេ មិនពិបាក រស់នៅជាមួយខ្មែរទេពីព្រោះគេចេះជាក់ខ្លួន ហើយគោរពទំនៀមទំលាប់ខ្មែរ ខ្មែរកាត់ចិនក៏ចាប់មានច្រើនតាំងពីពេលនោះមកដែរ នៅឆ្នាំ ១៩៥០គ.ស.គ.ស.-១៩៦០គ.ស. ប្រជាជនខ្មែរមានចំនួន ៥ ៤៦៣ ០០០នាក់ ប្រជាជនខ្មែរនៅទីក្រុងភ្នំពេញមានចំនួន៖

-១៩៣៩គ.ស. = ១០៨ ០០០ នាក់

-១៩៥៨គ.ស. = ៤៥០ ០០០ នាក់

-១៩៧៥គ.ស. = ២ ៥០ ០០០០នាក់។[9]

## ៦.៧.៤. ការនាំចូលនូវជនជាតិយួន

ទស្សនៈ «ស្អប់» យួន គឺជាជំងឺតជំនាន់នៅក្នុងសង្គមខ្មែរ ហើយជំងឺនេះ ទំនងជាមិនអាចព្យាបាលឱ្យជាសះស្បើយបានឡើយ។ នៅក្នុងទស្សនៈរបស់ជនជាតិខ្មែរមួយចំនួន វៀតណាម ឬ យួន កំពុងតែលេបត្របាក់ប្រទេសកម្ពុជា តាមរយៈការបញ្ជូនប្រជាពលរដ្ឋវៀតណាមមករស់នៅ រកស៊ីដោយខុសច្បាប់នៅស្រុកខ្មែរ និងការវាតទីយកទឹកដីខ្មែរនៅតាមខ្សែព្រំដែន។ ទស្សនៈនេះចាក់ឫសយ៉ាងជ្រៅនៅក្នុងផ្នត់គំនិតមនុស្សខ្មែរ គ្រប់ស្រទាប់វណ្ណៈទាំងអស់ រាប់ចាប់តាំងពីប្រជាពលរដ្ឋធម្មតាដល់ អ្នកនយោបាយ និងបណ្ឌិតផងដែរ ចំពោះខ្មែរនិងយួន មានប្រវត្តិជូរចត់រួមគ្នាជាច្រើនជំនាន់មកហើយ គឺចាប់តាំងពីពាក់កណ្ដាលសតវត្សរ៍ទី១៥ ដែនដីខ្មែរត្រូវលេបត្របាក់ ដោយសៀមនៅខាងលិច និងអាណ្ណាម នៅខាងកើត ដែលបច្ចុប្បន្នជាប្រទេសវៀតណាម។នៅអំឡុងសតវត្សរ៍ទី១៩ នគរអាណ្ណាម បានកាត់យកទឹកដីកូសាំងស៊ីន ឬកម្ពុជាក្រោមពីខ្មែរ និងបានលើកបន្តុបក្សត្រិយ៍ អង្គមី ឱ្យឡើងគ្រងរាជ្យជាមហាក្សត្រខ្មែរ។ ក្រោមខ្សែញាក់របស់នគរអាណ្ណាម ក្សត្រិយ៍អង្គមី ។យួនបានព្យាយាមបំបាត់ប្រពៃណី ទំនៀមទម្លាប់ សាសនា និងរបៀបរបបគ្រប់គ្រងរដ្ឋបាលពីបុរាណរបស់នគរខ្មែរ។ ខេត្តរបស់ខ្មែរ ដែលមាន ៥៦ខេត្ត ត្រូវបានកាត់បន្ថយមកនៅត្រឹម ៣៣ ហើយត្រូវប្ដូរឈ្មោះហៅតាមភាសាវៀតណាមវិញ ហើយគ្រប់ថៅហ្វាយខេត្តទាំងអស់នេះ ត្រូវមានជំនាញការវៀតណាមម្នាក់មកត្រួតពីលើ។ ដោយទ្រាំមិនបាននឹងទង្វើនេះ ប្រជារាស្ត្រខ្មែរក៏បាននាំគ្នាងើបឡើងបះបោរ ធ្វើការវាយ

[9] -វ៉ាន់ឌី កាអុន សុបិន និងការពិត ឆ្នាំ១៩៧២

ផ្ទក់ កាប់សម្លាប់ទាហាន និងប្រជាជនអាណ្ណាមដោយឥតរើសមុខ។ ការបះបោរប្រឆាំងអាណ្ណាម ឬ វៀតណាម លើកនោះ គឺជាព្រឹត្តិការណ៍ដ៏សំខាន់ ដែលត្រូវបានកត់ត្រាទុកនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា។ចាប់តាំងពីពេលនោះ មក អំពើហិង្សា និងការលាបពណ៌ ប្រឆាំងនឹងជនជាតិវៀតណាមនៅកម្ពុជាកើតមានជាបន្តបន្ទាប់និងខ្លាំងឡើងៗ រាប់ចាប់តាំងពីសម័យសាធារណរដ្ឋខ្មែរ សម័យកម្ពុជាប្រជាធិបតេយ្យ សម័យរដ្ឋកម្ពុជា និងសម័យព្រះរាជាណាចក្រកម្ពុជាទី២សព្វថ្ងៃ។

## ៧. កម្ពុជានិងសង្គ្រាមលោកលើកទី១

នៅដើមសតវត្សទី២០គ្មានចលនាបះបោរណាមួយច្បាស់លាស់ទេប៉ុន្តែ មានការបះបោរតូចៗជាច្រើនដែលបារាំងចាត់ថាជាពួកចោរ។នេះបង្ហាញថាប្រជាជនមិនពេញចិត្តនឹងការដឹកនាំប៉ុន្តែគ្មានការរៀបចំចលនាប្រឆាំងបារាំងជាទ្រង់ទ្រាយធំទេ។ សង្គ្រាមលោកលើកទី១១៩១៤-១៩១៨គ.ស.ពុំសូវជះឥទ្ធិពលលើអាស៊ី អាគ្នេយ៍ប៉ុន្មានទេ ក៏ប៉ុន្តនៅវៀតណាមបារាំងបានកែនមនុស្សប្រមាណដប់ម៉ឺននាក់ ទៅធ្វើទាហាននៅស្រុកបារាំងនៅកម្ពុជា បារាំងបានស្នើអ្នកស្ម័គ្រចិត្តហើយមានខ្មែរ ខ្លះស្ម័គ្រចិត្តទៅច្បាំងនៅបារាំងដោយរួមមាន ក្សត្រខ្មែរចំនួន៦អង្គពីរអង្គសុគតនៅទីនោះ។ អ្នកនយោបាយសំខាន់ម្នាក់ក្នុងទសវត្សឆ្នាំ១៩៥០គ.ស. លោក យឹម ទិត (សូមមើលខាងក្រោម)ក៏បានចូលរួមជាទាហានស្ម័គ្រចិត្ត ក្នុងសង្គ្រាមលោកលើកទី១ នោះដែរ។ មានក្សត្រខ្មែរភ្លាមនោះក្នុងខែមករា ឆ្នាំ១៩១៦ គ.ស.ប្រជាកសិករាប់ពាន់នាក់ ដំបូងមកពីខ្សាច់កណ្តាលនិងកំពង់ចាម ហើយក្រោយមកក៏មានមកពីខេត្តផ្សេងៗទៀតដែរបានមកធ្វើបាតុកម្ម ក្នុងក្រុងភ្នំពេញនៅមុខព្រះបរមរាជវាំង នៅចុងបញ្ចប់មានមនុស្សកើនឡើងដល់ទៅមួយសែននាក់។ ពួកគេទាមទារចូលគាល់ព្រះមហាក្សត្រដោយពុំបានវាយបារាំង ឬ បង្កចលាចល ពួកគេប្តឹងតវ៉ាពីអំពើពុករលួយរបស់មន្ត្រីកម្ពុជានៅតាមខេត្ត។នៅពេលនោះដែលបារាំងបានចាប់ផ្តើមកម្មវិធីកសាង ហើយគេបានអនុវត្តន៍ពន្ធពលកម្មតាមប្រពៃណីពន្ធពលកម្មចាស់ដែលមានពីមុន។ តាមច្បាប់ក្នុងឆ្នាំ១៩១៦គ.ស. មនុស្សមួយនាក់អាចគេចពីពន្ធការងារ បានបើគាត់បង់ពន្ធពិសេសចំនួនព្យាស(រូបីយប័ណ្ណឥណ្ឌូចិន)ប៉ុន្តែមន្ត្រីខេត្តបានទារលើសចំនួនដល់ទៅ១០ឬ១៥ព្យាស ពួកគេបានយកប្រាក់នោះមួយចំនួន ជួលកម្មករសរីជនជាតិចិន(បរទេសមិនត្រូវធ្វើពន្ធការងារទេ) ហើយទុកប្រាក់ដែលនៅសល់ទាំងនោះសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន នេះជាមូលហេតុនៃការធ្វើបាតុកម្មក្នុងឆ្នាំ១៩១៦គ.ស. ព្រះបាទស៊ីសុវត្ថិបានមានព្រះឱង្ការទៅកាន់ពួកបាតុក ដោយសន្យាថានឹងដោះស្រាយបញ្ហានេះ ពួកគេបានត្រឡប់ទៅភូមិស្រុកវិញ ពួកមន្ត្រីនៅខេត្តមួយចំនួនបានទទួលទណ្ឌកម្ម ហើយពួកបាតុករប្រមាណជាង៤០០នាក់ត្រូវបារាំងចាប់។



( ទាហានខ្មែរចូលរួមក្នុងសង្គ្រាមលោកលើកទី១ )

នៅពាក់កណ្តាលទី២នៃសតវត្សទី១៩ និងពាក់កណ្តាលទី១នៃសតវត្សទី២០បាតុកម្មនេះ មានលក្ខណៈសំខាន់ខុសពីការបះបោរ នៅឆ្នាំ១៨៨៤គ.ស.-១៨៨៦គ.ស. បដិវត្តន៍មុននោះ ដឹកនាំដោយមន្ត្រីចាស់១ ប៉ុន្តែនៅក្នុងឆ្នាំ១៩១៦គ.ស. ប្រជាកសិករដឹកនាំប្រឆាំងនិងពួកមន្ត្រីចាស់ៗដែល មានការបែកបាក់រវាងមេដឹកនាំនិងប្រជាជន។ គោលនយោបាយបារាំងទូទៅក្នុងសតវត្សទី២០មិនសូវមានសារៈប្រយោជន៍

ចំពោះប្រជានុរាស្ត្រកម្ពុជាសាមញ្ញទេ ពន្ធឡើងខ្ពស់ ។ថវិកាចំណាយលើការអភិវឌ្ឍន៍វិស័យអប់រំ និងសុខាភិបាលមានចំនួនតិចតួច។ ពន្ធការងារជូនកាលគាបសង្កត់ខ្លាំង ដូចករណីការកសាងបុរីបូកគោ ដែលមានកម្មករស្លាប់ចំនួន៩០០នាក់នៅទីនោះក្នុងរយៈពេល៩ខែដោយបាក់កម្លាំងនិងជំងឺគ្រុនចាញ់។[10]

## ៨. កម្ពុជានិងសង្គ្រាមលោកលើកទី២

### ៨.១. ឥទ្ធិពលជប៉ុននៅកម្ពុជា

នៅក្នុងសង្គ្រាមលោកលើកទី២ ខែកក្កដា ឆ្នាំ១៩៤១គ.ស. អគ្គទេសាភិបាលឥណ្ឌូចិន ដឺគូលបានចុះហត្ថលេខាជាមួយជប៉ុនលើសន្ធិសញ្ញាមួយ ដែលយល់ព្រមឱ្យជប៉ុនបោះទ័ពនៅគ្រប់ទីកន្លែងក្នុងឥណ្ឌូចិនក្នុងនោះ មានប្រទេសកម្ពុជាផង។ ពេលនោះប្រទេសកម្ពុជាត្រូវទទួលការជិះជាន់ពីបារាំងផងនិងពីជប៉ុន ផង។ ក្នុងគ្រាដំបូងបារាំង និងជប៉ុនហាក់ដូចជាត្រូវគ្នាបារាំង យល់ព្រមបែងចែកបុព្វសិទ្ធិខ្លះទៅឱ្យជប៉ុន តែក្រោយមកបារាំងនិងជប៉ុនរងចាំតែឱកាសកំចាត់គ្នាទៅវិញទៅមក។ នាយប់ថ្ងៃទី៩ ខែមិនា ឆ្នាំ១៩៤៥នៃ គ.ស. ជប៉ុនបានចាប់ផ្តើមធ្វើពលប្រហារ ។[41] ទៅលើកងទ័ពបារាំងនៅឥណ្ឌូចិន។ រដ្ឋការអាណានិគមបារាំងនៅឥណ្ឌូចិនត្រូវផ្តួលរលំ ឯកងទ័ពបារាំងត្រូវបង្ខំចិត្តដាក់អាវុធពិសេសអគ្គទេសាភិបាលបារាំង និងដឺគូល ប្រេស៊ីដង់ស៊ូប៉េរីយ័រ រដ្ឋការបារាំងទាំងអស់នៅវៀតណាម នៅប្រទេសកម្ពុជា និងឡាវត្រូវចាប់ឃុំឃាំងទាំងអស់។

ជប៉ុនបានប្រកាសថា "អាស៊ីជារបស់ជនជាតិអាស៊ី"ដែលជប៉ុនបានយកទ្រឹស្តីរបស់លោកម៉ុនរ៉ូ ជាប្រជានាធិបតីរបស់សហរដ្ឋអាមេរិក ដែលបាននិយាយថា«ទ្វីបអាមេរិកមិនអាចមានជនជាតិណាមកដាក់អាណានិគមលើទ្វីបអាមេរិកបានទេ»ជប៉ុនបានទាញប្រជាប្រិយភាពពីចំណោមពួកអ្នកជាតិនិយមខ្មែរ ទោះបីយ៉ាងណា នយោបាយទីក្រុងតូក្យូនៅឥណ្ឌូចិនបានទុកឱ្យមាន រដ្ឋាភិបាលអាណានិគមទទួលបន្ទុកត្រឹមតែឈ្មោះប៉ុណ្ណោះ។នៅពេលនោះព្រះសង្ឃដែលលេចធ្លោហើយសកម្មខាងនយោបាយ គឺព្រះអាចារ្យហែមចៀវ ត្រូវបានចាប់ខ្លួននិងដោះស្បង់ចីវរ ដោយមិនសមរម្យដោយពួករដ្ឋអំណាចបារាំងនៅខែ កក្កដា ១៩៤២ គ.ស .ពួកអ្នករៀបរៀង សារព័ត៌មាន "នគរវត្ត" បានដឹកនាំបាតុកម្មមួយទាមទារឱ្យមានការដោះលែងព្រះអង្គ។ ពួកគេ ដូចគ្នានឹងពួកអ្នកជាតិនិយមដទៃទៀតដែរ ជាក់ស្តែងបានប៉ាន់ស្មានជ្រុលពេកទៅលើឆន្ទៈរបស់ជប៉ុនថានឹងជួយពួកគេមកវិញ រីឯរដ្ឋអំណាចវិឈីភ្លាមៗបានចាប់ខ្លួនពួកបាតុករនិងបានដាក់ទោសប្រហារជីវិតដល់លោកប៉ាច-ឈឿន ដែលជាមនុស្សម្នាក់ក្នុងចំណោមពួកអ្នករៀបរៀងសារព័ត៌មាន "នគរវត្ត"។ ។ អ្នករៀបរៀងផ្សេងទៀត លោកសឺន-ង៉ុកថាញ់ បានរត់គេចខ្លួនពីភ្នំពេញ ទៅកាន់ ជប៉ុននៅឆ្នាំបន្ទាប់។ក្នុងកិច្ចប្រឹងប្រែងអស់សង្ឃឹមដើម្បីឱ្យទទួលបានការគាំទ្រក្នុងស្រុក នៅប៉ុន្មានខែចុងក្រោយនៃសង្គ្រាម ពួកជប៉ុនបានរំលាយរដ្ឋបាលអាណានិគមបារាំងនៅថ្ងៃ ៩ មីនា ១៩៤៥គ.ស. និងបានជំរុញឱ្យ កម្ពុជាប្រកាសឯករាជ្យរបស់ខ្លួននៅក្នុងមណ្ឌលវិបុលភាពរួម នៅអាស៊ីខាងកើតធំជាងគេ។ បួនថ្ងៃក្រោយមកព្រះបាទសីហនុបានចេញរាជក្រឹត្យថាកម្ពុជាបានឯករាជ្យ។ លោកសឺន-ង៉ុកថាញ់បានត្រឡប់មកពីតូក្យូនៅខែ ឧសភា ហើយលោកត្រូវបានគេតែងតាំងជារដ្ឋមន្ត្រីការបរទេស។លោកសឺន-ង៉ុកថាញ់ ឱ្យធ្វើជានាយករដ្ឋមន្ត្រី ដែលតាមការពិតរដ្ឋាភិបាលរបស់ សឺន-ង៉ុកថាញ់ គ្រាន់តែជារដ្ឋាភិបាលទីងមោងប៉ុណ្ណោះ នៃឯករាជ្យក្លែងក្លាយដែលផ្តល់ដោយ

[10]-ប្រវត្តិសាស្ត្រខ្មែរ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈឆ្នាំ២០០៦ទៅព័រ

ពួកយោធានិយមជប៉ុន។ នៅថ្ងៃ ១៥ សីហា ១៩៤៥គ.ស. ថ្ងៃដែលជប៉ុនបានចុះចាញ់សង្គ្រាម នៅពេលដែលកងកម្លាំងសម្ព័ន្ធមិត្តបានកាន់កាប់ភ្នំពេញ នៅក្រោយពេលជប៉ុនចាញ់សង្គ្រាមលោកលើកទី២ បារាំងបានវិលមកកាន់កម្ពុជាជាថ្មី កងទ័ពរបស់ សឺន-ង៉ុកថាញ់ បានប្រឹងទប់ទល់នឹងបារាំងដែរ តែពុំអាចតស៊ូនឹងបារាំងបានឡើយ ហើយសឺន-ង៉ុកថាញ់ ត្រូវបានចាប់ខ្លួនយកទៅឃុំនៅប្រទេសបារាំង។នៅឆ្នាំ១៩៥១គ.ស. បារាំងបានដោះលែង សឺន-ង៉ុកថាញ់ តាមសំណើរបស់ព្រះមហាក្សត្រខ្មែរ។នៅដើមឆ្នាំ១៩៥២គ.ស.សឺន-ង៉ុកថាញ់បានរត់ទៅប្រទេសថៃបង្កើតចលនាខ្មែរសេរី។

## ៨.២. កម្ពុជានិងឯករាជ្យភាព


កងជីវពលនារីក្លាហាន
រូបភាពGoogle Search )

កម្ពុជាដំណើរឆ្ពោះទៅកាន់ឯករាជ្យជាតិ និង សន្និសីទទីក្រុងហ្សឺណែវ ស្តីអំពីបញ្ហាឥណ្ឌូចិន ឆ្នាំ១៩៥៤ គ.ស. នៅក្រោមការត្រួតត្រា របស់អាណានិគមកំឡុងសង្គ្រាមលោកលើកទី២ ពួកជប៉ុន បានអនុញ្ញាតឱ្យមានរដ្ឋាភិបាលបារាំង(ដែលមានមូលដ្ឋាននៅវិចឈី) ដែលធ្វើសហប្រតិបត្តិការជាមួយក្រុមពួកសាធារណរដ្ឋ និងបានព្យាយាមចរចារលើលក្ខ័ណ្ឌដែលអាចទទួលយកបាន ដើម្បីបានឯករាជ្យភាពពីពួក បារាំង។ស្ថានភាពប្រទេសកម្ពុជានៅចុងនៃសង្គ្រាមលោកលើកទី២មានភាពវឹកវរ។ពួកបារាំងសេរីក្រោមការដឹកនាំរបស់លោកឧត្តមសេនីយ៍ឆាលស៍ដឺហ្គោល បានប្តេជ្ញាថានឹងយកឥណ្ឌូចិនមកវិញ ទោះបីជាពួកគេបានផ្តល់ឱ្យកម្ពុជានិងរដ្ឋអាណាព្យាបាលនៅ ឥណ្ឌូចិនដ៏ទៃទៀតក៏ដោយក៏មានវិធានដាក់កំហិតយ៉ាងប្រុងប្រយ័ត្នលើការគ្រប់គ្រងដោយខ្លួនឯង។ ដោយបានលួងលោមថាពួកគេមាន បេសកកម្មខាងអរិយធម៌ ពួកបារាំងបានមើលឃើញវែងឆ្ងាយនូវការចូលរួមចំណែករបស់ឥណ្ឌូចិន ក្នុងសហភាពបារាំងនៃអតីតអាណានិគម ដែល បានចែករំលែកនូវបទពិសោធន៍ជាទូទៅនៃវប្បធម៌បារាំង។ព្រះរាជបូជនីយកិច្ចដើម្បីឯករាជ្យរបស់ ព្រះសីហនុរាជជាលទ្ធផលនៅក្នុងការយល់ព្រមរបស់បារាំងដោយទើសទាល់ចិត្ត ចំពោះការទាមទាររបស់ទ្រង់សុំការផ្ទេរអធិបតេយ្យភាពវិញ។ កិច្ចព្រមព្រៀងមិនស្មើភាពគ្នាត្រូវបានសម្រេចនៅខែតុលា ១៩៥៣គ.ស.។ ព្រះបាទសីហនុក្រោយមកទ្រង់ក៏បានប្រកាសថាឯករាជ្យភាពបានសម្រេច ហើយក៏បានយាងត្រឡប់មកភ្នំពេញវិញដោយជោគជ័យ។

**- សន្និសីទទីក្រុងហ្សឺណែវស្តីអំពីបញ្ហាឥណ្ឌូចិន**

ទោះបីជាកម្ពុជាបានសម្រេចបានឯករាជ្យនៅចុងឆ្នាំ ១៩៥៣គ.ស. ក៏ដោយក៏ស្ថានភាពកងទ័ពរបស់ខ្លួនមិននឹងនរដែរ។ ក្រុមបក្សពួកដែលមិនមែនកុម្មុយនិស្តនៃពួកខ្មែរឥស្សរៈបានចូលក្នុងរដ្ឋាភិបាលក៏ប៉ុន្តែសកម្មភាព វៀតមិញ និយមកុម្មុយនិស្ត និង សមាគមខ្មែរឥស្សរៈបានកើតឡើងច្រើនដង ដែលកងកម្លាំងរបស់បារាំងបណ្តេញឱ្យនៅតិចតួចនៅកន្លែងផ្សេងៗទៀត។នៅខែមេសាឆ្នាំ១៩៥៤គ.ស.កងវរសេនាតូចវៀតមិញ ជាច្រើនបានឆ្លងកាត់ព្រំដែនចូលមកកម្ពុជា។កងកម្លាំងរាជានិយមបានប្រយុទ្ធនឹងពួកគេក៏ប៉ុន្តែមិនអាច

បង្ខំឱ្យមានការដកទ័ពថយទាំងស្រុងរបស់ពួកគេឡើយ ។ ម៉្យាងពួកកុម្មុយនិស្តកំពុងតែប៉ុនប៉ងពង្រឹងតំណែង ដែលនឹងតថ្លៃនៅសន្និសីទសឺណែវ ដែលបានកំណត់ការចាប់ផ្តើមនៅចុងខែមេសា។ សន្និសីទសឺណែវត្រូវបានចូលរួមដោយពួកអ្នកតំណាងមកពីកម្ពុជា វៀតណាមខាងជើង រដ្ឋាភិបាលចូលរួមនៃវៀតណាម (ពួកជំនាន់មុននៃសាធារណរដ្ឋវៀតណាម ឬវៀតណាមខាងត្បូង) ឡាវ សាធារណរដ្ឋប្រជាមានិតចិន សហភាពសូវៀត បារាំង ប្រ៊ីតថេន (ចក្រភពអង់គ្លេស) និងសហរដ្ឋ (សហរដ្ឋអាមេរិក)។ គោលដៅមួយនៃសន្និសីទគឺដើម្បីស្តារឱ្យមានសន្តិភាពបន្តនៅក្នុងឥណ្ឌូចិន។ ការពិភាក្សា ជា ច្រើនលើកឥណ្ឌូចិនបានផ្តើមនៅថ្ងៃ៨មីនា ឆ្នាំ១៩៥៤គ.ស. ។ ពួកវៀតណាមខាងជើងបានប៉ុនប៉ងដើម្បី ទទួលតំណាងចំពោះរដ្ឋាភិបាលតស៊ូដែលត្រូវបានបង្កើឡើងនៅភាគខាងត្បូង ក៏ប៉ុន្តែបានបរាជ័យ ។ នៅថ្ងៃទី ២១ កក្កដា ឆ្នាំ១៩៥៤គ.ស. សន្និសីទបានឈានឱ្យមានកិច្ចព្រមព្រៀងមួយដែលត្រូវឱ្យមាន ការផ្អាក់នូវអរិភាព(អំពើបង្ករសង្គ្រាម) នៅឥណ្ឌូចិន។ ដោយគោរពដល់កម្ពុជា កិច្ចព្រមព្រៀងបានចុះកិច្ចសន្យាថាកងកម្លាំងយោធាវៀតមិញ ទាំងអស់គឺត្រូវដកចេញក្នុងកៅសិប ថ្ងៃហើយនិងកម្លាំងតស៊ូខ្មែរត្រូវចេញពីកំណែនកងទ័ពក្នុងសាមសិបបីថ្ងៃ ។ នៅក្នុងកិច្ចព្រមព្រៀងផ្សេងមួយ បានចុះហត្ថលេខាដោយអ្នកតំណាងកម្ពុជា បារាំង និងវៀតមិញបានយល់ព្រមដើម្បី ដកកម្លាំងទាំងអស់ចេញពីដឹកដីកម្ពុជានៅខែតុលាឆ្នាំ១៩៥៤គ.ស.។ នៅក្នុងការដោះដូរសម្រាប់ការដកកងកម្លាំងវៀតមិញពួកអ្នកតំណាងកុម្មុយនិស្តនៅ សឺណែវចង់បានអព្យាក្រឹតភាពពេញលេញសម្រាប់ កម្ពុជា និងលាវដែលនឹងទប់ស្កាត់ការតាំងមូលដ្ឋាននៃ កងយោធាសហរដ្ឋនៅក្នុងប្រទេសទាំងនោះ។ នៅមុនថ្ងៃសម្រេចនៃសន្និសីទយ៉ាងណាៗអ្នកតំណាងឱ្យកម្ពុជា លោក សម សារី បានទទួចថា បើសិនកម្ពុជាត្រូវបានឯករាជ្យពិតប្រាកដមែន កម្ពុជាមិនត្រូវបានហាមឃាត់ពីការស្វែងរកជំនួយយោធាគ្រប់បែបយ៉ាងដែលកម្ពុជាចង់បាន ។ សន្និសីទបាទទួលយកចំណុចនេះលើការជំទាស់ប្រកែកដ៏ខ្លាំងក្លារបស់វៀតណាមខាងជើង។ នៅក្នុងកិច្ចព្រមព្រៀងចុងក្រោយ កម្ពុជាបានទទួលអព្យាក្រឹតភាពដែលចុះខ្សោយ នឹងប្តេជ្ញាមិនចូលរួមសម្ព័ន្ធមិត្តយោធាណាមួយដែលមិននៅក្នុងការអនុលោមភាពជាមួយគោលការនៃធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ឬការអនុញ្ញាត ឱ្យមានការតាំងកងកម្លាំងយោធាបរទេសលើទឹកដីរបស់ខ្លួនឡើយដរាបណាសន្តិសុខរបស់ខ្លួនមិនត្រូវបានគំរាមកំហែង។ កិច្ចព្រមព្រៀងសន្និសីទបានបង្កើតឡើងគណៈកម្មាការត្រួតពិនិត្យអន្តរជាតិ(ហៅជាផ្លូវការថា គណៈកម្មាការអន្តរជាតិដើម្បីត្រួតពិនិត្យ និងគ្រប់គ្រង) នៅក្នុងបណ្តាប្រទេសឥណ្ឌូចិនទាំងអស់។ ដោយបានបង្កើតឡើងដោយពួកអ្នកតំណាងមកពី កាណាដា ប៉ូឡូញ និងឥណ្ឌា ដែលត្រួតពិនិត្យលើបទឈប់បាញ់ ការដកកងទ័ពថយរបស់បរទេសការដោះលែងឈ្លើយសឹកនិងការយល់ព្រមទាំងស្រុងជាមួយនឹងលក្ខ័ណ្ឌនៃកិច្ចព្រមព្រៀង។ ពួកប្រឆាំង ភាគច្រើននៃកងកម្លាំងវៀតមិញត្រូវបានដកចេញតាមកាលកំណត់នៅខែតុលា ឆ្នាំ១៩៥៤គ.ស.។

នៅខែ មិថុនា ១៩៥២គ.ស. ព្រះសីហនុបានប្រកាសវិស្ថានបនកម្មនូវគណៈរដ្ឋមន្ត្រីរបស់ព្រះអង្គ ហើយបានព្យួរដ្ឋធម្មនុញ្ញ និងបានកាន់កាប់គ្រប់គ្រងរដ្ឋាភិបាលជានាយករដ្ឋមន្ត្រីដោយព្រះអង្គផ្ទាល់។ ក្រោយមកទៀត ដោយគ្មានសច្ចាប័នរដ្ឋធម្មនុញ្ញច្បាស់លាស់ ព្រះអង្គបានរំលាយសភាជាតិ ហើយបានប្រកាសច្បាប់អាជ្ញាសឹកនៅខែ មករា ឆ្នាំ១៩៥៣គ.ស.។ ព្រះសីហនុបានប្រើច្បាប់ផ្ទាល់ព្រះអង្គឯងអស់រយៈពេលជិតបីឆ្នាំចាប់ពី ខែ មិថុនា ឆ្នាំ១៩៥២គ.ស. រហូតដល់ ខែ កុម្ភៈ ឆ្នាំ ១៩៥៥គ.ស.។ បន្ទាប់ពីការរំលាយសភាចោលហើយ ព្រះអង្គបានបង្កើតសភាប្រឹក្សាដើម្បីចូលជំនួសកន្លែងអង្គនីតិបញ្ញត្តិ ហើយបានតែងតាំង

ព្រះវរបិតាព្រះអង្គ ព្រះនរោត្តម-សុរាម្រិតជារាជានុសិទ្ធិ។នៅខែ មីនា ឆ្នាំ ១៩៥៣ គ.ស.ព្រះសីហនុបានយាងទៅបារាំង។ ដោយបានប្រកាសក្តែងៗថា ព្រះអង្គកំពុងតែធ្វើដំណើរដើម្បីព្រះរាជសុខភាពទ្រង់ តែព្រះអង្គកំពុងតែចាប់ផ្តើមយុទ្ធនាការយ៉ាងខ្លាំងដើម្បីបញ្ចុះបញ្ចូលពួកបារាំង ឱ្យប្រគល់ឯករាជ្យពេលលេញមកឱ្យកម្ពុជាបរិយាកាសនៃការយល់ឃើញនៅកម្ពុជានៅពេលនោះមានដូចតទៅថា បើសិនជាទ្រង់មិនបានសម្រេចឯករាជ្យភាពភ្លាមៗទេ ប្រជាជនប្រហែលជាបែរត្រលប់ទៅរក លោកសឺន-ង៉ុកថាញ់ និងពួកខ្មែរឥស្សរៈ ដែលពួកគេតាំងចិត្តពេញទីដើម្បីសម្រេចគោលដៅមួយនេះ។ នៅក្នុងជំនួបជាមួយប្រធានាធិបតីបារាំង និងជាមួយមន្ត្រីជាន់ខ្ពស់ផ្សេងៗទៀតព្រះសីហនុបានធ្វើឱ្យពួកបារាំងក្លាយជាអ្នករង ការភិតភ័យភ្ញាក់ផ្អើលហួសហេតុអំពីស្ថានភាពនយោ បាយនៅក្នុងប្រទេសរបស់ទ្រង់។ ពួកបារាំងក៏បានធ្វើការគំរាមកំហែងលាក់កំបាំងបន្តិចថាបើសិនព្រះអង្គបន្តមិនធ្វើសហប្រតិបត្តិការទេ ពួកគេអាចនឹងផ្លាស់ប្តូរព្រះអង្គចេញពីតំណែង។ ព្រះរាជដំណើរនេះបានទទួលបរាជ័យ ក៏ប៉ុន្តែនៅតាមផ្លូវមកប្រទេសកំណើតវិញឆ្លងកាត់តាម សហរដ្ឋអាមេរិក កាណាដា និង ជប៉ុន ព្រះសីហនុបានផ្សព្វផ្សាយអំពីស្ថានភាពដ៏អាក្រក់របស់កម្ពុជា នៅតាមប្រព័ន្ធផ្សព្វផ្សាយ។ ដើម្បីធ្វើវិនាដកម្មបន្ថែមទៀតនូវ រាជបូជនីយកិច្ចដើម្បីឯករាជ្យ របស់ព្រះអង្គ ព្រះបាទនរោត្តមសីហនុបានកំពុងតែប្រកាសថាព្រះអង្គនឹងមិនវិលត្រឡប់ទៅវិញដរាបដល់ពួកបារាំងផ្តល់ឱ្យនូវការធានាអះអាងថាឯករាជ្យពេញលេញនឹងត្រូវផ្តល់ឱ្យកម្ពុជាវិញ។ ព្រះអង្គក្រោយមកទៀតបានយាងចាកចេញពីភ្នំពេញនៅខែ មិថុនា បាននិរទេសខ្លួនដោយព្រះអង្គឯងទៅកាន់ប្រទេសថៃ។ ដោយគ្មានការស្វាគមពីទីក្រុងបាងកក ព្រះអង្គក៏បានផ្លាស់មករាជដំណាក់របស់ព្រះអង្គ ក្បែរ វិកិណ្ណដ្ឋានអង្គរនៅ ខេត្តសៀមរាបវិញ។ សៀមរាបជាផ្នែកមួយនៃភូមិភាគកងទ័ពស្វយ័តដែលបានបង្កើតឡើងនៅឆ្នាំ ១៩៤៩គ.ស. ដែលត្រូវបានបង្គាប់បញ្ជាការដោយលោកនាយវរសេនីយទោលន់-នល់ ដើមឡើយជាអ្នកនយោបាយស្តាំ ដែលនឹងក្លាយជាជនលេចធ្លោម្នាក់ ហើយនៅពេលនោះជាសម្ព័ន្ធមិត្តរបស់ព្រះសីហនុដែលមិនអាចខ្វះបានខាងយោធា។ ចាប់ផ្តើមពីមូលដ្ឋានទ័ពឯសៀម រាបរបស់ទ្រង់ ព្រះមហាក្សត្រ និងលោកលន់ បានរិះរកផែនការជាច្រើនដើម្បីធ្វើការតស៊ូ បើសិនជាពួកបារាំងមិនព្រមទទួលកិច្ចសន្យាតាមលក្ខខណ្ឌរបស់ពួកទ្រង់។

ព្រះបាទនរោត្តមសីហនុកំពុងបង្កើតល្បែងភ្នាល់ធំមួយ ចំពោះពួកបារាំងវិញអាចដកព្រះអង្គចេញដោយដាក់ជំនួសស្តេចមួយទៀតដែលងាយបង្វិលបានតាមចិត្ត ក៏ពិតមែន តែស្ថានភាពកងទ័ពនៅពេលនោះនឹងអាចធ្វើឱ្យខ្មែចខ្ទាំឥណ្ឌូចិនទាំងមូល ក្រោយមកទៀតរដ្ឋាភិបាលបារាំងនៅថ្ងៃទី៣ កក្កដា ឆ្នាំ ១៩៥៣ គ.ស.បានប្រកាសខ្លួនរួចរាល់ដើម្បីប្រគល់ឯករាជ្យភាពពេញលេញដល់រដ្ឋទាំងបីមានកម្ពុជាវៀតណាមលាវ។ ព្រះសីហនុបានទទូចលើលក្ខខណ្ឌផ្ទាល់របស់ព្រះអង្គ ដែលរួមមានការគ្រប់គ្រងពេញទីខាង ការពារជាតិ នគរបាល តុលាការ និង បញ្ហាហិរញ្ញវត្ថុ។ ពួកបារាំងបានប្រគល់ឱ្យ នគរបាល និងតុលាការត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់កម្ពុជានៅចុងខែ សីហា ហើយនៅក្នុងខែ តុលា ប្រទេសនេះបានក្តោបក្តាប់ការបញ្ជាកងកម្លាំងទ័ពរបស់ខ្លួនពេញទី។ ព្រះបាទសីហនុ កាលណោះបានក្លាយជាវីរបុរសនៅក្នុងកែវភ្នែកនៃប្រជាជនរបស់ព្រះអង្គ និងបានត្រឡប់មកភ្នំពេញវិញដោយជ័យជម្នះ ហើយថ្ងៃឯករាជ្យគឺត្រូវប្រារព្ធធ្វើឡើងនៅថ្ងៃទី៩ វិច្ឆិកា ឆ្នាំ ១៩៥៣គ.ស.។ ការគ្រប់គ្រងបញ្ហានានាដែលសេសសល់កំពុងតែជះឥទ្ធិពលដល់អធិបតេយ្យភាព ដូចជាកិច្ចការហិរញ្ញវត្ថុ និង ថវិកា ត្រូវបានហុចបន្តដល់រដ្ឋកម្ពុជាថ្មីនៅឆ្នាំ ១៩៥៤គ.ស.។ តាមលទ្ធផល នៃសន្និសិទសឺណែវ លើឥណ្ឌូចិនកម្ពុជាអាចឱ្យការដកទ័ពរបស់វៀតមិញ ពីទឹកដីរបស់ខ្លួន

ហើយនិងតស៊ូប្រឆាំងនឹងការប៉ះពាល់ដែលនៅសេសសល់លើអធិបតេយ្យភាព របស់ខ្លួនតាមរយៈមហាអំណាចខាងក្រៅ។ អព្យាក្រិត្យគឺជាធាតុស្នូលនៃនយោបាយការបរទេស របស់កម្ពុជាកំឡុងទសវត្ស ១៩៥០-១៩៦០គ.ស.។

## ៨.៣. ការវិលត្រឡប់របស់បារាំង និងកំណែទម្រង់

### ៨.៣.១. កំណែទម្រង់ច្បាប់

កំណែទម្រង់រចនាសម្ព័ន្ធអំណាចសាធារណៈ ដែលលោករដ្ឋមន្ត្រីត្រូវបង្ហាញ នៅថ្ងៃពុធទី ១៤មិថុនា ឆ្នាំ១៩៤៦នៃគ. ទៅកាន់ក្រុមប្រឹក្សារដ្ឋមន្ត្រី បន្ទាប់មកនឹងបញ្ជូនទៅសភា និងចុងក្រោយ នៅពេលបើកបវេសនកាលមកវិញនឹងមានសំណើកំណែទម្រង់ច្បាប់រដ្ឋធម្មនុញ្ញ។

### ៨.៣.២. ការប្តូរទម្លាប់អាក្រក់របស់តំណាងរាស្ត្រ

អំណាច ប្រតិបត្តិបានសន្យាថានឹងធ្វើកំណែទម្រង់ស៊ីជម្រៅ ដ៏ធំមិនធ្លាប់មាន ដោយគ្រោងនឹងហាមឃាត់មិនឱ្យសមាជិកសភា ព្រមទាំងរដ្ឋមន្ត្រី ជ្រើសរើសសមាជិកគ្រួសារ មកធ្វើជាបុគ្គលិកបំរើការក្រោមបង្គ្រាប់ទេ។ហាមមិនឱ្យតំណាងរាស្ត្រ សមាជិកសភា ព្រឹទ្ធសភា ឬតំណាងអំណាចប្រតិបត្តិថ្នាក់តំបន់ ថ្នាក់ខេត្ត មូលដ្ឋានធំៗបន្តតំណែងលើសពីបីអាណត្តិ។សមាជិកសភា លែងមានកញ្ចប់ថវិកាបម្រុងសម្រាប់ចាយដូចមុនទៀត។ កញ្ចប់ថវិកានេះ ត្រូវចែកចាយជាមូលនិធិសកម្មដើម្បីដែនដីនិងគម្រោងបំរើផលប្រយោជន៍សាធារណៈទូទៅវិញ។ រដ្ឋាភិបាលចង់រឹតបន្តឹងខ្លាំងបំផុតសកម្ម ភាពរបស់ទីប្រឹក្សាសភា និងព្រឹទ្ធសភា។ ក្នុងករណីល្មើសកេងលុយរដ្ឋ និងប្រព្រឹត្តអំពើពុករលួយមន្ត្រីនោះអាចនឹងត្រូវកាត់ទោសលែងឱ្យឈរឈ្មោះបោះឆ្នោតរហូតដល់១០ឆ្នាំ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានសន្យាផ្តល់ទម្រង់ថ្មីដល់ហិរញ្ញវត្ថុសាធារណៈនយោបាយតាមរយៈការបង្កើត "ធនាគារប្រជាធិបតេយ្យ" សម្រាប់ឱ្យគណបក្សនីមួយៗខ្ចីលុយយកទៅឃោសនាបោះឆ្នោត។ជំនួយហិរញ្ញវត្ថុពីបរទេស ដល់គណបក្សនយោបាយ ត្រូវហាមឃាត់។ បុគ្គលឯកជនរបស់បក្សអាចខ្ចីលុយធនាគារពិសេសនេះបាន តែស្ថិតក្រោមការពិនិត្យពិច័យច្បាស់លាស់ ដើម្បីកុំឱ្យអ្នកនយោបាយនេះបង្វៀងយកទៅប្រើជាប្រយោជន៍បក្ស។ប្រធានាធិបតីផ្ទាល់ ក៏ត្រូវគោរពច្បាប់សីលធម៌នយោបាយដែរ។ នៅពេលបញ្ចប់អាណត្តិ ប្រធានាធិបតីត្រូវធ្វើសេចក្តីប្រកាសទ្រព្យសម្បត្តិ ទៅអាជ្ញាធរជាន់ខ្ពស់ ដើម្បីតម្លាភាពក្នុងជីវិតសាធារណៈ។ ប្រធានាធិបតីផុតអាណត្តិ មិនប្រាកដថាត្រូវមានអាសនៈនៅក្រុមប្រឹក្សាធម្មនុញ្ញជាស្វ័យប្រវត្តិទៀតទេ។

### ៨.៣.៣.កំណែទម្រង់រដ្ឋធម្មនុញ្ញ

លើផ្នែករដ្ឋធម្មនុញ្ញ រដ្ឋាភិបាលនឹងលុបចោលស្ថាប័នតុលាការសាធារណរដ្ឋ (ស្ថាប័នតែមួយគត់ដែលសព្វថ្ងៃនេះ មានអំណាចកាត់ទោសរដ្ឋមន្ត្រី ក្នុងឋានៈជាយុត្តាធិការពិសេស)។ តែតាមរយៈកំណែទម្រង់ រដ្ឋមន្ត្រី សមាជិកសភា ព្រឹទ្ធសភា មានជាប់សង្ស័យនឹងត្រូវកាត់ទោសដោយចៅក្រម ដូចពលរដ្ឋដទៃធម្មតា។ លោក ហ្វ្រង់ស័រ បាយរ៉ូ បានប្រកាសថានឹងមានដំណើរការ ទទួលខុសត្រូវដោយសមាជិកតុលាការគណនីក្រុមប្រឹក្សារដ្ឋ និងតុលាការកំពូល។ ការធ្វើបែបនេះ គឺដើម្បីបញ្ចៀសកុំឱ្យមានចោទប្រកាន់យកចំណេញ និង

ធ្វើឱ្យមានអស្ថិរភាពនយោបាយ។ ប៉ុន្តែកំណែទម្រង់រដ្ឋធម្មនុញ្ញនេះអាចពិបាកសម្រេចដោយត្រូវអនុម័តក្នុងសំឡេងភាគច្រើនដាច់ខាត ពីរភាគបីនៃសភានិងព្រឹទ្ធសភា ឬដោយឆ្លងកាត់ប្រជាមតិ ។

## ៩. កម្ពុជានិងឥទ្ធិពលជាតិនិយមថៃ

### ៩.១. បាត់ដំបងក្នុងសម័យសង្គ្រាមលោកលើកទី២

ប្រវត្តិការឈ្លានពាន និង កាន់កាប់ខេត្តបាត់ដំបង របស់សៀម នាសម័យសង្គ្រាមលោកលើកទី ២។ នៅឆ្នាំ១៩៤១គ.ស. នាកំឡុងសម័យសង្គ្រាមលោកលើកទី២ ឆ្លៀតពេលដែលបារាំងកំពុងចាញ់សង្គ្រាមនៅទ្វីបអឺរ៉ុប ប្រទេសសៀម ដោយមានការគាំទ្រពីជប៉ុនដែលជាមហាអំណាចអាស៊ីនៅពេលនោះ បានឈ្លានពាន និង កាត់យកដីមួយភាគធំនៃខេត្តពោធិសាត់ បាត់ដំបង និង សៀមរាប (លើកលែងតែតំបន់អង្គរ) ពីប្រទេសកម្ពុជា (ឥណ្ឌូចិនបារាំង) ហើយបន្តកាន់កាប់ដោយខុសច្បាប់លើដែនដីទាំងនោះ ដល់ខែតុលា ឆ្នាំ១៩៤៦ គ.ស. ដោយមានព្រំប្រទល់នៅត្រង់ស្ពានអូរដូនកែវ ខេត្តពោធិសាត់។ សៀមបានប្តូរឈ្មោះខេត្តទាំងនោះមកជា ខេត្តប្រាថាំបង ខេត្តពិបុលសង្គ្រាម ខេត្តណាខនចាំប៉ាសាក់ និង ប្តូរឈ្មោះតំបន់មួយចំនួនមកជាឈ្មោះថៃ ដូចជា ក្លងប្រាអាគី (អូរតាគី) ស៊ីសុផុន (សេរីសោភ័ណ) ជាដើម។ ប្រជាជនខ្មែរនៅតំបន់ទាំងនោះ ត្រូវបានបង្ខំឲរៀនភាសាថៃនិងហាមប្រាមមិនឲរៀនភាសាខ្មែរ ហើយថែមទាំងបានឱ្យ ចូលរួមបោះឆ្នោតសកលថៃ ឆ្នាំ១៩៤៦គ.ស.ទៀតផង។ ក្រោយសង្គ្រាមលោកលើកទី២ ជប៉ុនចាញ់សង្គ្រាមហើយដកទ័ពចេញពីឥណ្ឌូចិន ហើយបារាំងបានបង្ខំឱ្យសៀមសងខេត្តដែលខ្លួន ចូលកាន់កាប់ដោយខុសច្បាប់មក ឱ្យកម្ពុជាវិញយ៉ាងអាម៉ាស់ជាទីបំផុត។

### ៩.២. ខ្មែរឥស្សរៈនិយមថៃ

តាមរយៈអ្នកនិពន្ធកន្លងមក ដូចជាលោក ប៊ុណ្ណ ចន្ទម៉ុល ហាក់ព្យាយាមពន្យល់ "គាត់ជាប្រធាន ឬ ប្រមុខនៃចលនាខ្មែរឥស្សរៈដំបូងគេ" នៅបាត់ដំបងតែប៉ុណ្ណោះ។ តែតាមការពិតកំណាកំណើតរបស់ ចលនាខ្មែរឥស្សរៈ បើសិនយើងធ្វើការពិភាក្សា រែកញែក ដោយផ្ទៀងផ្ទាត់ជាមួយនឹងឯកសារពិគ្រោះ ដទៃទៀត ក៏ដូចជាព័ត៌មានដែលទទួលបានពីការសាកសួរលោក នី វ៉ាន់ធី គឺមានដំណើរដូចខាងក្រោម៖

ចលនាតស៊ូដំបូងនេះ ត្រូវបានផ្តួចផ្តើមបង្កើតឡើងដោយបច្ចជនដ៏មានឥទ្ធិពលម្នាក់របស់អភ័យ ធីបេស "បៃន" ឈ្មោះ ប៉ុក គុណ ឬ ប៉ុក ផល្គុណ ហៅតាត្រឡាច។ គាត់ និងបក្សពួកបានដាក់ឈ្មោះថា "ចលនាខ្មែរឥស្សរៈ" មានមូលដ្ឋានបង្អែកនៅខេត្តបាត់ដំបង ដែលកាលនោះជាដែនដីស្ថិតនៅក្រោមការ ត្រួតត្រារបស់ថៃ មួយរយៈពេលខ្លី ឆ្លៀតពេលដែលបារាំងចាញ់ដៃក្នុងសង្គ្រាមលោកលើកទី២ និងត្រូវ ស្ថិតនៅក្រោមឥទ្ធិពលនៃអំណាចយោធាជប៉ុន។ ចលនានេះ មានទីស្នាក់ការធំនៅផ្ទះអ្នក ល្មាយ ដែល ជាកូនស្រីម្នាក់នៃត្រកូល "កថាថន" ដែលជាបច្ចាជនរបស់អភ័យធីបេស "បៃន" ដែរ។ តាត្រឡាច បានតាំងមេដឹកនាំផ្ទាល់ដែលជាអតីតគ្រូបង្រៀនម្នាក់ ឈ្មោះ រស់ យឿន និងកូឈ្មួយរបស់គាត់ ឈ្មោះ បូរិន។ ចលនាខ្មែរឥស្សរៈបានធ្វើប្រតិបត្តិការតែនៅក្នុងតំបន់ទីរួមខេត្ត និងជាយទីក្រុងបាត់ដំបង ពិសេស នៅម្តុំ វត្តក្តាំងងារ វត្តលៀប និង វត្តពិភិទ្ធរង្សី ហៅវត្តកំភិត។

នៅក្នុងស្នាដៃ "ចរិតខ្មែរ" របស់គាត់, លោក ប៊ុណ្ណ ចន្ទម៉ុល ពិតជាមិនបានបង្ហាញកំណើតដើមទង របស់ខ្មែរឥស្សរៈឱ្យបានជាក់ច្បាស់នោះទេ ហេតុដូច្នេះហើយ ទើបមានអ្នកអានជាច្រើនយល់ថា រូបគាត់ តែម្នាក់ ដែលជាមេផ្តួចផ្តើមបង្កើតចលនាឥស្សរៈដំបូងៗនោះ។ ម្យ៉ាងទៀត ទាក់ទិននឹងបញ្ហា វាក្យសព្ទ "ឥស្សរៈ" នេះ គាត់បានឱ្យនិយមន័យថា "ធំ, មិនកញ្ចះគេ, ជាអ្នកជា។ ដូច្នេះ ខ្មែរឥស្សរៈ គឺជាក្រុមខ្មែរ ដែលជាម្ចាស់លើខ្លួនឯង គ្មាននៅក្រោមអំណាចនរណា, ជាខ្មែរមានឯករាជ្យ, មានសេរីភាព, មានសិទ្ធិ គ្រប់គ្រាន់ជាខ្មែរ"។ តើដោយសារ ខ្មែរឥស្សរៈ ជាខ្មែរមិនកញ្ចះ ឬ នៅក្រោមបង្គាប់គេដូច្នេះហើយឬ ដែលបណ្តាលឱ្យពួកមេដឹកនាំខ្មែរឥស្សរៈមិនរវល់ទៅពឹងពាក់កម្លាំង ឬជំនួយពីបរទេស ដែលអាចនាំឱ្យ ពួកគេធ្លាក់ក្នុងអន្លង់ ឬនឹមត្រួតត្រារបស់បរទេសនោះ? ម្ល៉ោះហើយ ដើម្បីជំនួសជំនួយបរទេស តើពួកគេ ត្រូវធ្វើអ្វីខ្លះ ដើម្បីធ្វើការតស៊ូបាន? មានហេតុផលជាច្រើនដែលផ្តល់ឱកាសឱ្យចលនាខ្មែរឥស្សរៈរីកធំធាត់ និងប្រមូលបានការគាំទ្រ យ៉ាងច្រើនពីសំណាក់ប្រជាជនខ្មែរ។ មូលហេតុមួយក្នុងចំណោមហេតុផលសំខាន់ៗបំផុត គឺដោយសារការ គាបសង្កត់ពីសំណាក់បារាំង។ ដូចដែលគេបានដឹង មានមន្ត្រី អាណានិគមបារាំងមួយចំនួនធំ តែងធ្វើការ គាបសង្កត់ ទារពន្ធដារធ្ងន់ធ្ងរមកលើប្រជារាស្ត្រខ្មែរក្រីក្រ។ដូច្នេះហើយទើបមានការតស៊ូវាយបារាំងឆ្នាំ១៩៨៤-១៩៨៦គ.ស . ព្រឹត្តិការណ៍១៩១៦គ.ស. ព្រឹត្តិការណ៍សម្លាប់លោកបារដេសឆ្នាំ១៩២៥គ.ស. និងបាតុកម្មឆត្រ របស់ព្រះសង្ឃឆ្នាំ១៩៤២គ.ស.ជាដើម។ ទាំងនេះ អាចជាមូលហេតុសមរម្យសម្រាប់ប្រជារាស្ត្រខ្មែរក្រោកឈរឡើងប្រឆាំងបារាំង។លើសពីនេះទៅទៀត ក្រោយការចាប់ខ្លួនរបស់អាចារ្យ ហែម ចៀវ នៅឆ្នាំ១៩៤២គ.ស.ក៏បានជំរុញឱ្យ ព្រះសង្ឃខ្មែរជាច្រើន រត់ចូលរួមជាមួយចលនានេះដែរ។ ការភ័យខ្លាចបណ្តាលមកពីការមានការរំលោភបំពានពីសំណាក់បារាំង ដូចជាគំរូក្នុងការតាមចាប់ខ្លួនជនស្នេហាជាតិ ប៉ាច ឈឺន និងចុងក្រោយការចាប់ខ្លួនលោក ស៊ឺង ង៉ុកថាញ់ នាឆ្នាំ១៩៤៥គ.ស. ព្រមទាំងអ្នកពាក់ព័ន្ធដទៃទៀត នាពេលបារាំងវិលមកកម្ពុជា ជា លើកទី២ បានបង្ខំឱ្យកូនចៅ បក្សពួករបស់គាត់ រត់ទៅខេត្តបាត់ដំបង និង ចូលព្រៃរួបរួម ជាចលនាតស៊ូឥស្សរៈ ដើម្បីជាការដោះគេចខ្លួន និងបុព្វហេតុដ៏សមស្របមួយ គឺតស៊ូដណ្តើមឯករាជ្យជាតិ នោះសម្រាប់ ពួកអ្នកចេះដឹង។ ដូច្នេះមធ្យោបាយ ដ៏ល្អបំផុតសម្រាប់ពួកគេ គឺចាប់កាន់អាវុធប្រឆាំងបារាំង។ប៉ុន្តែបើតាមលោក វ.ម. រេឌ្ឌី (V.M. Reddi) យល់ថា ការចុះសន្ធិសញ្ញា ម៉ូឌុស វីវ៉ង់ឌី (Modus Vivendi)(កិច្ចសន្យាបណ្តោះអាសន្ន) ដែលទទួលស្គាល់ការវិលត្រឡប់របស់បារាំង មកកាន់ប្រទេសកម្ពុជា នាខែមករាឆ្នាំ ១៩៤៦គ.ស. នោះ បានបញ្ចេះអ្នកមិនពេញចិត្តនឹងរដ្ឋការបារាំង ឱ្យមានចំនួនកាន់តែច្រើនឡើង នាំគ្នាប្រឆាំងបារាំង ជាមួយខ្មែរឥស្សរៈដែរ។ ប៉ុន្តែ បើតាមលោកចន កូស(Jonh Coast)លើកឡើងថា"ខ្មែរឥស្សរៈមិនអាចធំធាត់ និងអាចទាក់ទាញការ ចាប់ អារម្មណ៍ពីសំណាក់បារាំង និងរដ្ឋាភិបាលខ្មែរបានទេ បើសិនគ្មាន ការគាំទ្រយ៉ាងខ្លាំងក្លាពីសំណាក់បញ្ញវន្ត និង ជនជាតិថៃដែលមានចិត្តស្អប់បារាំង និងលោភលន់ចង់បានទឹកដីខ្មែរនៅតំបន់អង្គរ។ ទោះជាយ៉ាងណាក៏ដោយ រហូតដល់ឆ្នាំ១៩៤៥គ.ស. ចលនាខ្មែរឥស្សរៈមានអ្នកគាំទ្រដែលមានសមានចិត្តទាំងប្រុសទាំងស្រីប្រហែល ៣០០០នាក់ និងមានកងទ័ពប្រហែល ១០០០ នាក់នៅឆ្នាំ១៩៤៦គ.ស. ដែលអ្នក ទាំងអស់នោះ ត្រៀមខ្លួនជាស្រេចសម្រាប់ការវាយប្រហារដំបូង នៅក្រុងសៀមរាបនៅថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៤៦គ.ស.។ដើម្បីសម្រេចបានគោលដៅរបស់ខ្លួន ក្រុមខ្មែរឥស្សរៈបាន

អនុវត្តនូវសកម្មភាពជាច្រើនគួរឱ្យកត់ សំគាល់ និងភ័យខ្លាចសម្រាប់ អាណានិគមបារាំង។ ពួកគេបានកំណត់ថា ធ្វើយ៉ាងណា ដើម្បីរំខានអាជ្ញាធរបារាំង ឱ្យមានការពិបាកគ្រប់គ្រងស្រុកទេស ដូចជាការធ្វើសង្គ្រាមទ័ពព្រៃ ការវាយឆ្មក់ និងការពួនស្ទាក់ ដើម្បីវាយយកភស្តុភារ និងសម្ភារៈផ្សេងៗដែលពួកបារាំងដឹកជញ្ជូនតាមផ្លូវ ជាដើមម៉្យាងវិញទៀតពួកគេក៏តែងបានបិទផ្លូវទំនាក់ទំនងរបស់បារាំង ដែលនាំឱ្យបារាំងពិបាកទាក់ទងគ្នាធ្វើការត្រួតត្រា ឬបង្ក្រាប ក្រុមបះបោរ។ ខ្មែរឥស្សរៈ កម្ចាត់ចោលនូវជនជាតិខ្មែរទាំងឡាយ ដែលនិយមចូលចិត្ត និងធ្វើគិញបារាំង ត្រូវរងការធ្វើទុក្ខបុកម្នេញពីកំហឹងរបស់ខ្មែរឥស្សរៈ។

លោក ប៊ុណ្ណ ចន្ទម៉ុល បាន រៀបរាប់ឱ្យយើងដឹងពីអំពើឃោរឃៅមួយចំនួនរបស់ឥស្សរៈ ដូចជាការសម្លាប់គិញបារាំងឈ្មោះ ប៊ុន ចាន់ និងការធ្វើទារុណកម្មគិញដទៃទៀត បែបស្រងែពៃន។ លើសពីនេះទៀត គាត់បានរៀបរាប់យ៉ាងលម្អិតអំពីព្រឹត្តិការណ៍វាយប្រហារលើកដំបូងរបស់ខ្មែរឥស្សរៈនៅទីក្រុងសៀមរាប នៅថ្ងៃទី៧ ខែសីហា ឆ្នាំ ១៩៤៦គ.ស.។ពួកកងឯកភាពរួមរបស់ខ្មែរឥស្សរៈ ជាអ្នកបានចាប់ផ្តើមចេញប្រតិបត្តិការវាយប្រហារនេះ។ ពួកគេបានបែងចែកគ្នាជាប្រាំក្រុម ទីមួយគឺក្រុមដឹកនាំដោយ ហែម សាវ៉ាង និង ហែម សាវ៉ាត (ជាបងប្អូនបង្កើតនឹងគ្នា) ដែលមានទិសដៅវាយសណ្ឋាគារខេត្ត។ ក្រុមទីពីរ គឺក្រុមសម្រាប់វាយបន្ទាយទាហានជើងខ្មៅ។ ក្រុមទីបីគឺ ក្រុមមានគោលដៅវាយប៉ុស្តិ៍ប្រៃសណីយ៍ និងផ្តាច់វិទ្យុ។ ក្រុមទីបួន វាយពន្ធនាគារ រំដោះអ្នកទោស។ ក្រុមទីប្រាំ ដឹកនាំដោយដាបឈួន មានគោលដៅវាយ តម្រួតខេត្ត និងផ្ទះគយ។ តែបើតាមការស្រាវជ្រាវរបស់ប្រវត្តិវិទូអូស្ត្រាលី ចន ទូលី (Jonh Tully) បានអះអាងថា ក្នុងការវាយប្រហារនេះ ប្រទេសថៃត្រូវបានបារាំងបន្ទោស និងចោទប្រកាន់ថា បានផ្សំគំនិតរៀបចំផែនការ និងបញ្ជាលើការវាយប្រហារនេះ។ តែតាម លោក ប៊ុណ្ណ ចន្ទម៉ុល អះអាងថា គឺពួកថៃក៏មិនបានចូលរួម ឬ ដឹងគម្រោងការណ៍នេះឡើយ។ ពួកខ្មែរឥស្សរៈផ្ទាល់តែម្តង ដែលរៀបចំការវាយប្រហារដូចខាងលើ។កងទ័ពខ្មែរឥស្សរៈបានវាយលុកក្រុងបានរយៈពេល ៤ម៉ោង តែព្រឹកឡើងត្រូវទ័ពបារាំងដេញវាយវិញយ៉ាងសង្កុញ។ ពួកគេប្រមូលជ័យភណ្ឌបានយ៉ាងច្រើន ពិសេសក្រុមប្រតិបត្តិការរបស់ ដាប ឈួន ដែលជាហេតុមួយធ្វើឱ្យគាត់មានឈ្មោះល្បីឡើង និងមានថវិកាច្រើនជាងក្រុមដទៃទៀត។ គាត់មិនបាន ត្រឡប់មកបាត់ដំបងវិញទេ ក្រោយការវាយបកយ៉ាងលឿនរបស់បារាំងនោះ។ ជាលទ្ធផលនៃការវាយប្រហារនេះ មានសាកសពស្លាប់នៅកន្លែង ៣០នាក់ រួមបញ្ចូលទាំងនាយទាហានបារាំង៧នាក់ផងដែរ។ ចំណែកកាសែតបាងកកប៉ុស្តិ៍ថាភាគីទាំងសង្ខាងមានមនុស្សស្លាប់ និងរបួសប្រហែលច្រើនជាងនេះ។លោកអ្នកតស៊ូ និងអ្នកស្រាវជ្រាវទាំងអស់នេះអាចផ្តល់ព័ត៌មានបានល្អ និងច្បាស់ជាងគ្នាដោយអន្លើ ហើយអាចបង្គ្រប់គ្នាទៅ វិញទៅមក បង្កើតបានជាទិដ្ឋភាពប្រវត្តិសាស្ត្រមួយនៃ ចលនាខ្មែរឥស្សរៈ។ លោកប៊ុនចាន់ម៉ុល គាត់បានបញ្ជាក់ គឺគាត់បានដកខ្លួនចេញពីចលនាខ្មែរឥស្សរៈ តាំងពីភាគដំបូងនៃចលនាតស៊ូនេះម្ល៉េះ។ ម្ល៉េះហើយ មានអាថ៌កំបាំងជាច្រើនទៀត ពិសេស ជីវភាព និងរបត់នៃកម្លាំងតស៊ូរបស់ខ្មែរឥស្សរៈរបស់ទ្រង់ ចន្ទរង្សី (នាពេលក្រោយ) ដែលគាត់មិនអាចដឹង ឬមិនបានសរសេរប្រវត្តិវិទូឥណ្ឌា វ. ម. រេឌ្ឌី ទាំងប្រវត្តិវិទូអូស្ត្រាលី ចន ទូលី ក៏ដូចជាអ្នកស្រាវជ្រាវមួយចំនួនទៀត ពិតជាមិនបានសិក្សាលំអិតពីចលនាតស៊ូនេះទេ។ ជាក់ស្តែង នៅក្នុងស្នាដៃរបស់ខ្លួន ដែលមានចំណងជើងថា"ប្រវត្តិសាស្ត្រនៃចលនា(ទាមទារ)ឯករាជ្យកម្ពុជា" លោក រេឌ្ឌី បានត្រឹមតែរៀបរាប់ ខ្លះតែប៉ុណ្ណោះអំពីចលនាខ្មែរឥស្សរៈ។ ម៉្យាងទៀត គាត់បានត្រឹមតែបញ្ជាក់ពីរូបភាពទូទៅនៃចលនានេះ ដោយគាត់

ចំណាយពេលវែង ថ្លាថ្លែងពីការទាមទារឯករាជ្យរបស់ក្រុមតស៊ូដោយវិធីការទូតនៅក្នុងស្រុក។ ចលនាទាមទារឯករាជ្យនៅក្នុងស្រុកនេះរួមមាន ក្រុមអភិរក្សនិយម (the Conservatives) ដែលមានសម្តេច នរោត្តម សីហនុ ជាប្រមុខ, ក្រុម មជ្ឈន្តិកជន (the Moderators) ដែលមានពួកបញ្ញវន្តសម័យទំនើបជាគោល, ហើយគាត់បានបន្តចាត់ទុកពួកខ្មែរឥស្សរៈសេរីនិយម ជាផ្នែកមួយនៃក្រុមក្រោយនេះ។ ឯក្រុមទីបី គឺពួកឧទ្ទាមព្រៃ (the Radicals) ដូចជាពួកខ្មែរវៀតមិញ។ទោះជាគាត់បានបែងចែក យ៉ាងច្បាស់ដូចនេះហើយក្តីតែគាត់មិនបានថ្លឹងថ្លែងស្រាវជ្រាវពីជំពូកអ្នកតស៊ូទាំងបីក្រុមនោះ ឱ្យស្មើគ្នាទេ។ ទន្ទឹមនឹងនេះចលនាខ្មែរឥស្សរៈត្រូវបានលោក ចន ទូលី ពិភាក្សានិងចំណាយត្រឹមតែមួយជំពូកតូច នៃសៀវភៅ "ប្រវត្តិអាណាព្យាបាលបារាំង នៅ កម្ពុជា" របស់លោក ដែលមានជាង ៥០០ទំព័រ ឯណោះ។

លោក ប៊ុណ្ណ ចន្ទម៉ុល បានយល់ថា"ការវាយប្រហារលើក្រុងសៀមរាបនេះ មិនសន្មតថា ជោគជ័យ ឬបរាជ័យអ្វីទេ។ ប៉ុន្តែជាស្រមោលតស៊ូមួយ ដែលធ្វើឱ្យពួកបារាំងភ័យផ្អើមមាត់មួយគ្រាដ៏ធំទៅដែរ ហើយវាអាចបណ្តុះទឹកចិត្តខ្មែរឯទៀត ឱ្យភ្ញាក់រលឹកឡើងផង។" នេះគ្រាន់តែជាការព្រមានមួយរបស់ខ្មែរឥស្សរៈទៅលើ អាណានិគមបារាំង។ ឯការពិតនោះ គឺចាប់តាំងពីពេលនោះមករហូតដល់ពេលបារាំង សម្រេចចិត្តប្រគល់ឯករាជ្យពេញបរិបូណ៌ ដល់ប្រទេសកម្ពុជានោះ ចលនាខ្មែរឥស្សរៈបានបង្កបញ្ហាច្រើនណាស់ដល់អាជ្ញាធរបារាំង។តាមការអួតអាងរបស់អតីតខ្មែរឥស្សរៈម្នាក់ឈ្មោះ ក្រុត ជាមបានប្រាប់ទៅលោកប៊ិន យៀនិនថាប្រសិនបើបារាំងមិនបានផ្តល់ឯករាជ្យពេញបរិបូរណ៍ ដល់សម្តេច សីហនុនោះទេ ម្ល៉េះទ្រង់ពិតជាប្រឈមមុខនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរជាមិនខាន ព្រោះនាពេលនោះដែនដីកម្ពុជាមួយភាគបី ត្រូវបានត្រួតត្រាដោយខ្មែរឥស្សរៈ។ ឆ្លើយតបនឹងការអួតអាងនេះ សម្តេច សីហនុ ផ្ទាល់បានសារភាពប្រាប់រដ្ឋមន្ត្រីការបរទេសថៃ ថាបើគ្មានព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យពីបារាំងទេ ប្រទេសកម្ពុជាប្រហែលមានផ្ទុះឡើងនូវការបះបោរធ្ងន់ធ្ងរប្រឆាំងនឹងបារាំង និងប្រឆាំងរាជានិយមផ្ទាល់តែម្តង។ ប្រសិនបើព្រះអង្គមិនប្រញាប់ប្រញាល់ ទាមទារឯករាជ្យពេញបរិបូណ៌ទេនោះ ប្រជាជនកម្ពុជាមុខតែនឹងងាកទៅសង្ឃឹមលើលោក ស៊ឺងង៉ុកថាញ់ និង ខ្មែរឥស្សរៈជាពុំខាន ព្រោះពួកគេប្រាថ្នាចង់បានតែឯករាជ្យពេញបរិបូរណ៍ ដោយមិនពេញចិត្តនឹងអ្វីដែល ព្រះអង្គពីមុនបានហៅថា "ឯករាជ្យ៥០ភាគរយ" នោះទេ។ដូច្នេះចង់ ឬមិនចង់ ទាំងបារាំង ទាំងសម្តេច សីហនុត្រូវប្រុងប្រយ័ត្នចំពោះការរីកឡើងនូវឥទ្ធិពល របស់ពួកខ្មែរឥស្សរៈ និងដឹងនូវតួនាទីសំខាន់របស់ខ្មែរឥស្សរៈ ក្នុងការទាមទារឯករាជ្យសម្រាប់ជាតិ មាតុភូមិកម្ពុជា។ ដូច្នេះ សម្តេចសីហនុ ត្រូវស្រូតរូតផ្តើមយុទ្ធនាការទាមទារឯករាជ្យឱ្យបានមុនការគំរាមកំហែងចំពោះព្រះអង្គដែលអាចកើតឡើង ហើយដើម្បីជម្នះលើការគំរាមកំហែងនេះ ព្រះអង្គត្រូវឈានទៅមុខ មុនពួកជាតិនិយមឥស្សរៈ និងពួកកុម្មុយនិស្តវៀតមិញ។ តែទោះជាយ៉ាងណាក៏ដោយ ចាប់ពី ឆ្នាំ ១៩៤៨គ.ស. ចលនាខ្មែរឥស្សរៈ ក៏កាន់តែរីកធំ តាមការដឹកនាំរបស់មេផ្ទាល់របស់ពួកគេតែរៀងៗខ្លួន ដូចជា ខ្មែរឥស្សរៈ ក្រោមការដឹកនាំរបស់ ដាប ឈួន, ពុយ ឆាយ លាវ កែវមុនី មានទីតាំងនៅ ភ្នំដងរែក, កោតក់ និងក្រុម ខ្មែរឥស្សរៈរបស់ទ្រង់នរោត្តមចន្ទរង្សី ដែលកំពុងបោះទីតាំងនៅតានៀវ នៃខេត្តកំពង់ស្ពឺ។[11]។

[11] -ស្វែងយល់ពីចលនាខ្មែរឥស្សរៈ"របស់លោក" ថា លាងអាង"។(

# ១០. អំណាចកូសាំងស៊ីនលើកម្ពុជា

## ១០.១. ការតែងតាំងមន្ត្រីជាន់ខ្ពស់

មានការបង្កើតក្រុមប្រឹក្សាមួយមានមន្ត្រីជាន់ខ្ពស់ប្រាំនាក់ ដែលអាចពិភាក្សាកិច្ចការរដ្ឋបាលដោយគ្មានវត្តមានព្រះរាជា ។ ក្រុមប្រឹក្សានេះទទួលភារៈកិច្ចត្រួតពិនិត្យមើលនូវការអនុវត្តច្បាប់ សិក្សាពី កំណែទម្រង់ដែលត្រូវធ្វើ និងពិនិត្យមើលនូវរាល់កិច្ចព្រមព្រៀងទាំងឡាយរវាងរដ្ឋាភិបាល និងជនទាំង ឡាយណាដែលចង់ធ្វើអាជីវកម្មក្នុងព្រះរាជាណាចក្រ ។ទឹកដីខ្មែរទាំងមូលនិងត្រូវបានបែងចែកជាមណ្ឌលរដ្ឋបាលធំៗប្រាំតាមចំនួននៃរដ្ឋមន្ត្រីទាំងប្រាំដែលត្រូវគ្រប់គ្រងមណ្ឌលនីមួយៗ ។ ចំនួនខេត្តត្រូវពង្រួញពី ៥៧ខេត្ត មក ៥០ខេត្ត ។ តពីនេះទៅពួក អ្នកម៉ឺនមន្ត្រីត្រូវទទួលប្រាក់បៀវត្សមានកម្រិតជាក់លាក់ ហើយត្រូវហាមឃាត់មិនឱ្យធ្វើជំនួញ ។ ពួកឧកញ៉ាហ្លួង មានភារៈកិច្ចទៅត្រួតមើលតាមខេត្តនានាត្រូវលុបចោល ព្រោះពួកនេះបានទាញយក ប្រយោជន៍ពីព្រះរាជាផង និងពីរាស្ត្រផង ។ ម្យ៉ាងទៀតរាស្ត្រមានសិទ្ធិជ្រើសរើសមេស្រុក មេឃុំ និងជំទប់របស់ខ្លួន ។

## ១០.២. ការកំណត់ព្រំដែនរដ្ឋបាល

តើបារាំងជាន់លើទឹកដីឥណ្ឌូចិនដោយរបៀបណា ? ដោយយកលេសថា ស្តេចយួនធ្វើទុកបុក ម្នេញលើរូបអ្នកផ្សាយសាសនាជាតិបារាំង ពួកនេះក៏បានវាយយកកំពង់ផែយួន **តួរ៉ាន** នៅថ្ងៃទី១ ខែ កញ្ញា ឆ្នាំ ១៨៥៨គ.ស. ។ បន្ទាប់មក**បន្ទាយព្រៃនគរ**ត្រូវបានបារាំងវាយយកបាននៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៨៥៩ គ.ស. ទៀត ។ តាមសន្ធិសញ្ញាចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ១៨៦២គ.ស. ស្តេចយួនទីឌឹកបានទទួលស្គាល់ជា កម្មសិទ្ធិរបស់បារាំងនូវខេត្តបៀនវ៉ា ( កំពង់ស្រកាត្រី ) , យ៉ាឌិញ ( ឧកញ៉ាឌិន ) , ឌិញទឿង ( មេសរ ) និង **កោះត្រឡាច** ដែលយួនបានយកពីខ្មែរពីមុនមក ។ មកដល់គ.ស. ១៨៦៤គ.ស. ព្រះបាទ**នរោត្តម** អមដោយលោក**ឌូដាដឺឡាក្រេ** ( Doudart De Lagree ) ផងបានយាងទៅជួបលោកទេសាភិបាល**ឡា ក្រង់ឌីយ៉េរ** ( La Granduere ) នៅ**ព្រៃនគរ** ហើយធ្វើសំណូមពរឱ្យបារាំងបង្វិលសងខេត្តទាំងបីមកវិញគឺ **លង់ហោ មាត់ជ្រូក** និង**ពាម** ។ ឯបារាំងបានទទួលពាក្យជាមួយព្រះអង្គពីរឿងនេះហើយ ។ប៉ុន្តែនៅ ឆ្នាំ១៨៦៧ គ.ស. ដោយខេត្តទាំងបីកន្លែងយួនធ្វើសកម្មភាពប្រឆាំងបារាំង ពួកគេបានបញ្ចូលខេត្តទាំងនេះ ជាអាណានិគមរបស់ខ្លួន ដោយភ្លេចគិតដល់ពាក្យសន្យាជាមួយព្រះបាទនរោត្តម ។ដូច្នេះចាប់ពីឆ្នាំ ១៨៦៧គ.ស. ទឹកដីកម្ពុជាក្រោមទាំងមូលបានក្លាយជាអាណានិគមរបស់បារាំង ។ ឯកម្ពុជាលើតាមលក្ខណៈជាប្រទេសក្រោមអាណាព្យាបាល ម្លោះហើយអាជ្ញាធរបារាំងនៅកូសាំង ស៊ីន តែងតែធ្វើការកែប្រែបន្ទាត់ព្រំដែនតាមទំនើងចិត្តដោយសំអាងលើបញ្ហានយោបាយ និងសេដ្ឋកិច្ច ។ ហើយការកែប្រែសុទ្ធតែចំណេញទឹកដីនៅកូសាំងស៊ីនជានិច្ច ហើយមិនអើពើដល់ការតវ៉ារបស់ព្រះ រាជាខ្មែរ និងមិនស្នើសួរព្រះយោបល់ផងដែរ ។ចាប់ពីឆ្នាំ ១៨៩៣គ.ស. ដល់ ១៩១៤គ.ស. ប្រទេសខ្មែរត្រូវបានបាត់បង់ទឹកដីថែមទៀត ព្រមទាំងកោះ ដូចជា **កោះត្រល់**ជាដើម ដោយបារាំងកេងប្រវ័ញ្ចយកទៅបញ្ចូលក្នុងអាណានិគម**កូសាំងស៊ីន** ឬក្នុង ប្រទេសអណ្ណាមទៅវិញ ។

## ១០.៣. ការកំណត់ដែនពាណិជ្ជកម្ម

សម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី ព្រះចៅក្រុងកម្ពុជានិងសាលមុង អ្នកការទូតពេញសមត្ថភាពនៃព្រះចៅអធិរាជណាប៉ូឡេអុងមានការព្រមព្រៀងគ្នា ដូចតទៅៈ

-មាត្រា១ ជនជាតិបារាំង និងទទួលបាននូវកិច្ចការពារពេញលេញនៅក្នុងប្រទេសកម្ពុជាទាំងមូលចំពោះខ្លួននិងកម្មសិទ្ធិរបស់គេព្រមទាំងមានសិទ្ធិចំពោះឯកសិទ្ធិ និងផលប្រយោជន៍គ្រប់បែបយ៉ាង ដូចដែលត្រូវបានផ្តល់ ឬនឹងត្រូវផ្តល់ចំពោះជនជាតិនៃប្រជាជាតិទាំងឡាយដែលមានលក្ខណៈអនុគ្រោះបំផុតនោះ ។

-មាត្រា២ ជនជាតិបារាំងអាចធ្វើដំណើរ និងតាំងទីលំនៅដោយសេរីនៅគ្រប់អាណាខេត្តនៃព្រះរាជាណាចក្រកម្ពុជា អាចប្រតិបត្តិសាសនាជារបស់សាធារណៈអាចទិញដីធ្លីសង់វិហារទីលំនៅ និងអាចប្រកបរបរជំនួញ ឬឧស្សាហកម្មនៅលើដីធ្លីនោះ ។

-មាត្រា៣ ជនជាតិបារាំងនឹងអាចទិញ និងលក់ទំនិញ នៅគ្រប់អាណាខេត្តនៃប្រទេសកម្ពុជា ដោយមានសេរីភាពពេញលេញ និងពុំមានការរារាំងពីក្រុមហ៊ុនផ្តាច់មុខណាមួយ លើកលែងតអាជីវកម្មអាភៀនដែលជាអាជីវកម្មផ្តាច់មុខរបស់រដ្ឋ។

-មាត្រា៤ ទំនិញនាំចូល ឬនាំចេញដោយនាវាបារាំង នឹងត្រូវបង់ពន្ធគយតែមួយគត់ ៣% តាមមុខតម្លៃ ដែលត្រូវបង់នៅពេលដាក់ទំនិញចុះឬពេលផ្ទុកទំនិញហើយមិនត្រូវបង់ពន្ធក្នុងស្រុក ពន្ធឆ្លងកាត់ ឬពន្ធផ្សេងដទៃទៀតឡើយ ។

-មាត្រា៥ នាវាចំបាំង និងនាវាជំនួញបារាំង នឹងចូលមកក្នុងកំពង់ផែទាំងអស់កម្ពុជាដោយសេរីដោយមិនត្រូវបង់ពន្ធ និងត្រូវចាត់ទុកដូចជានាវាកម្ពុជា និងរបស់ព្រះរាជាផ្ទាល់ព្រះអង្គ ។

-មាត្រា៦ ព្រះចៅអធិរាជបារាំងអាចតែងតាំងមន្ត្រីកុងស៊ុល ឬភ្នាក់ងារកុងស៊ុលនៅប្រចាំការលើប្រទេសកម្ពុជា ឬភ្នាក់ងារកុងស៊ុលទាំងនោះមានសិទ្ធិបង្ហូតទង់ជាតិបារាំងនៅលើទីលំនៅរបស់ខ្លួន ព្រមទាំងបានទទួលនូវឯកសិទ្ធិនិងអភ័យឯកសិទ្ធិ ដូចភ្នាក់ងារដែលមានឋានៈស្មើ នៃប្រជាជនដែលបានទទួលនូវការអនុគ្រោះបំផុតនោះ ផងដែរ ។

-មាត្រា៧ ជនជាតិបារាំងដែលធ្វើដំណើរក្នុងឋានៈជាអ្នកប្រាជ្ញដូចជាធម្មជាតិ នឹងទទួលពីអាជ្ញាធរខ្មែរនូវការយកចិត្តទុកដាក់ពិសេស ដើម្បីជួយពួកគេក្នុងការបំពេញបេសកកម្ម និងជួយសម្រួលដល់ការធ្វើដំណើរនៅក្នុងប្រទេស ។

-មាត្រា៨ នៅពេលដែលជំនួញបារាំង ត្រូវទទួលរងនូវការវាយប្រហារឬធក់ប្លន់ពីពួកចោរ នៅក្នុងដែនទឹកនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរដែនដីនៅជិតនោះ ពេលបានដឹងអំពីហេតុការណ៍នេះហើយ ត្រូវតាមដានយ៉ាងសកម្មរកជនល្មើស ដើម្បីចាប់ខ្លួននិងផ្តន្ទាទោសទៅតាមច្បាប់ ទំនិញដែលរឹបអូសយកបាននៅកន្លែងណាមួយដែលនៅមានសភាពបែបណាក៏ដោយ និងត្រូវប្រគល់ទៅឱ្យម្ចាស់ដើមវិញ ក្នុងករណីអវត្តមានម្ចាស់ដើម ត្រូវប្រគល់ទៅឱ្យអាជ្ញាធរបារាំង ដែលមានភារកិច្ចប្រគល់ទំនិញទាំងនោះទៅឱ្យម្ចាស់ដើមនៅពេលក្រោយ ប្រសិនបើគេមិនអាចចាប់ជនល្មើសបាន និងមិនអាចរឹបអូសទំនិញទាំងអស់មកវិញបានទេ មន្ត្រីខ្មែរនឹងត្រូវរួចខ្លួនពីការពិន័យជាប្រាក់ ប្រសិនបើមានភស្តុតាងបញ្ជាក់ថាគេបានខិតខំអស់លទ្ធភាព ។ ចំពោះអំពើធក់ប្លន់នៅលើកម្មសិទ្ធិ របស់ជនជាតិបារាំង ដែលស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាក៏ដូច្នេះ

អាជ្ញាធរកម្ពុជានឹងមិនទទួលរងនូវការពិន័យជាប្រាក់ទេ ប្រសិនបើមានភស្តុតាងបញ្ជាក់ថា គេបានខិតខំអស់ពីលទ្ធភាព ដើម្បីតាមចាប់ខ្លួនជនល្មើសនិងរឹបអូសយករបស់ទាំងនោះមកវិញ ។

-មាត្រា៩ ទ្រព្យសម្បត្តិរបស់ជនជាតិបារាំងណាម្នាក់ ដែលទទួលមរណភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា នឹងត្រូវប្រគល់ទៅឱ្យអ្នកស្នងមរតក ឬឱ្យទៅជនផ្សេងទៀតតាមបណ្តាំរបស់អ្នកស្លាប់ ឬបើពុំមានអ្នកទាំងនោះទេ ត្រូវប្រគល់ទៅឱ្យអាជ្ញាធរបារាំងដែលមានភារកិច្ចបញ្ជូនទ្រព្យសម្បត្តិនោះ ទៅឱ្យអ្នកមានសិទ្ធិទទួលមរតក ។

-មាត្រា១០ បេសកបព្វជិតបារាំងនឹងមានសិទ្ធិទេសនា និងបង្រៀនអំពីសាសនាកាតូលិកមានសិទ្ធិសង់វិហារ លំនៅដ្ឋានអ្នកបួស មន្ទីរពេទ្យ និងសំណង់ផ្សេងៗទៀត នៅទីណាក៏បានក្នុងព្រះរាជាណាចក្រកម្ពុជា។ គេនឹងមានសេរីភាពពេញលេញក្នុងការធ្វើដំណើរនៅក្នុងប្រទេសកម្ពុជា ដោយគ្រាន់តមានលិខិតបញ្ជាក់ពីមកុងស៊ុលបារាំង ឬករណីអវត្តមានមន្ត្រីកុងស៊ុល ត្រូវមានលិខិតពីមន្ត្រីសង្ឃដែលបញ្ជាក់ពីអត្តសញ្ញាណរបស់ជនទាំងនោះ និងមានសេចក្តីបញ្ជាក់ពីចៅហ្វាយខេត្តនៃខេត្តណាមួយដែលគេចង់ធ្វើដំណើរទៅកាន់នោះ។

-មាត្រា១១ សាសនាកាតូលិក ដែលបានទទួលការអនុញ្ញាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ( អស់រយៈពេលជាងពីរសតវត្សកន្លងមកហើយនោះនឹងត្រូវ ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជាចាត់ទុកថាជាសាសនាមួយក្នុងចំណោមសាសនារបស់រដ្ឋ ប្រជាជនកម្ពុជាដែលកាន់សាសនាកាតូលិក ចាប់ពីពេលនេះតទៅត្រូវស្ថិតនៅក្រោមបទបញ្ញត្តិនៃសាសនាដទៃដែលជួយ និងសាសនាកាតូលិកនោះឡើយ ។នៅពេលអនាគត ត្រូវមានឧបសគ្គអ្វីមករារាំង ដោយការបំភិតបំភ័យឬដោយមធ្យោបាយផ្សេងទៀត ចំពោះជនជាតិខ្មែរដែលកាន់សាសនាកាតូលិក ។ក្រោយពីបានទទួលសច្ចាប័ន ពីព្រះចៅអធិរាជបារាំងនិងព្រះរាជាណាចក្រកម្ពុជា នឹងត្រូវប្រកាសឱ្យប្រើភ្លាមនៅគ្រប់អាណាខេត្តនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យអាជ្ញាធរខ្មែរបានដឹងនិងកុំឱ្យគេប្រើវិធានការបង្កក្តី ទោមនស្សចំពោះជនជាតិខ្មែរដែលប្រតិបត្តិសាសនានៃប្រជាជាតិបារាំងដែលជាសម្ព័ន្ធមិត្តនិងប្រទេសកម្ពុជា ។

-មាត្រា១២ ព្រះរាជាណាចក្រកម្ពុជា នឹងផ្តល់ចំពោះព្រះចៅអធិរាជបារាំងនូវសិទ្ធិជ្រើសរើសឈើម៉ៃសាក់ និងឈើដទៃៗទៀតនៅក្នុងព្រៃនៃព្រះរាជាណាចក្ររបស់ព្រះអង្គ សម្រាប់យកទៅស្ថាបនានៃកងទ័ពជើងទឹកបារាំង ព្រមទាំងផ្តល់នូវសិទ្ធិឱ្យអារត្រចៀក និងនាំឈើយទាំងនោះទៅកាន់ប្រទេសបារាំង ដោយពុំមានការចំណាយអ្វីក្រៅពីពន្ធ១០ ដែលត្រូវបង់ជាឈើ ឬតាមមុខតម្លៃជាពន្ធដែលកំណត់ដោយច្បាប់ខ្មែររួចមក ហើយ និងកំពុងនៅជាធរមាន ។

-មាត្រា១៣ អនុសញ្ញានេះត្រូវបានតាក់តែងជាភាសាបារាំង និងជាភាសាខ្មែរដែលមានខ្លឹមសារដូចគ្នា

-មាត្រា១៤ អនុសញ្ញានេះនឹងត្រូវប្រកាសឱ្យប្រើក្រោយពីបានទទួលសច្ចាប័នពីព្រះចៅអធិរាជបារាំង សច្ចាប័ននឹងត្រូវធ្វើនៅក្នុងចន្លោះពេលមួយឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខានេះទៅ ឬអាចឆាប់ជាងនេះ ប្រសិនបើអាចធ្វើបាន ។ចុះហត្ថលេខា និងបោះត្រាដោយព្រះរាជាកម្ពុជា និងអ្នកការទូតបារាំងនិងប្រទេសកម្ពុជា ថ្ងៃទី ១៨ តុលា ១៨៨៦គ.ស. ។

# ១១. ចលនាតស៊ូទាមទារឯករាជ្យ

## ១១.១. ខាងក្នុងរដ្ឋាភិបាល

ចលនាបះបោរ ក្នុងសម័យអាណានិគមដោយសារតែការមិនពេញចិត្តចំពោះរដ្ឋការអាណាព្យាបាលបារាំងពីសំណាក់ប្រជារាស្ត្រខ្មែរទូទៅ និងជាពិសេសពីសំណាក់ពួកបញ្ញវន្តខ្មែរខ្លះទើបបណ្តាលឱ្យមានផ្ទុះឡើងនូវចលនាបះបោរប្រឆាំងបារាំងកើតមានជាបន្តបន្ទាប់ដូចខាងក្រោម៖

ក្នុងសម័យអាណានិគមបារាំង បារាំងបានជំរិតទារពន្ធដារយ៉ាងធ្ងន់ធ្ងរ ទៅលើប្រជាជនកម្ពុជា ។ មានតាំងពីពន្ធមនុស្សពន្ធដីពន្ធលំនៅ ពន្ធសត្វពាហនៈ ពន្ធយានជំនិះ ពន្ធអាជីវកម្មជាដើម។ដើម្បីបង់ពន្ធជាប្រាក់កាសឱ្យបារាំងកសិករខ្មែរបានខិតខំពង្រីកដំណាំឧស្សាហកម្ម មានកៅស៊ូជាដើមព្រមទាំងពង្រីកដំណាំដទៃទៀតមានស្រូវ ពោត សណ្តែក។ ប៉ុន្តែទិន្នផលដំណាំមិនសូវល្អទេ។ផលស្រូវក្នុងមួយហិចតាបានត្រឹមតែពី ១ តោន ដល់ ១.២តោនប៉ុណ្ណោះ។ដូចនេះហើយកសិករក្រីក្រ ក៏ក្លាយទៅជាអ្នកជាប់បំណុលពួកឈ្មួញកណ្តាល និងឈ្មួញបរទេស។ ចំណែកការប្រាក់វិញមានកម្រិតខ្ពស់ណាស់ ហើយ ការប្រាក់នេះបានក្លាយជាបន្ទុកដ៏ធំសម្រាប់ប្រជាជនកម្ពុជា។ដោយហេតុមានការជំរិតទារពន្ធដារយ៉ាងធ្ងន់ធ្ងរ ពីសំណាក់ អាណានិគមបារាំងនេះហើយ បានជាធ្វើឱ្យ ចលនាបះបោរពីសំណាក់ពួកបញ្ញវន្តខ្មែរ បានងើបឡើងតវ៉ាអាណានិគមបារាំងជាបន្តបន្ទាប់ក្នុងនោះមានដូចជា៖

**-ការបះបោរនៅឆ្នាំ ១៨៨៥-១៨៨៦គ.ស.**

ទសវត្សដំបូងៗនៃការគ្រប់គ្រងបារាំងនៅកម្ពុជារួមមានកំណែទម្រង់មួយចំនួនក្នុងនយោបាយកម្ពុជាដូចជាការកាត់បន្ថយអំណាចរបស់ព្រះមហាក្សត្រ និងលុបចោលទាសភាព ។ នៅឆ្នាំ ១៨៨៤គ.ស. ទេសាភិបាលឥណ្ឌូចិន លោកគាល-អង្គថ្វាន-ផ្រង់ស្វាស-ធមសុន មានបំណងរំលំព្រះ មហា ក្សត្រ និងធ្វើការគ្រប់គ្រងពេញទីលើកម្ពុជាដោយការបញ្ជូនកងកម្លាំងតូចមួយក្រុម ចូលទៅកាន់ព្រះបរមរាជវាំងនៅភ្នំពេញ។ ការបង្កចលា ចល នេះទទួលបានជោគជ័យតិចតួច ដូចនោះហើយអគ្គទេសា ភិបាលសហភាពឥណ្ឌូចិនបានបង្អាក់ការធ្វើអាណានិគមកិច្ចពេញលេញដោយសារ តែអាចនិងមានការប៉ះទង្គិចគ្នា ជាមួយប្រជាជនខ្មែរ ហើយអំណាចព្រះមហាក្សត្រត្រូវបានកាត់បន្ថយនៅត្រឹមតែជា**ស្តេចមានតែឈ្មោះប៉ុណ្ណោះ** ។ នៅឆ្នាំ ១៨៨៥ គ.ស. ព្រះអង្គម្ចាស់**ស៊ីវុត្ថា** ព្រះអនុជបិតាតែមួយរបស់ព្រះបាទនរោ ត្តម និងក៏ជាគូប្រជែងរាជបល្ល័ង្កផងនោះ បានដឹកនាំការបះបោរដើម្បីទម្លាក់ព្រះបាទនរោត្តមដែលមានបារាំងនៅពីក្រោយខ្នង ។ បន្ទាប់ពីទ្រង់ត្រឡប់ពីការនិរទេសនៅស្រុកសៀម ។ ដោយប្រមែប្រមូលបាន ការគាំទ្រពីសំណាក់ពួកអ្នកប្រឆាំងនឹងព្រះបាទនរោត្តមនិងពួកបារាំង ទ្រង់ស៊ីវត្ថាបានដឹកនាំការបះ បោរមួយដែលដើមឡើយបានប្រមូលផ្តុំគ្នានៅក្នុងព្រៃនៅ**ក្រុងកំពត** ។ កងកម្លាំងបារាំងក្រោយមកបាន ជួយដល់ព្រះនរោត្តមដើម្បីបង្ក្រាបស៊ីវត្ថា ដែលស្ថិតក្រោមកិច្ចព្រមព្រៀងដែលប្រជាជនកម្ពុជាត្រូវទម្លាក់អាវុធចុះ និងទទួលស្គាល់ឯករាជ្យជាអំណាចកំពូលលើសគេក្នុងដែនអាណាព្យាបាលនេះ ។

**-ការបះបោររបស់ស៊ីវត្ថា (១៨៦១គ.ស.-១៨៩១នៃ១គ.ស.)**

ព្រះអង្គស៊ីវត្ថា ត្រូវជាបុត្រទី៣របស់ព្រះបាទអង្គឌួង ។ ដោយសារការច្រណែននឹងព្រះរាមទាំង ពីរគឺ នរោត្តម និងស៊ីសុវត្ថិដែលមានសិទ្ធិឡើងសោយរាជ្យ ព្រះអង្គក៏គេចបាត់ពីរាជធានីតែម្តង (១៨៦១គ.ស. ) ពីឆ្នាំ១៨៦១គ.ស.-១៨៦២គ.ស.។ ទោះបីពុំមានវត្តមានព្រះអង្គស៊ីវត្ថាក៏ដោយ ចលនាបះបោរដែលបង្ក ដោយបក្សពួកព្រះអង្គបានលើកទៅវាយបានក្រុងភ្នំពេញ រួចកាន់កាប់រាជធានីឧដុង្គទៀត ។ ចលនា ស៊ីវត្ថា បានបង្កការលំបាកយ៉ាងច្រើនដល់ព្រះមហាក្សត្រ និងពួកអាណាព្យាបាលបារាំង ។ ព្រះបាទ នរោត្តមភៀស ខ្លួនទៅសៀម ហើយយាងត្រឡប់មកវិញនៅខែ មីនា ឆ្នាំ ១៨៦២គ.ស. បន្ទាបពីចលនា បះ បោរត្រូវបាន បង្រ្កាប ។ ស៊ីវត្ថារត់រួចហើយទៅរកកងទ័ពធ្វើការបះបោរបន្តទៀត ។ នៅឆ្នាំ ១៨៧៦គ.ស. ព្រះស៊ីវត្ថាបានត្រ ឡប់ចូលស្រុកវិញហើយបំបះបំបោររាស្ត្រម្តងទៀតនៅត្រង់ បាភ្នំ រំដួល ព្រៃវែង ។ តែ លើកនេះព្រះមហា ឧបរាជស៊ីសុវត្ថិត្រូវចាត់ឱ្យចេញបង្ក្រាបបានរាបទាបវិញ ដោយមានជំនួយពីកងទ័ពបារាំង ។ ឪកាសល្អបាន កើតមានឡើង នៅពេលនោះចុះហត្ថលេខាដោយបង្ខំលើសន្ធិសញ្ញា **ព្រះបាទ នរោត្តម ថុំសុន** ។ នៅឆ្នាំ ១៨៨៥គ.ស. ព្រះអង្គស៊ីវត្ថាបានរៀបចំខ្លួនប្រុងវាយឧដុង្គ ប៉ុន្តែត្រូវអាក់ខានទៅវិញ ហើយបានដកខ្លួនទៅព្រំ ដែនសៀម ។

ក្នុងខែ ឧសភា ឆ្នាំ ១៨៨៦គ.ស. បក្សពួករបស់ព្រះអង្គ**ស៊ីវត្ថា** ចំនួន៥០០នាក់ ចូលវាយ**ភ្នំពេញ** តែ ត្រូវគេកម្ចាត់ចេញ ។ បន្ទាប់ពីពេលនោះមករហូតដល់ឆ្នាំ១៨៩០គ.ស. ការរំដើបរំដួលជាច្រើនកន្លែងបានធ្វើ ឱ្យកងព័ទបារាំង និងកងព័ទព្រះមហាក្សត្រខូចខាតយ៉ាងដំណំ ។ក្នុងខែ មីនា ឆ្នាំ១៨៩០គ.ស. ពួកអាណា និគមបារាំងបានស្នើសុំជួបជាមួយព្រះ**ស៊ីវត្ថា** ដើម្បីធ្វើកិច្ចចរចា នេះគ្មានលទ្ធផលអ្វីសោះ ។

នៅក្នុងឆ្នាំ ១៨៩១គ.ស. ព្រះអង្គស៊ីវត្ថាបានទទួលមរណៈភាពដោយជម្ងឺនៅភាគខាងជើងសម្បូរ ។ ចលនាបះបោររបស់ព្រះអង្គក៏បែកខ្ញែកគ្នាបន្តិចម្តងៗ ។ព្រះបាទនរោត្តម សីហនុ បានឡើងសោយរាជ្យ នៅ ឆ្នាំ ១៩៤១គ.ស.គឺចំពេលដែលភ្លើងសង្គ្រាមលោកលើកទី២ កំពុងឆាបឆេះ។ នៅពេលដែលពួកយោធា និយមជប៉ុនកំពុងមានជ័យជម្នះនៅចុងបូព៌ា និងអាស៊ីអាគ្នេយ៍។បារាំងចុះចាញ់សង្គ្រាមហើយបានព្រមព្រៀង ស្តីពី កិច្ចការពាររួមលើដែនដីឥណ្ឌូចិន។ម្តងនេះប្រទេសកម្ពុជាបានធ្លាក់ទៅនៅក្រោមរបបត្រួតត្រាពីរត្រួតគឺ អាណានិគមបារាំង និងរបបយោធាជប៉ុន។ជប៉ុនបានយកប្រទេសកម្ពុជាធ្វើជាមូលដ្ឋានទ័ព និងគាបយកវត្ថុ ធាតុដើមខាងកសិកម្មដោយតម្លៃថោកបំផុត។ តាមការទាមទារ របស់ជប៉ុនរដ្ឋាភិបាលបារាំងបង្ខំឱ្យកសិករខ្មែរ លក់ផលដំណាំបំពេញតម្រូវការសេដ្ឋកិច្ចជប៉ុន។ នៅឆ្នាំ ១៩៤១គ.ស. ដល់ ១៩៤៨គ.ស.ផលិតផល កសិកម្មនៅកម្ពុជាបានថយចុះ។

**-ក្រុមដែលលំអៀងទៅខាងជប៉ុន**

មេដឹកនាំក្រុមនេះគឺលោក សឹង ង៉ុកថាញ់។ នៅឆ្នាំ១៩៤៥គ.ស.ជប៉ុនបានបណ្តេញបារាំងចេញពី ប្រទេសកម្ពុជា ហើយប្រកាសកម្ពុជាជារដ្ឋឯករាជ្យដោយលើក សឹង ង៉ុកថាញ់ ឱ្យធ្វើជានាយករដ្ឋមន្រ្តីតែតាម ការពិតរដ្ឋាភិបាលរបស់សឹងង៉ុកថាញ់គ្រាន់តែជារដ្ឋាភិបាល ទីងមោប៉ុណ្ណោះនៃឯករាជ្យក្លែងក្លាយដែលផ្តល់ ដោយពួកយោធានិយមជប៉ុន។ ក្រោយពេលជប៉ុនចាញ់សង្គ្រាមលោកលើកទី២បារាំងបានវិលមកកាន់កម្ពុជា ជាថ្មី កងទ័ពរបស់ សឹង ង៉ុកថាញ់បានប្រឹងទប់ទល់នឹងបារាំងដែរ តែពុំអាចតស៊ូនឹងបារាំងបានឡើយហើយ សឹង ង៉ុកថាញ់ ត្រូវបានចាប់ខ្លួនយកទៅឃុំនៅប្រទេសបារាំង។នៅឆ្នាំ ១៩៥១នៃ គ.ស. បារាំងបានដោះលែង

សឹង ង៉ុកថាញ់តាមសំណើរបស់ព្រះមហាក្សត្រខ្មែរ។ នៅដើមឆ្នាំ ១៩៥២គ.ស.សឹង ង៉ុកថាញ់បានរត់ទៅប្រទេសថៃបង្កើតចលនាខ្មែរសេរី។

**-ក្រុមដែលមាននិន្នាការខាងកុម្មុយនិស្ត**

នៅឆ្នាំ ១៩៣០គ.ស. ចលនាប្រជារាស្ត្របានរួបរួមជាមួយក្រុមដែលមាននិន្នាការខាងកុម្មុយនិស្ត។ បន្ទាប់ពីការមកដល់នៃរបបឃោជានិយមជប៉ុន ក្រុមនេះបានក្លាយទៅជារណសិរ្សអ្នកស្នេហាមាតុភូមិខ្មែរឬហៅខ្មែរឥស្សរៈ។ ស្ថានភាពរង្គោះរង្គើខាងសេដ្ឋកិច្ច និងសង្គមនៃប្រទេសផ្តល់ឱ្យរណសិរ្សខ្មែរឥស្សរៈ ពង្រីកមូលដ្ឋាននយោបាយ និងពង្រីកចម្បាំងឈ្លបទៅលើពួកអាណានិគម។ ទោះបីមានប្រតិបត្តិការបង្ក្រាបដ៏សាហាវអំពីកងទ័ពបារាំង ក៏ដោយក៏កងកម្លាំងខ្មែរឥស្សរៈ បានវាយប្រហារតបវិញធ្វើឱ្យបារាំងមានការខូចខាតយ៉ាងដំណំ។

## ១១.២. ខាងក្រៅរដ្ឋាភិបាល

ចលនាបះបោរប្រឆាំង នឹងបារាំងក្រោយសន្ធិសញ្ញាឆ្នាំ ១៨៦៣គ.ស. និងឆ្នាំ ១៨៨៤គ.ស.។ទោះបីសន្ធិសញ្ញាថ្ងៃទី ១១ ខែសីហា ឆ្នាំ ១៨៦៣គ.ស. ស្ថិតនៅក្នុងការផ្តល់ប្រយោជន៍ឱ្យគ្នាទៅវិញ ទៅមកក៏ដោយក៏អ្នកស្នេហាជាតិបានក្រោកឈរកាន់អាវុធប្រឆាំងនឹងការប៉ុនប៉ងរបស់បារាំងក្នុងការ ត្រួតត្រាប្រទេសខ្មែរ ។ បន្ថែមលើនេះសន្ធិសញ្ញាថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៨៨៤គ.ស. រឹតតែបង្កភាពក្តៅ ក្រហាយទ្វេឡើងគ្រប់ស្រទាប់ប្រជាជនខ្មែរ ដែលនាំឱ្យមានចលនាតស៊ូជាហ៊ូហែរដូចជា៖

**ចលនាតស៊ូរបស់អាចារ្យស្វា (១៨៦៤គ.ស.-១៨៦៦គ.ស.)**

តាមពាក្យតំណាលតៗមកលោក **អាចារ្យស្វា**ជាខ្ញុំបម្រើរបស់នាម៉ឺនម្នាក់ ( **ឧកញ៉ាវិជ្ជោសុខ** ) នៅរាជធានីឧដុង្គ ។ ពេលបារាំងមកតាំងអាណាព្យាបាលលើប្រទេសខ្មែរនៅឆ្នាំ១៨៦៤គ.ស. លោក អាចារ្យស្វាបានភៀសខ្លួនទៅវាយយកបានខេត្តទ្រាំង ( កំពត-តាកែវ ) ហើយលើកឆ្ពោះមកភ្នំពេញ ទៀត ។ ក្រោយមកកងព័ទព្រះបាទនរោត្តមដោយមានជំនួយពីកងព័ទបារាំង បានធ្វើប្រតិបត្តិការសឹក ដេញចាប់លោកនៅថ្ងៃទី ១៩ ខែសីហា ឆ្នាំ ១៨៦៦គ.ស. ។ លោកត្រូវបារាំងនិរទេសយកទៅដាក់នៅកោះ ត្រឡាច រួចបញ្ជូនទៅ**កោះរេអុយនីញុង** ( Reunion ) ហើយទីបំផុតបញ្ជូនទៅ**កោះអង់ទី** ( Antilles ) ។

**ចលនាបះបោររបស់ពោធិកំបោរ (១៨៦៥គ.ស.-១៨៦៧គ.ស.)**

លោក**ពោធិកំបោរ** ជាព្រះសង្ឃមួយអង្គមានដើមកំណើតនៅ**ខេត្តរោងដំរី** ។ នៅឆ្នាំ១៨៦៥គ.ស. បារាំងបានផ្តល់មធ្យោបាយជាលុយកាក់ឱ្យលោករស់នៅ**ព្រៃនគរ** ដើម្បីឃ្លាំមើលសកម្មភាពលោកតែ ប៉ុណ្ណោះ នៅខែសីហា ឆ្នាំ ១៨៦៦នៃ គ.ស. លោកបានភៀសខ្លួនចូលទៅ**ខេត្តរោងដំរី**ហើយបង្ករកងទ័ពនៅទីនោះ ។ នៅខែក្រោយមកមានមេទាហានបារាំងពីរនាក់ត្រូវអ្នកស្នេហាជាតិខ្មែរសម្លាប់ ។ ទ័ពបារាំងនៅ**ព្រៃនគរ** បានលើកទៅបម្រុងនឹងកម្ចាត់លោក ។ នៅខែធ្នូ ឆ្នាំ១៨៦៦គ.ស. កងកម្លាំងពោធិ៍កំបោរមានអ្នកចូលរួម ប្រហែលមួយម៉ឺននាក់ ។ ចលនានេះធ្វើសកម្មភាពនៅព្រំដែនលាវ តាមតំបន់សងខាងទន្លេមេគង្គ និងតំបន់ចន្លោះទីក្រុងឧដុង្គ និងភ្នំពេញ ។ លោកបានឆ្លងចូលក្នុងប្រទេសខ្មែរ ហើយលើកព័ទឆ្ពោះទៅ **រាជធានីឧដុង្គ** និង **ភ្នំពេញ** ។ ប៉ុន្តែនៅខែមករា ឆ្នាំ ១៨៦៧គ.ស. ស្ថានភាពសឹក និងនយោបាយនៅប្រទេស ខ្មែរកាន់តែតឹងតែង

ឡើង រាស្ត្រក្រោកឈរឡើងប្រឆាំងបារាំងគ្រប់ទីកន្លែង ។ កងព័ទលោកពោធិ៍កំបោរបានបរាជ័យនៅជាយ **ភ្នំពេញ** ។ ពោធិកំបោររត់ទៅពួននៅ**កំពង់ស្វាយ** រួចត្រូវកងព័ទបារាំងចាប់ ហើយសម្លាប់យកក្បាលមកដោត នៅ**ក្រុងឧដុង្គ** ។

## ១២. ផលវិជ្ជមាននិងអវិជ្ជមាននៃអាណាព្យាបាលបារាំង

### ១២.១. ផលវិជ្ជមាន

នៅខែធ្នូ ឆ្នាំ១៨៨៤គ.ស. ទេសាភិបាលកូសាំស៊ីនបានផ្ញើរលិខិតមួយច្បាប់ជូនដំណឹងមកអ្នកតំណាងអាណាព្យាបាលបារាំងនៅក្នុងក្រុងភ្នំពេញថា ដាវមានខ្សែរក្រវ៉ាត់ចំនួន៣៦ កាំភ្លើងរ៉េវុលចំនួន៦ដើម និងគ្រាប់កាំភ្លើងចំនួន៥០០គ្រាប់និងត្រូវបញ្ជូនឱ្យមកនគរបាល ក្រុងភ្នំពេញដោយដាវសម្រាប់ផ្តល់ឱ្យភ្នាក់ងារម្ចាស់ស្រុក ឬស្រុកអាយ ឯកាំភ្លើងខ្លីសម្រាប់ផ្តល់អោយស្នងការបារាំង។

-ការរៀបចំកំពង់ផែក្រុងភ្នំពេញឆ្នាំ១៨៨៥គ.ស. នាយកំពង់ផែពានិជ្ជកម្មបានស្នើរសុំអ្នកតំណាងអាណាព្យាបាលបារាំងឱ្យមានការរៀបចំនគរបាលកំពង់ផែទីក្រុងភ្នំពេញដើម្បីបង្កើនការត្រួតពិនិត្យលើនាវា។

-កំណើតមន្ទីរពេទ្យព្រះកេតុមាលាឆ្នាំ១៨៨៥គ.ស. នៅខែសីហា ឆ្នាំ១៨៨៥គ.ស. មន្ទីរពេទ្យប្រក់ស្លឹកមួយនៅខាងជើងវត្តភ្នំត្រូវបានសាងសង់ឡើងសម្រាប់ព្យាបាល នាយទាហានបារាំងដែលរងរបួសដោយសារចលនាបះបោរប្រឆាំងនិងបារាំង ហើយក្រោយមកបានក្លាយជាមន្ទីរពេទ្យព្រះកេតុមាលា។ គួរកត់សម្គាល់ថាចាប់តាំងពីឆ្នាំ១៨៨៥គ.ស. កងទ័ពបារាំងបានកើនឡើងពី៦០នាក់ទៅ ១២០០នាក់។

សរុបសេចក្តីមក នៅពាក់កណ្តាលនៃសតវត្សទី១៩ រដ្ឋបាលបារាំងបានព្យាយាមគ្រប់គ្រងប្រទេសកម្ពុជា តាមរយៈការខិតខំស្វែងយល់ពីប្រវត្តិសាស្ត្រ វប្បធម៌ និតិសាស្ត្រ និង អតិតកាលនៃប្រទេសកម្ពុជា ក្នុងបំណងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និង ទទួលនូវសមានចិត្តពីប្រជាជនកម្ពុជា។ ពួកអ្នករដ្ឋបាល និងនាយទាហានបារាំង បានបំពេញការងារជាអ្នកគ្រប់គ្រងផង និង អ្នកស្រាវជ្រាវផង ដូចជាលោកអេទែន អៃមូនីញ៉េ (Etienne Aymonier) លោក ហ្សង់ មូរ៉ា (Jean Moura) និង លោក អាដេម៉ា ឡឺក្លែរ (Adhemard Leclere)ជាដើម។

-បារាំងបានបង្កើតសាលាចុងបូព៌ាប្រទេសដើម្បីស្រាវជ្រាវចងក្រង ផ្សព្វផ្សាយពីអរិយធម៌ សិល្បៈចម្លាក់ ប្រវត្តិសាស្ត្ររបស់ខ្មែរ និងជួសជុលប្រាសាទបុរាណខ្មែរជាច្រើន ធ្វើឱ្យមរតកអតីតកាលខ្មែរដែលកប់បាត់បានរស់ឡើងវិញ។ កិច្ចការនេះបានផ្តល់ប្រយោជន៍ជាច្រើនដល់ខ្មែរ ដូចជាការមានទំនុកចិត្ត និងមោទនភាពជាតិតាមរយៈភាពរុងរឿងនៃចក្រភពអង្គរ ព្រមទាំងពញ្ញាក់ស្មារតីខ្មែរឱ្យចេះសាមគ្គីតាមរយៈមេរៀនប្រវត្តិសាស្ត្រ

-ក្រោមការកៀបសង្កត់របស់បារាំង សៀមបានប្រគល់មកអោយខ្មែរវិញនូវខេត្តកោះកុង ម្លូរព្រៃ ទន្លេពៅ ស្ទឹងត្រែង បាត់ដំបង សៀមរាប សិរីសោភ័ណ

-បានធ្វើផែនទីដងរ៉ែកជាច្រើនផ្ទាំង ដែលទទួលស្គាល់ដោយរដ្ឋាភិបាលបារាំងសៀម។ ផែនទីទាំងនេះបានផ្តលសារៈប្រយោជន៍យ៉ាងខ្លាំងដល់កម្ពុជាក្នុងរឿងក្តីប្រាសាទព្រះវិហារ នៅតុលាការអន្តរជាតិទីក្រុងឡាអេ ប្រទេសហូឡង់។

-វិស័យរដ្ឋបាល៖ បារាំងបានកែទម្រង់រដ្ឋបាលខ្មែរឱ្យមានប្រសិទ្ធភាព និង មានរបៀបរៀបរយ។

-វិស័យសង្គម៖ការកែទម្រង់លើប្រព័ន្ធពន្ធដារ រដ្ឋបាល ការពង្រឹងច្បាប់កម្មសិទ្ធដីធ្លី និង ការលុបបំបាត់ទាសភាពបានធ្វើឱ្យមានការប្រែប្រួលវិស័យចិត្តសាស្ត្រសង្គម ការបង្កើតឡើងនូវការចុះបញ្ជីដីធ្លី និង ការបង្កើតនូវកម្មសិទ្ធិលើដីធ្លីបានផ្លាស់ប្តូរប្រពៃណីទំនៀមទម្លាប់បុរាណ ការបង្កើតប្រព័ន្ធច្បាប់ថ្មីធ្វើឱ្យសង្គមខ្មែរមានភាពម្ចាស់ការ និង ស្ថិរភាព ពិសេសម្ចាស់ដីតូចតាច

-វិស័យសិក្សាធិការ៖ បង្កើតសាលាតាមវត្ត សាលាតាមឃុំ និង សាលាបឋមសិក្សា រីឯសាលាមធ្យមសិក្សាដែលបង្កើតដំបូងមានអនុវិទ្យាល័យព្រះស៊ីសុវត្ថិមានការដាក់ទោសដល់ឪពុកម្តាយដែលមិនបានបញ្ជូនកូនទៅរៀន មានការបង្កើតគណកម្មាធិការរៀបចំវនានុក្រមខ្មែរ ដើម្បីធ្វើអោយភាសារជាតិមានលក្ខណៈប្រាកដនិយមនៅឆ្នាំ ១៩១៥គ.ស.

-វិស័យសេដ្ឋកិច្ច៖ ពឹងផ្អែកលើកសិកម្ម និង កសិករ ឧស្សាហកម្ម ដូចជា ម្រេច ក្រចៅ ថ្នាំជក់ កៅស៊ូ

-វិស័យកសិកម្ម៖ បារាំងបានបង្កើនផ្ទៃដីកសិកម្ម និង ដំណាំកៅស៊ូ។ កំណែទម្រង់នេះបានធ្វើឱ្យកម្ពុជាមានមុខមាត់លើទីផ្សារអន្តរជាតិ ព្រមទាំងទទួលបាននូវប្រព័ន្ធផ្គត់ផ្គង់ផលិតផលលើទីផ្សារ។

-វិស័យសុខាភិបាល៖ មានការបង្កើតមន្ទីរពេទ្យ

- វិស័យគមនាគមន៍៖ ការកសាងស្ពានព្រះមុន្នីវង្សឆ្លងកាត់ទន្លេបាសាក់ ផ្លូវរថភ្លើងមួយខ្សែប្រវែង ២៧៥គីឡូម៉ែត្រដែលតភ្ជាប់ពីភ្នំពេញទៅអារញ្ញដោយកាត់តាមប៉ោយប៉ែត ព្រមទាំងផ្លូវថ្នល់ជាច្រើនដូចជាផ្លូវអាណានិគម (ផ្លូវជាតិ)ផ្លូវខេត្ត និង ផ្លូវជនបទ។

-សភាសម្រាប់ឱ្យយោបល់មួយ(ភាសាខ្មែរ) តាមព្រះរាជបញ្ញត្តិថ្ងៃទី ១៨ ខែសីហា ១៩២៨គ.ស. បានបង្កើតឡើងសម្រាប់ ផ្តល់យោបល់ ដែលមានសមាជិក ៤៦នាក់ក្នុងចំណោមនេះ៤១នាក់ត្រូវបោះ ឆ្នោតជ្រើសរើសដោយពួកបញ្ញាវន្តនិង ៥នាក់ទៀតត្រូវតែងតាំងដោយគណៈរដ្ឋមន្ត្រី។

-ថ្ងៃទី១៨ ខែវិច្ឆិកា ១៩២៨គ.ស. សម្ពោធ ស្ពានព្រះមុនីវង្ស(ស្ពានក្បាលថ្នល់)ដែលឆ្លងកាត់ទន្លេបាសាក់ មានប្រវែង ២៩២ម. (ធ្វើពី បេតុង) ។ ក្រុមជុំនុំប្រែព្រះត្រៃបិដក បានបង្កើតនៅថ្ងៃទី១៤ ខែវិច្ឆិកា ១៩២៩គ.ស.ក្រុមនេះមានភារៈបកប្រែ ព្រះត្រៃបិដក(វិន័យបិដក សុត្តន្តបិដក និងអភិធម្មបិដក) ។ គម្ពីរទាំងបីនេះ មានទាំងអស់ ១១០ក្បាល។

-វិជ្ជាឋាន(វិទ្យាស្ថាន)**ពុទ្ធសាសនាបណ្ឌិត្យ** បានបង្កើតនៅឆ្នាំ១៩៣០គ.ស. មានភារៈធ្វើការសិក្សាស្រាវជ្រាវពី ព្រះពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជា ដោយមិនបាច់ចេញទៅបរទេស។ ព្រះរាជបញ្ញតិថ្ងៃទី១៦ ខែធ្នូ១៩៣០គ.ស. ដដែល ស្តីពីការៀបចំនូវ ការសិក្សាភាសាបាលី និងព្រះពុទ្ធលទ្ធិ ក្នុងខេត្តទាំងឡាយនៃព្រះរាជាណាចក្រនិងមានបង្កើតសាលាអនុវត្តសម្រាប់"គរុសង្ឃ" និមន្តទៅសិក្សាពីវិធីបង្រៀនតាមបែបទំនើប

-នៅឆ្នាំ១៩៣០គ.ស. ព្រះអង្គបានប្រកាសឱ្យប្រើនូវរាជបញ្ញត្តិ បង្កើតធានាគារសម្រាប់ផ្តល់ឥណទានឱ្យកសិករនៅ បាត់ដំបង ព្រៃវែង និង កំពង់ចាម

-នៅឆ្នាំ១៩៣១គ.ស. ទំហំផ្ទៃចម្ការកៅស៊ូ នៅមេមត់មាន៦០០០ហិចតា និងមានដើមកៅស៊ូ ៥៥០.០០០ដើម ដែលជាចម្ការធំបំផុតនៃពិភពលោកនាសម័យនោះ ។ ឯដំណាំថ្នាំជក់ និងដំណាំពោតក៏ត្រូវបានគេចាប់ផ្តើមដែរ

-នៅឆ្នាំ១៩៣២គ.ស. បានស្ថាបនារួច និងសម្ភោធ នូវផ្លូវរថភ្លើងពីភ្នំពេញទៅព្រំដែនសៀម ដោយកាត់តាម បាត់ដំបង មានប្រវែង ២៧៥គ.ម

-ឆ្នាំនៅ១៩៣៧គ.ស. ត្រូវបានកសាង **ប្រាសាទខេមរិន្ទនិងផ្សារថ្មី**



( **សកម្មភាពបារាំងចុះទារពន្ធ**ពីប្រជាជន )

-នៅថ្ងៃទី១២ ខែធ្នូ ១៩៣៧គ.ស. សន្ធិសញ្ញា បារាំង-សៀមបានឱ្យសច្ចានុម័តលើសន្ធិសញ្ញាឆ្នាំ១៩២៥គ.ស. ស្តីពីកិច្ចសន្យាគោរពបទបញ្ញា តុលាការអន្តរជាតិ នៅទីក្រុងឡាអេ ក្នុងករណីដែលមានវិវាទ រវាងភាគីទាំងពីរ។ ឆ្នាំ១៩៤០គ.ស. កងទ័ព អាល្លឺម៉ង់ វាយលុកចូលប្រទេសបារាំង (បារាំងត្រូវបរាជ័យក្នុងសង្គ្រាមលោកលើកទី២) ហើយសៀមបានឃុបឃិតជាមួយកងទ័ពជប៉ុនបានចុះសន្ធិសញ្ញា ក្រុង តូក្យូ ឆ្នាំ១៩៤០ គ.ស. ស្តីពីការកាត់ផ្តាច់អាណាខេត្តខ្មែរនូវទឹកដីខេត្តបាត់ដំបង សៀមរាបកំពង់ធំ យកទៅវិញ។

- បារាំងបានស្រាវជ្រាវ និងចងក្រងប្រវត្តិសាស្ត្រខ្មែរ
- បារាំងជួយអភិរក្ស និងផ្សព្វផ្សាយវប្បធម៌ ប្រពៃណីខ្មែរ
- បារាំងធ្វើទំនើបកម្មប្រព័ន្ធអប់រំ កសាងសាលារៀន មន្ទីរពេទ្យ រៀបចំរចនានុក្រមខ្មែរ
- បារាំងធ្វើកំណែទម្រង់វិស័យរដ្ឋបាល សេដ្ឋកិច្ច និងកសិកម្ម
- បារាំងកសាងហេដ្ឋារចនាសម្ព័ន្ធដូចជាកសាងផ្លូវថ្នល់ ស្ពាន រថភ្លើង
- នៅក្នុងការដឹកនាំនៅសម័យអាណានិគមបារាំង ១៨៦៣គ.ស.-១៩៥៣គ.ស. គឺ បារាំងបានកសាងប្រទេសឱ្យមានភាពរីកចម្រើន និងមានកេរ្តិ៍ឈ្មោះល្បីល្បាញនៅក្នុងតំបន់អាស៊ីអាគ្នេយ៍
- ធ្វើឱ្យគោលនយោបាយអព្យាក្រឹតនៅកម្ពុជាល្បីសុះសាយនៅក្នុងតំបន់ និង ត្រូវពង្រឹងបន្ថែម
- ពួកប្រឆាំងមិនហ៊ានប៉ះពាល់នយោបាយអព្យាក្រឹត
- ជួយការពារស្តេចខ្មែរ ក៏ដូចជាប្រជារាស្ត្រខ្មែរ ឱ្យរួចផុតពីការត្រួតត្រា របស់ពួកយួន និង សៀម
- ជួយទាមទារយកខេត្តមួយចំនួន ពីសៀមមកឱ្យខ្មែរវិញ ( ម្លូព្រៃ ទន្លេរពៅ និងខេត្តកោះកុង នៅឆ្នាំ ១៩០៤គ.ស. ព្រមទាំងខេត្តបាត់ដំបង និងមហានគរ សេរីសោភ័ណ្ឌ តាមរយៈសន្ធិសញ្ញាបារាំង សៀម ថ្ងៃទី ២៣ មីនា ១៩០៧គ.ស.

-ជួយបង្រឹងវិស័យអប់រំនៅ ស្រុកខ្មែរ

-លើកស្ទួយជីវភាពកម្មករ និងបង្កើតមន្ទីរពេទ្យទំនើបៗសម្រាប់កម្មករ

-មានការរីកចម្រើនលើវិស័យមួយចំនួនដូចជា វិស័យកសិកម្ម ឧស្សាហកម្ម គមនាគមន៍ ពាណិជ្ជកម្ម និង វិស័យវប្បធម៌

-ទាមទារយកដី និង ប្រាសាទព្រះវិហារដែលប្រទេសថៃបានបញ្ជូនកងទ័ពមកកាន់កាប់ដោយខុសច្បាប់ ចាប់ពីឆ្នាំ ១៩៥៤គ.ស. មកវិញនៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ១៩៦២គ.ស. ។

## ១២.២.ផលអវិជ្ជមាន

សង្គមខ្មែរបានលេចឡើងនូវសកម្មភាពពាណិជ្ជកម្ម យ៉ាងសកម្មក្នុងការទិញដូរអចលនវត្ថុ ការដាក់បញ្ចាំ និង ការធ្វើជំនួញ ស្រូវអង្ករនៅទីក្រុង ដែលជាទំនាក់ទំនងប្រព័ន្ធទីផ្សារ។ ស្របពេលជាមួយគ្នា យើងសង្កេតឃើញថា ពួកអ្នកមាននិងអ្នកជំនួញភាគច្រើនជាជនជាតិចិន និងយួន ឯកសិករខ្មែរភាគច្រើនក្លាយជាជនរងគ្រោះអស់ដីធ្លី ដោយការលក់បញ្ចាំ។

-បារាំងបានធ្វើការជិះជាន់ គាបសង្កត់ និង ប្រមូលពន្ធដារ គ្រប់ប្រភេទយ៉ាងធ្ងន់ធ្ងរដែលធ្វើឱ្យសង្គមខ្មែរកាន់តែក្រីក្រ

-បារាំងបានកែនប្រជាជនខ្មែរឱ្យបម្រើយោធាបារាំងក្នុងសង្គ្រាមលោកលើកទី១ និង លើកទី២

-ទឹកដីកម្ពុជាមួយចំនួនដែលស្ថិតនៅប៉ែកខាងកើតទន្លេមេគ្គងដូចជាអាតាពើរ (Attopeu) ត្រូវបានបារាំងសម្រេចប្រគល់ទៅឱ្យកូសាំងស៊ីន នៅឆ្នាំ១៨៩៣គ.ស.។ ទឹកដីដ៏មានជីវជាតិនេះ ផ្តល់សារសំខាន់យ៉ាងខ្លាំងក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និង នយោបាយ របស់ស្តែន ជាពិសេសកូសាំងស៊ីនដែលជាទឹកដីក្រោមការគ្រប់គ្រងផ្ទាល់របស់បារាំង។ បារាំងបានពន្យល់ពីហេតុផលនៃការកាត់ទឹកដីនេះទៅឱ្យកូសាំងស៊ីនថា ព្រះមហាក្សត្រខ្មែរ ព្រះបាទនរោត្តមបដិសេធមិនព្រមទទួលដោយសារ កង្វះខាតថវិការក្នុងការគ្រប់គ្រង។ ក្រោយមកទឹកដីអាតាពើត្រូវបានបារាំងកាត់ទៅឱ្យឡាវវិញ។

-នៅថ្ងៃទី៣១ខែមករាឆ្នាំ១៩៣៩គ.ស. បារាំងបានដាក់បញ្ចូលកោះត្រល់ទៅក្នុងផែនទីកូសាំងស៊ីន

-បារាំងបានកាត់ទឹកដីកម្ពុជាក្រោម (កូសាំងស៊ីន) ទៅឱ្យអំណាចស្តេចបាវដាយវៀតណាមនៅថ្ងៃទី ៤ ខែមិថុនា ឆ្នាំ១៩៤៩គ.ស.

-បារាំងបានប្រមូលយកវត្ថុកេតនភណ្ឌរបស់ខ្មែរទៅស្រុកបារាំង

-បារាំងបានធ្វើឱ្យសង្គមខ្មែរ កាន់តែក្រឡើង ទារពន្ធដារច្រើនប្រភេទ ចាប់ពីពន្ធស្រូវ សត្វពាហនៈ

-បារាំងបានកាត់ទឹកដីខ្មែរក្រោម និងដាឡាត់ឱ្យស្តេចយួនបាវដោយ (១៩៤៧គ.ស.) និងខេត្តត្រាចឱ្យសៀម

-បារាំងបានធ្វើទុក្ខបុកម្នេញមកលើប្រជាពលរដ្ឋខ្មែរ ដោយបានសម្លាប់ប្រជាជនស្លូតត្រង់ដែលបានបះបោរប្រឆាំងនិងពួកបារាំង ។

# សំណួរត្រិះរិះ

១.តើហេតុអ្វីបានជាកម្ពុជាស្វែងរកកិច្ចការបារពីបារាំង?
២.តើមានមូលហេតុអ្វីបានជាបារាំងងាកមកចាប់អារម្មណ៍ដាក់អាណាព្យាបាលលើប្រទេសកម្ពុជា?
៣.តើកម្ពុជាស្ថិតក្នុងទម្រង់នៃការគ្រប់គ្រងបែបអាណាព្យាបាលឬអាណានិគម?
៤.ចូរបញ្ជាក់ពីខ្លឹមសារសំខាន់នៃសន្ធិសញ្ញាអាណាព្យាបាលបារាំងលើប្រទេសកម្ពុជា?
៥.តើមានអ្វីកើតឡើងក្រោយពីរាជាភិសេកព្រះបាទនរោត្តមនៅថ្ងៃទី០៣ខែមិថុនា ឆ្នាំ១៨៦៤?
៦.ចូររៀបរាប់ពីស្ថាប័នសន្តិសុខ និងសណ្តាប់ធ្នាប់សង្គមនាសម័យអាណាព្យាបាលបារាំង?
៧.ចូរពណ៌នាពីកំណែទម្រង់ផ្ទៃក្នុងរបស់បារាំងនៅឆ្នាំ១៩១១។
៨.តើបារាំងប្រឈមនឹងបញ្ហាអ្វីខ្លះក្នុងការធ្វើឱ្យប្រទេសជិតខាងទទួលស្គាល់អំណាចខ្លួនលើទឹកដីខ្មែរ?
៩.ចូររៀបរាប់ពីកំណែទម្រង់ពន្ធដានៅកម្ពុជានាសម័យអាណាព្យាបាលបារាំង។
១០.តើអភិក្រមទំនើបកម្មដែលបារាំងបាននាំមកកម្ពុជាជួបនឹងកត្តាប្រឈមអ្វីខ្លះ និងផ្តល់នូវលទ្ធផលវិជ្ជមាន ឬផលអវិជ្ជមានក្នុងសង្គមខ្មែរ?
១១.តើសង្គ្រាមលោកលើកទី១បានជះឥទ្ធិពលអ្វីខ្លះដល់ប្រទេសកម្ពុជា?
១២.តើជប៉ុនមានឥទ្ធិពលយ៉ាងដូចម្តេចខ្លះពីភាពចុះខ្សោយរបស់បារាំងសង្គ្រាមលោកលើកទី២?
១៣.តើកម្ពុជាទាញយកផលចំណេញអ្វីខ្លះពីការចុះខ្សោយរបស់បារាំងក្នុងសង្គ្រាមលោកលើកទី២?
១៤.តើសង្គ្រាមលោកលើកទី២?
១៥.តើនយោបាយជាតិនិយមថៃធ្វើឱ្យប៉ះពាល់អ្វីខ្លះចំពោះវប្បធ៌មនយោបាយ សង្គម និងអធិបតេយ្យភាពកម្ពុជា?
១៦.តើនយោបាយកូសាំងស៊ីននាំមកនូវផលប៉ះពាល់អ្វីខ្លះដល់កម្ពុជាក្នុងអំឡុងសម័យអាណាព្យាបាលបារាំង?
១៧.តើកម្ពុជាទទួលឯករាជ្យពីបារាំងដោយរបៀបណា?
១៨.តើរបបអាណាព្យាបាលបារាំងបានផ្តល់ផលវិជ្ជមាន និងអវិជ្ជមានអ្វីខ្លះ?

# ឯកសារយោង


១. វច្ចនានុក្រមសម្តេចសង្ឃរាជជួនណាត ឆ្នាំ១៩៦២
២. សាំង ម៉ាក់សាង កូសាំងស៊ីនជាដីរបស់ខ្មែរ ឆ្នាំ១៩៧៣ទំព័រ៥៧
៣. ត្រឹងងា ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ១៩៧៣ ទំព័រ២៦៩
៤. មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ ឆ្នាំ១៩៨៥
៥. ឃីន សុខប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ ២០០៣
៦. ដា សោភារី និងហ៊ុយ ស៊ីវង ឆ្នាំ២០០៧
៧. អាជីម៉ា ឡឺក្លែរ ប្រវត្តិសាស្ត្រខ្មែរ ឆ្នាំ២០០៦
៨. វ៉ាន់ឌី កាអុន សុបិន និងការពិត ឆ្នាំ១៩៧២
៩. ប្រវត្តិសាស្ត្រខ្មែរ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈឆ្នាំ២០០៦
១០. លោក ថា**លាងអាង** ស្វែងយល់ពីចលនាខ្មែរឥស្សរៈ
១១. Google Search